អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 13-Dec-2013, 13:28
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចប្រជុំរៀបចំសវនាការក្នុងសំណុំរឿង០០២/០២

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៥នាទី**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក នីកូឡាស គូមជែន
*(Mr.Nicolas KOUMJIAN)*

លោក សេង ប៊ុនឃាង

លោក វេង ហ៊ត់

កញ្ញា សុង ឆវ័ន្ត

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឃីត រេយ៍ន័រ *(Mr. Keith RAYNOR)*

លោក ឌេល លីសាក់ *(Mr.Dale LYSAK)*

**ជនជាប់ចោទ៖**

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី បេនី យេ *(Ms. Beini YE)*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោកស្រី ជេត វណ្ណលី

លោកស្រី អេលេន័រ ហ្វែរណង់ដេស *(Ms. Eleonor FERNANDEZ)*

**ការិយាល័យរដ្ឋបាល៖**

ឯកឧត្តម ក្រាញ់ តូនី

លោក ឃ្នុត រ៉ូសាន់ហោក *(Mr. Knut ROSANDHAUG)*

លោក គង់ សុភី

**ផ្នែកគាំពារការពារក្តី៖**

លោក អ៊ីសាក់ អែនដឺលី *(Mr. Isaac ENDELEY)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោកស្រី គ្រីស្តាល់ ថមសុន *(Mr. Krystal THOMPSON)*

លោក សាន់ វ៉ាដា

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោកស្រី ជា លាង | ខ្មែរ |
| លោក ឃ្នុត រ៉ូសាន់ហោក | អង់គ្លេស |
| ឯកឧត្តម ក្រាញ់ តូនី | ខ្មែរ |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី បេនី យេ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[០៩:០៥:២០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

ជាបឋមសូមអញ្ជើញលោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន បុគ្គល និងភាគីទាំងឡាយដែលអង្គជំនុំជម្រះបានអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចប្រជុំនាពេលនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាបកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃនេះគ្រប់ភាគីទាំងអស់នៃរឿងក្តី និងបុគ្គលដែលអង្គជំនុំជម្រះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចប្រជុំថ្ងៃនេះមានវត្តមាន។ លើកលែងតែលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត សហមេធាវីនាំមុខអន្តរជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីអវត្តមានដោយមូលផ្ទាល់ខ្លួន។ ប៉ុន្តែលោកស្រីបានផ្ទេរសិទ្ធិជូនលោកស្រី បេនី យេ នៅក្នុងកិច្ចប្រជុំថ្ងៃនេះ។

សូមកត់សម្គាល់ដោយឡែកលោក ខៀវ សំផន មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ ចំណែកលោក នួន ជា តាមការបញ្ជាក់ពីក្រុមមេធាវីរបស់លោក បញ្ជាក់ថាលោកមិនមានបំណងចូលរួមក្នុងកិច្ចប្រជុំនេះទេ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រី សែ កុលវុឌ្ឍី។ បាទដោយនៅក្នុងកិច្ចប្រជុំរៀបចំសវនាការនេះមានការចូលរួមពីសំណាក់លោកជនជាប់ចោទ ខៀវ សំផន ពីបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការនេះ អង្គជំនុំជម្រះបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ទៅបន្ទប់ខាងក្រោម ដើម្បីឲ្យលោក ខៀវ សំផន អាចចូលរួម និងតាមដាននូវកិច្ចប្រជុំរបស់យើងនេះបាន។

ក្នុងនាមខ្ញុំជាប្រធាន និងជំនួសមុខឲ្យចៅក្រមសាលាដំបូងទាំងអស់ ខ្ញុំសូមស្វាគមន៍ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាដែលមានវត្តមាននៅក្នុងកិច្ចប្រជុំនេះ។ បន្ទាប់ពីបញ្ចប់សវនាការលើសំណុំរឿង០០២/០១ រួចមក អង្គជំនុំជម្រះសាលាដំបូងរៀបចំកិច្ចប្រជុំរៀបចំសវនាការនាពេលនេះ ក្នុងគោលចំណងដើម្បីជួយសម្រួលដល់ការរៀបចំផែនការជាមុនសម្រាប់ធ្វើសវនាការបន្តលើសំណុំរឿង០០២/០២។

[០៩:០៧:៤៨]

ជាបឋមកិច្ចប្រជុំនេះមានគោលបំណងដើម្បីដោះស្រាយទៅលើបញ្ហាបច្ចេកទេស និងការអនុវត្តនានាដែលជាបញ្ហាស្នូលនៃការរៀបចំសំណុំរឿង០០២/០២។ ហេតុដូច្នេះហើយ ទើបអង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីនានាពីចេតនារបស់ខ្លួន ក្នុងការលើកយកបញ្ហាចំនួនពីរមកពិភាក្សា។

១) វិសាលភាពសំណុំរឿង០០២/០២ ព្រមទាំងផ្នែកដែលត្រូវជំនុំជម្រះនាថ្ងៃខាងមុខ និង ២) កាលបរិច្ឆេទបណ្ដោះអាសន្នសម្រាប់សវនាការសំណុំរឿង០០២/០២។ ក៏ប៉ុន្តែ បន្ទាប់ពីមានសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចំពោះសេចក្ដីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី និងការចេញនូវសំអាងហេតុពេញលេញនូវសេចក្ដីសម្រេចរបស់ខ្លួនក្នុងពេលថ្មីៗនេះ ដោយផ្អែកលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលនោះ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីទាំងអស់ថា របៀបវារៈនៃកិច្ចប្រជុំត្រូវបានផ្លាស់ប្ដូរ ដោយយកចិត្តទុកដាក់ផ្ដោតជាសំខាន់ទៅលើបញ្ហានៃការចាត់តាំងបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ សម្រាប់អង្គជំនុំជម្រះសាលាដំបូងដែលត្រូវយកមកពិចារណាជាដំបូង ដោយបន្ទាន់បំផុត។

លើសពីនេះភាគីត្រូវបានជូនដំណឹងថា បញ្ហារដ្ឋបាលនៃការរៀបចំសវនាការក្នុងសំណុំរឿង០០២ ក៏នឹងត្រូវលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំនេះផងដែរ។ ដើម្បីសម្រួលដល់កិច្ចពិភាក្សាលើបញ្ហារដ្ឋបាលនៃការរៀបចំសំណុំរឿង០០ -- សវនាការក្នុងសំណុំរឿង០០២ អង្គជំនុំជម្រះសាលាដំបូងបានអញ្ជើញឯកឧត្តមប្រធាន និងលោកអនុប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមកចូលរួមនៅក្នុងកិច្ចប្រជុំនេះ ដើម្បីឆ្លើយបំភ្លឺទៅនឹងសំណួរនានារបស់អង្គជំនុំជម្រះ និងភាគីនៃរឿងក្ដី។ ប្រធានអង្គភាពគាំពារការពារក្ដីក៏ត្រូវបានអញ្ជើញឲ្យចូលរួម និងមានវត្តមាននៅក្នុងកិច្ចប្រជុំនេះដែរ ដើម្បីពិភាក្សាអំពីបញ្ហាដែលពាក់ព័ន្ធនឹងថវិកាផ្នែកការការពារក្ដីក្នុងករណីចាំបាច់។

អង្គជំនុំជម្រះសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅចំពោះឯកឧត្តមប្រធាន និងលោកអនុប្រធានការិយាល័យរដ្ឋបាល ព្រមទាំងប្រធានអង្គភាពគាំពារការពារក្ដីដែលបានអញ្ជើញចូលរួមនៅក្នុងកិច្ចប្រជុំថ្ងៃនេះ។

[០៩:១០:២៨]

តទៅនេះខ្ញុំនឹងលើកឡើងពីបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងរបៀបវារៈសម្រាប់ពិភាក្សាក្នុងកិច្ចប្រជុំរបស់អង្គជំនុំជម្រះសាលាដំបូងដូចដែលបានចែកជូនភាគីនានារួចហើយនៅថ្ងៃទី០៤ ខែធ្នូ

ឆ្នាំ២០១៣ មកពិភាក្សា។

របៀបវារៈទី១ លទ្ធភាពក្នុងការអនុវត្តអនុសាសន៍របស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២ សម្រាប់អង្គជំនុំជម្រះសាលាដំបូង។ នៅក្នុងសេចក្តីសង្ខេបសំអាងហេតុរបស់ខ្លួនចំពោះសេចក្តីសម្រេចលើកទី២លើការបំបែកកិច្ចដំណើរការនីតិវិធីកាលពីថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣នោះ អង្គជំនុំជម្រះតុលាការកំពូលបានស្នើឲ្យក្រុម -- ឲ្យបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២សម្រាប់អង្គជំនុំជម្រះសាលាដំបូង ដែលជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយនានាក្នុងការធានាថាផ្នែកបន្ទាប់នៃសំណុំរឿង០០២ ត្រូវបានចាប់ផ្តើមជំនុំជម្រះយ៉ាងឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន។

ក្នុងពេលថ្មីៗនេះ អង្គជំនុំជម្រះតុលាការកំពូលបានចេញសំអាងហេតុពេញលេញរបស់ខ្លួនចំពោះសេចក្តីសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ដែលក្នុងនោះអង្គជំនុំជម្រះតុលាការកំពូលបានចង្អុលបង្ហាញថាវាជាការទទួលខុសត្រូវរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូងក្នុងការពិនិត្យលទ្ធភាពដែលមានស្រាប់ក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ សម្រាប់ជំនុំជម្រះលើសំណុំរឿង០០២/០២។

ក្នុងគោលបំណងអនុវត្តអនុសាសន៍របស់អង្គជំនុំជម្រះតុលាការកំពូល ហេតុដូច្នេះហើយបញ្ហាបឋម អង្គជំនុំជម្រះសាលាដំបូងដាក់បញ្ចូលការពិភាក្សាអំពីក្របខ័ណ្ឌដែលអាចមានពាក់ព័ន្ធនឹងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ សម្រាប់អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរបៀបវារៈនៃកិច្ចប្រជុំរៀបចំសវនាការនេះ។

[០៩:១២:៤៤]

បន្ថែមពីលើការណែនាំដ៏ជាក់លាក់ដែលផ្តល់ឲ្យពីអង្គជំនុំជម្រះតុលាការកំពូលនោះ ការពិភាក្សានឹងជួយដល់យើងខ្ញុំជាប្រធានអង្គជំនុំជម្រះសាលាដំបូង ក្នុងការវាយតម្លៃអំពីក្របខ័ណ្ឌពេលវេលាសម្រាប់ការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២។ ការពិភាក្សានេះនឹងផ្តល់ឱកាសបន្ថែមដល់ភាគីនានាដើម្បីលើកឡើងអំពីមតិយោបល់របស់ខ្លួនទាក់ទងទៅនឹងបញ្ហានេះផងដែរ។ បន្ថែមពីលើនេះ កិច្ចប្រជុំនេះនឹងផ្តល់លទ្ធភាពដល់សាធារណជនឲ្យបានយល់អំពីការវិវត្តន៍ក្នុងការត្រៀមរៀបចំដំណើរការជំនុំជម្រះលើសំណុំរឿង០០២/០២ នាពេលខាងមុខនេះ។

ដូចដែលបានបញ្ជាក់នៅក្នុងអនុស្សរណៈកំណត់កាលបរិច្ឆេទបានចេញមុនកិច្ចប្រជុំនេះ។ អង្គជំនុំជម្រះសាលាដំបូងបានប៉ាន់ប្រមាណថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង អាចរក្សាបាននូវបុគ្គលិក

ទាំងអស់របស់ខ្លួន នោះយើងខ្ញុំប៉ាន់ប្រមាណថាសាលក្រមនៅក្នុងសំណុំរឿ០០២/០១ អាចនឹងត្រូវប្រកាសនៅក្នុងត្រីមាសទី២ ក្នុងឆ្នាំ២០១៤។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងនឹងចាប់ផ្តើមសវនាការលើសំណុំរឿង០០២/០២ ភ្លាមបន្ទាប់ពីនោះ ប្រសិនបើវិសាលភាពសម្រាប់ការជំនុំជម្រះដំណាក់កាលទី២នេះអាចត្រូវបានកំណត់មុនពេលនោះ។ យើងខ្ញុំបានកំណត់ថា ចៅក្រមទាំងអស់ដែលមាននៅក្នុងក្រុមប្រឹក្សាជំនុំជម្រះបច្ចុប្បន្នរបស់អង្គជំនុំជម្រះសាលាដំបូងព្រមទាំងបុគ្គលិកគាំទ្របច្ចុប្បន្នទាំងអស់ចាំបាច់ត្រូវតែផ្តោតជាចម្បងទៅលើការរៀបចំសាលក្រមក្នុងសំណុំរឿង០០២/០១ ដើម្បីធានាការចេញសាលក្រមបានឆាប់ទាន់ពេលវេលា។ ហេតុដូច្នេះប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះទី២ ចាំបាច់ត្រូវបង្កើតឡើងនោះ វាជាការចាំបាច់ណាស់ត្រូវតែមានចៅក្រមថ្មី។ យើងខ្ញុំបានវាយតម្លៃបន្ថែមទៀតថា ក្រុមប្រឹក្សាជំនុំជម្រះទី២នឹងត្រូវការមន្ត្រីច្បាប់ជាតិចំនួនប្រាំរូប និងមន្ត្រីច្បាប់អន្តរជាតិចំនួនប្រាំរូបដើម្បីជួយគាំទ្រដល់ការងាររបស់ក្រុមប្រឹក្សាជំនុំជម្រះទី២នេះ។

[០៩:១៥:១០]

តទៅនេះ គឺមានសំណួរមួយចំនួនចំពោះឯកឧត្តមប្រធាន និងលោកអនុប្រធានការិយាល័យរដ្ឋ-បាល។ ខ្ញុំសូមអញ្ជើញឯកឧត្តមប្រធាន និងលោកអនុប្រធានការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឆ្លើយតបនឹងសំណួរមួយចំនួនពាក់ព័ន្ធនឹងការអនុវត្តអនុសាសន៍របស់អង្គជំនុំជម្រះតុលាការកំពូលក្នុងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២ សម្រាប់អង្គជំនុំជម្រះសាលាដំបូងដូចខាងក្រោមនេះ។ ហើយបញ្ហាទាំងអស់នេះ អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅភាគីពាក់ព័ន្ធនានាអាចតាំងសំណួរបន្ថែមប្រសិនបើចាំបាច់។

សំណួរ៖ នៅក្នុងកថាខណ្ឌ៣ នៃអនុស្សរណៈរបស់ឯកឧត្តមប្រធាន និងលោកអនុប្រធានផ្ញើជូនប្រធានអង្គជំនុំជម្រះតុលាការកំពូល ឯកសារ E284/4/7/1/2 ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣ ឆ្លើយតបទៅនឹងដីកាដែលអង្គជំនុំជម្រះនេះ បានបង្គាប់ឲ្យការិយាល័យរដ្ឋបាលស្វែងរកលទ្ធភាពក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២នោះ ឯកឧត្តមប្រធាន និង លោកអនុប្រធានបានបញ្ជាក់ថា ការិយាល័យរដ្ឋបាលបានពិនិត្យមើលចំណងបញ្ហាផ្នែករដ្ឋបាល និងហិរញ្ញវត្ថុនៃការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២នៅក្នុងអង្គជំនុំជម្រះសាលាដំបូង ដោយបានបញ្ជាក់អំពីការត្រៀមខ្លួនរួចជាស្រេចក្នុងការគាំទ្រដល់សេចក្តីសម្រេចណាមួយដែលធ្វើឡើងដោយអង្គជំនុំជម្រះតុលាការកំពូល ឬដោយអង្គជំនុំជម្រះសាលាដំបូងដើម្បីបំពេញឲ្យបានត្រឹមត្រូវនូវដំណើរការនីតិវិធីរបស់តុលាការនៅក្នុងសំណុំរឿង០០២។ ការអះអាង

នេះត្រូវបានដកស្រង់ដោយអង្គជំនុំជម្រះតុលាការកំពូល នៅក្នុងកថាខណ្ឌ៧៤ នៃសេចក្ដីសម្រេចរបស់ខ្លួន,ឯកសារ E284/4/8, ដែលបានលើកឡើងថា "ពុំមានឧបសគ្គផ្នែកហិរញ្ញវត្ថុឬផ្នែករដ្ឋបាលទេ ក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២នោះ"។ តើឯកឧត្ដមប្រធាន និងលោកអនុប្រធាន អាចបង្ហាញឲ្យច្បាស់អំពីលក្ខណៈវិសាលភាពពិតប្រាកដនៃការពិនិត្យមើលឡើងវិញ ដែលឯកឧត្ដមប្រធាន និងអនុប្រធានបានធ្វើដែរឬទេ? តើនៅក្នុងការពិនិត្យឡើងវិញទាំងនោះ មានស្ថាប័នឬបុគ្គលណាខ្លះដែលត្រូវបានពិគ្រោះយោបល់នៅកម្រិតជាតិ ឬកម្រិតអន្តរជាតិដែរឬទេ?

សូមអញ្ជើញបាទ!

[០៩:១៧:៤៧]

**ឯកឧត្ដម ក្រាញ់ តូនី៖**

បាទ សូមគោរពសាលាដំបូងទាំងមូល សូមគោរពអង្គប្រជុំយើងទាំងមូលបាទ។ ទស្សនទានអ្វីដែលយើងត្រូវមាន ដែលយើងហៅថា សាលាជំនុំជម្រះទី២នោះ ត្រូវបានលើកឡើងតាមសេចក្ដីសម្រេចរបស់តុលាការកំពូល ហើយតុលាការកំពូលបានដាក់បញ្ជាឲ្យរដ្ឋបាលពិនិត្យមើលលទ្ធភាពក្នុងការគាំទ្រនៃទស្សនទានថ្មីនេះ។ បាទ ហេតុដូចនេះ យើង -- ដូចខ្ញុំបានជម្រាបជូន សរសេរនៅក្នុងអនុស្សរណៈរបស់យើងខ្ញុំ ដូចឯកឧត្ដមប្រធានបានលើកឡើងនោះហើយ។ សូមឲ្យសាលាដំបូង ជាពិសេសលោកប្រធានសម្រេចទៅលើការបង្កើត ឬមិនបង្កើតសភាទី២នេះ ខាងរដ្ឋបាលយើងនឹងត្រៀមជានិច្ចក្នុងការគាំទ្រនូវផែនការសកម្មភាពជាយថាហេតុរបស់អង្គជំនុំជម្រះសាលាដំបូងបាទ។ ទាំងទិដ្ឋភាពហិរញ្ញវត្ថុ ទាំងទិដ្ឋភាពរដ្ឋបាល ដូចយើងជាគ្មានអ្វីដែលយើងមិនអាចគាំទ្របានទេ។ នេះជាចម្លើយរបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណឯកឧត្ដម។

លោកអនុប្រធានមានអ្វីបន្ថែមទេ?

**លោក ឃ្លុត រ៉ូសាន់ហោក៖**

អរុណសួស្ដីលោក លោកស្រីចៅក្រម និងអស់លោក លោកស្រីដែលមានវត្តមាននៅក្នុងពេលនេះ។ ខ្ញុំគាំទ្រការលើកឡើងរបស់ប្រធានរដ្ឋបាលស្ដីទី។ អនុស្សរណៈរបស់យើងនៅក្នុងនោះមានជម្រើសពីរ។ ទី១ គឺអង្គជំនុំជម្រះបច្ចុប្បន្នបន្តដំណើរការទៅមុខទៀត ហើយយើងជាអ្នកគាំទ្រលើដំណើរការនេះ។ ជម្រើសទី២ គឺយើងក៏គាំទ្រជម្រើសផ្សេងមួយទៀត ប្រសិនបើអង្គជំនុំជម្រះបច្ចុប្បន្ននេះមិនអាច

ដំណើរការទៅមុខនោះថា បើសិនជាមានជម្រើសណាផ្សេង គឺយើងនៅបន្តគាំទ្រដដែល។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ព័ត៌មាននេះមានសារៈសំខាន់ណាស់ សូមអរគុណលោកច្រើន។ ក៏ប៉ុន្តែ លោកនិងឯកឧត្តមមិនទាន់បានឆ្លើយតបទៅនឹងសំណួរដែលប្រធានបានចោទសួរអម្បាញ់មិញនោះទេ។ សំណួរនោះ គឺពាក់ព័ន្ធទៅនឹងលក្ខណៈ និងវិសាលភាពពិតប្រាកដនៃការពិនិត្យឡើងវិញ ដែលលោកបានធ្វើដែរឬទេ? តើមានស្ថាប័ន ឬបុគ្គលណាខ្លះដែលត្រូវបានពិគ្រោះយោបល់ នៅកម្រិតថ្នាក់ជាតិ ឬអន្តរជាតិ? ហើយតើវាមានឧបសគ្គផ្នែកបច្ចេកទេស ឬរដ្ឋបាលដែរឬទេ ប្រសិនបើបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរនោះ? ដូចដែលឯកឧត្តមលោក និងលោក បានជ្រាបរួចមកហើយ អង្គជំនុំជម្រះនេះ គឺមានការព្រួយបារម្ភ ហើយធ្វើយ៉ាងណាថានៅពេលដែលដំណាក់កាលទី២ នៃសំណុំរឿង០០២ ដំណើរការទៅមុខទៀតនោះ គឺថាធ្វើយ៉ាងកុំឱ្យមានការរាំងស្ទះ ហើយយើងចង់ដឹងថាតើខាងរដ្ឋបាលអាចគាំទ្រផ្នែកហិរញ្ញវត្ថុ ហើយតើមានបញ្ហាបច្ចេកទេស ឧបសគ្គបញ្ហាបច្ចេកទេស ឬក៏បញ្ហាណាទៀតដែលអាចកើតឡើងដែរឬទេ? សូមឱ្យឯកឧត្តម និងលោកធ្វើការឆ្លើយតបទៅនឹងសំណួរ។

ហើយខ្ញុំដឹងថា ប្រហែលជាការិយាល័យរដ្ឋបាលមិនទាន់ធ្វើការពិគ្រោះយោបល់ជាមួយនឹងខាងអង្គជំនុំជម្រះសាលាដំបូង អំពីបញ្ហាបច្ចេកទេសនៅឡើយទេ ក៏ប៉ុន្តែប្រហែលជាឯកឧត្តម និងលោកបានពិគ្រោះយោបល់ជាមួយនឹងផ្នែកផ្សេងទៀត។ សូមអរគុណ។

[០៩:២១:៣៥]

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ សូមអរគុណចំពោះសំណួរនេះ។

សូមសាលាដំបូងជ្រាបថា ជាគោលការណ៍យើង ពេលណាដែលសាលាដំបូងសម្រេចដើរទៅផ្លូវណា ទៅឆ្វេង ឬទៅស្តាំ ត្រូវធ្វើតាមដំណើរការបច្ចុប្បន្ន ឬក៏មានបង្កើតសភាជំនុំជម្រះទី២? ទី៣? ទី៤? នោះហើយយើងនឹងធ្វើការពិគ្រោះយោបល់ជាលម្អិត ជាជំនាញ ជាមុតស្រួចជាមួយផ្នែកពាក់ព័ន្ធទាំងអស់។ ក៏ប៉ុន្តែអ្វីដែលខ្ញុំជម្រាបជូនអម្បាញ់មិញនេះ គឺថាជាគោលការណ៍ បើសិនជាសាលាដំបូងជ្រើសរើសដើរផ្លូវសភាជំនុំជម្រះទី២ ខាងផ្នែករដ្ឋបាល ខាងហិរញ្ញវត្ថុក៏គ្មានឧបសគ្គអ្វីជាដុំកំភួនដែលធ្វើឱ្យ

មិនបានទេបាទ។ ដោយសារយើងបានពិភាក្សាជាត្រួតៗហើយ សភាជំនុំជម្រះទី២ហ្នឹង តាមការពិតទៅក្នុងរូបភាព យើងមាន អ.វ.ត.ក មានរចនាសម្ព័ន្ធគ្រប់គ្រាន់ មានផ្នែកបច្ចេកទេសទូទៅ ដំណើរការដោយរលូន មាន -- យ៉ាងច្រើនត្រូវការអ្នកជំនាញច្បាប់មួយចំនួនថែម ឬក៏ចៅក្រមមួយចំនួនថែម ក្នុងរយៈពេលមួយ។ អ៊ីចឹងខ្ញុំយល់ឃើញថា វាអត់មានបញ្ហាជាដុំកំភួនទេបាទ។

ម្តងទៀត ជាសរុបមក ពេលណាសាលាដំបូងសម្រេចដើរផ្លូវណា យើងនឹងពិភាក្សាជាមួយនឹងសាលាដំបូងក្នុងការងារគ្រប់គ្រង រៀបចំផ្នែកបច្ចេកទេស ហិរញ្ញវត្ថុឲ្យបានសមស្របៈ។

បាទ ខ្ញុំសូមមានចម្លើយប៉ុណ្ណឹង។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

វាជាការលើកទឹកចិត្តមួយ នៅពេលដែលស្តាប់ថាមិនមានឧបសគ្គផ្នែកថវិកា ឬក៏បច្ចេកទេស។ ក៏ប៉ុន្តែខ្ញុំសូមលើកឡើងថា យើងនឹងត្រឡប់មកពិភាក្សាចំណុចនេះលម្អិតឡើងវិញ ក្នុងពេលកិច្ចប្រជុំរៀបចំសវនាការ។ ដោយសារតែបញ្ហានេះ ជាបញ្ហាមួយដែលពាក់ព័ន្ធទៅនឹងអង្គជំនុំជម្រះ ជាពិសេសនៅក្នុងការធានាថា កុំឲ្យមានការរអាក់រអួល នៅក្នុងការជំនុំជម្រះដែលនឹងធ្វើឡើង ដោយក្រុមប្រឹក្សាជំនុំជម្រះនេះ ឬក៏ក្រុមប្រឹក្សាជំនុំជម្រះទី២។ ហើយខ្ញុំគិតថាចម្លើយនេះ គឺជាការលើកទឹកចិត្តសម្រាប់យើង ក៏ប៉ុន្តែយើងនៅតែមានចំណុចសង្ស័យមួយចំនួនដដែល។

[០៩:២៤:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំដូចជាមិនសូវយល់សោះ យើងបានសួរសំណួរដូចជាសាមញ្ញទេ ចង់ដឹងថា តើមានការពិគ្រោះយោបល់ក្នុងក្របខ័ណ្ឌនៃការពិនិត្យមើលឡើងវិញដែរឬទេ? ខ្ញុំស្តាប់លោកបញ្ជាក់ថា មានការពិគ្រោះយោបល់នោះ គឺនៅពេលដែលមានការសម្រេចដោយប្រធានអង្គជំនុំជម្រះសាលាដំបូងហើយ។

ហើយខ្ញុំក៏ឮផងដែរថា មិនមានបញ្ហាអ្វីនោះទេ។ ដូច្នេះយើងត្រូវយល់ថាមតិយោបល់នេះ គឺត្រូវបានចែករំលែកដោយខាងអង្គការសហប្រជាជាតិនៅញូវយ៉ក ហើយនិងរាជរដ្ឋាភិបាលកម្ពុជាដែរឬទេ?

ខ្ញុំជឿថាសំណួរនេះគឺច្បាស់លាស់ តើនេះគឺគ្រាន់តែជាការបញ្ជាក់ធម្មតាពីសំណាក់លោក ឬក៏លោកមានព័ត៌មានច្បាស់លាស់ដែលអាចឲ្យយើងយល់បានថា តើអ្វីដែលលោកលើកឡើងនោះមានមូលដ្ឋានអ្វី?

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ ខ្ញុំចង់និយាយអ្វីដែលក្នុងដែនសមត្ថកិច្ចរបស់ខ្ញុំជាប្រធានរដ្ឋបាល។ ទស្សនទាននៃសភាទី២នេះត្រូវបានលើកឡើងពីសេចក្ដីសម្រេចលើរបស់សាលាកំពូលនៃ អ.វ.ត.ក យើងនេះ។ ហើយព័ត៌មាននេះត្រូវបានយល់ដឹងពីសំណាក់ដៃគូទាំងអស់ដែលពាក់ព័ន្ធទៅនឹង អ.វ.ត.ក ប៉ុន្តែអ្វីដែលខ្ញុំយល់ដឹងនេះគឺជាសារសម្រេចនៅក្នុងក្របខ័ណ្ឌយុត្តាធិការរបស់ អ.វ.ត.ក។ អ៊ីចឹង ខ្ញុំមិនដឹងថា យើងត្រូវសម្រេចជំនួសតុលាការ អ.វ.ត.ក ដើម្បី ធ្វើឲ្យទស្សនទាននេះក្លាយជាការពិត ឬយ៉ាងណាមិញនោះយើងមិនមានសមត្ថកិច្ចអីនឹងថ្លឹងទេ។ សមត្ថកិច្ចរបស់ខ្ញុំ កាតព្វកិច្ចរបស់ខ្ញុំគឺការងាររដ្ឋបាល ហើយនិងហិរញ្ញវត្ថុដើម្បីគាំទ្រឲ្យបានប្រសិទ្ធភាពនៃដំណើរការទូទៅរបស់ អ.វ.ត.ក។

[០៩:២៧:០២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

នេះគឺជាសំណួរផ្ទាល់ទៅលោក រ៉ូសាន់ហោក។ ខ្ញុំចង់ដឹងថា តើខាងរដ្ឋបាលដែលបានពិនិត្យមើលឡើងវិញនោះមានពាក់ព័ន្ធទៅនឹងការពិនិត្យទៅលើបញ្ហាគតិយុត្តដែលឬទេ? ជាបញ្ហាដែលអាចត្រូវបានលើកឡើងដោយចំណុចទាំងអស់នេះ។ ខ្ញុំនិយាយបែបនេះពីព្រោះថា យើងហាក់ដូចជាឃើញថាលោក រ៉ូសាន់ហោក លោក -- កាលពីថ្ងៃទី១៨ ធ្នូ ឆ្នាំ២០១៣ លោកបានផ្ញើអនុស្សរណៈមួយដែលមាននៅក្នុងសំណុំរឿងហើយ គឺលេខ E248/4/7/1 ហើយនៅក្នុងអនុស្សរណៈលោកបានយោងទៅមាត្រា៣ នៃកិច្ចព្រមព្រៀង ហើយខ្ញុំសូមអានជាភាសាអង់គ្លេស។ ខ្ញុំលើកពីបញ្ហា បទប្បញ្ញត្តិនេះលើកបញ្ហាចោទថា តើការបង្កើតអង្គជំនុំជម្រះទី២ នៃអង្គជំនុំជម្រះសាលា និងតម្រូវឲ្យមានការពិសោធនកម្មទៅលើកិច្ចព្រមព្រៀងដែរឬទេ?

នៅក្នុងកថាខណ្ឌបន្ទាប់មកទៀត លោកសរសេរថា “ចំណុចនេះគឺបានចែងនៅក្នុងមាត្រា៣(៨) នៃកិច្ចព្រមព្រៀង គឺចែងថា ប្រធាននៃអង្គជំនុំជម្រះទៅតាមករណីនីមួយៗអាចចាត់តាំងពីបញ្ជីតែងតាំងដោយអគ្គលេខាធិការ គឺអាចចាត់តាំងចៅក្រមណាមួយឲ្យមានវត្តមាននៅក្នុងដំណាក់កាលនីតិវិធី ឬក៏ឲ្យជំនួសចៅក្រមអន្តរជាតិ ដើម្បីឲ្យដំណើរការជំនុំជម្រះអាចបន្តទៅមុខបាន។ ហើយក៏អាចបង្កើតអង្គជំនុំជម្រះទី២ នៃអង្គជំនុំជម្រះសាលាដំបូងផងដែរ”។

ដូច្នេះ ខ្ញុំចង់ដឹងថា តើការវិភាគគតិយុត្តនេះ តើវាជាផ្នែកមួយនៃការពិនិត្យរបស់លោកដែរឬទេ? ហើយខ្ញុំចង់ដឹងថា តើលោកអាចប្រាប់បានទេថា តើអ្នកណាជាម្ចាស់នៃមតិច្បាប់ដែលលោកយោងទៅនេះ? ពីព្រោះថាក្នុងឯកសាររបស់លោក លោកបានលើកឡើងអំពីទស្សនៈច្បាប់ដែលត្រូវបានបង្ហាញជូន។ សូមអរគុណ។

[០៩:២៩:៥៣]

**លោក ឃ្លុត វ៉ូសាន់ហោក៖**

សូមអរគុណច្រើន។ ខ្ញុំសូមបញ្ជាក់បំភ្លឺចំពោះការឆ្លើយឆ្លងរវាងអង្គជំនុំជម្រះតុលាការកំពូល និងការិយាល័យរដ្ឋបាល គឺមានអនុស្សរណៈចំនួនពីរ។ អនុស្សរណៈនេះ គឺកំពុងតែត្រូវបានដកស្រង់ ដែលក្នុងនោះគឺស្នើសុំឲ្យមានការបញ្ជាក់បំភ្លឺលើការបង្គាប់ឲ្យយកជម្រើសណាមួយដែលអាចធ្វើទៅបាន។ នៅក្នុងអនុស្សរណៈការិយាល័យរដ្ឋបាលសុំឲ្យតុលាការកំពូលបញ្ជាក់បំភ្លឺថា តើមានភាពចាំបាច់ត្រូវធ្វើការវិសោធនកម្មកិច្ចព្រមព្រៀងដែរឬទេ ប្រសិនតាមការយល់របស់ខ្ញុំនោះ ប្រសិនបើគេសុំឲ្យយើងពិនិត្យមើលគឺយើងត្រូវតែសួរទៅកាន់ភាគីនៃកិច្ចព្រមព្រៀងចំពោះករណីហ្នឹង។ នេះជាគោលបំណងនៃអនុស្សរណៈនេះ។ ហើយគឺមិនមានការផ្តល់យោបល់ ត្រឡប់មកវិញពីតុលាការកំពូលលើបញ្ហានោះទេ។ ហើយចំពោះសេចក្តីសម្រេចលើដីកា បំបែកកិច្ចដំណើរការនីតិវិធីរបស់តុលាការកំពូលនៅក្នុងនោះបានសរសេរបញ្ជាក់យ៉ាងច្បាស់ ហើយជម្រើសដែលខ្ញុំបានលើកឡើងអម្បាញ់មិញនេះ គឺគេមិនថាត្រូវធ្វើការវិសោធនកម្មនោះទេ ដូច្នេះគេទុកឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន។ ហើយគឺយើងមិនបាន និយាយឲ្យរួមទៅយើងមិនមានការលើកឡើងអំពីបញ្ហាអង្គច្បាប់អំពីការបង្កើតអង្គជំនុំជម្រះទីពីរនេះទេ។ ហើយចំពោះអ្វីដែលខ្ញុំលើកឡើងគឺថា យើងមិនគិតថាមិនមានបញ្ហាថវិកា ឬបច្ចេកទេសនោះទេ។ ហើយវាក៏គ្មានឧបសគ្គពីការិយាល័យរដ្ឋបាលក្នុងការបន្តគាំទ្រអង្គជំនុំជម្រះទីពីរ ឬក៏អង្គជំនុំជម្រះបច្ចុប្បន្ននេះនោះទេ ឬក៏យើងមិនគិតថាមិនមានឧបសគ្គបច្ចេកទេស ឬរដ្ឋបាលអ្វីឡើយប្រសិនបើយើងដើរទៅតាមផ្លូវផ្សេងទៀតនោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំចង់ឲ្យយល់ច្បាស់ពីចំណុចនេះ។ នៅពេលដែលលោកយោងទៅអនុស្សរណៈទី១ ខ្ញុំសូមលើកឡើងគឺថាលើកឡើងអំពីមតិយោបល់ច្បាប់។ ដូច្នេះមតិយោបល់ច្បាប់នេះគឺអង្គជំនុំជម្រះតុលាការកំពូលបានផ្អែកទៅលើ ដែលបង្ហាញថាមិនមានឧបសគ្គច្បាប់ទេក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២។ ដូច្នេះ

អនុស្សរណៈនេះគឺជាប្រភពសំខាន់មួយរបស់យើង។ ហើយខ្ញុំនៅតែមិនយល់ ថាតើដូចជាទស្សនៈយោបល់ផ្ទាល់របស់លោកដែលផ្អែកទៅលើការវិភាគច្បាប់ជាក់លាក់ និងជាយថាហេតុនិងជាមតិយោបល់របស់តតីយជន? ដូច្នេះយើងមិនដឹងច្បាស់ទេថាតើជាយោបល់របស់អ្នកណា។ សូមឱ្យលោកបញ្ជាក់ឱ្យបានច្បាស់ជាងនេះបន្តិច។

[០៩:៣៣:០៦]

**លោក ឃ្លុត វ៉ូសាន់ហោក៖**

អនុស្សរណៈនេះចុះហត្ថលេខាដោយខ្ញុំ។ ដូច្នេះ ខ្ញុំទទួលខុសត្រូវលើខ្លឹមសារនៅក្នុងអនុស្សរណៈនេះ។ សូមអរគុណ។

**ប្រធានអង្គប្រជុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

លោកអនុប្រធានរដ្ឋបាល លោកមិនបានឆ្លើយតបទៅនឹងសំណួររបស់យើងខ្ញុំ។ ខ្ញុំដឹងថាអនុស្សរណៈនេះលោកជាអ្នកធ្វើឡើង។ ចៅក្រមឡាវែន៍ ចង់សួរបញ្ជាក់ថា តើជាមតិយោបល់របស់អ្នកណាគេនៅក្នុងអនុស្សរណៈនេះ? លោកក៏មានសមត្ថកិច្ចអាចឆ្លើយតបទៅនឹងបញ្ហាផ្លូវច្បាប់ផងដែរ។ ក៏ប៉ុន្តែតើលោកជាអ្នកធ្វើការវិភាគវាយតម្លៃទៅលើមាត្រា៣(៨) នៃកិច្ចព្រមព្រៀង ឬក៏លោកបានពិគ្រោះយោបល់ជាមួយគេបន្ទាប់មកទើបលើកយោបល់នេះ។ ចំណុចនេះវាមានសារៈសំខាន់ណាស់នៅពេលដែលយើងត្រូវការសម្រេច ឬក៏ប្រធានត្រូវការសម្រេច ជាពិសេសដោយយើងយល់អំពីបញ្ហាផ្លូវច្បាប់ក្នុងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២។

ចំណុចទី២ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូង ឬក៏ប្រធាននៃអង្គជំនុំជម្រះសាលាដំបូងនឹងត្រូវតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២ ហើយចាប់ផ្តើមការងារនាពេលនេះ លោកបានបញ្ជាក់រួមជាមួយឯកឧត្តមប្រធានរដ្ឋបាលស្តីទីបានបញ្ជាក់ថា លោកមានថវិកាគ្រប់គ្រាន់ ក្នុងការគាំទ្រអង្គជំនុំជម្រះក្រុមប្រឹក្សាទី២ និងបុគ្គលិកគាំទ្រ។ តើអ៊ីចឹងដែរឬទេ?

**លោក ឃ្លុត វ៉ូសាន់ហោក៖**

អនុស្សរណៈនេះគឺថាចុះហត្ថលេខាដោយខ្ញុំ ហើយខ្ញុំជាអ្នកទទួលខុសត្រូវ។ ខ្ញុំបានប្រឹក្សាជាមួយនឹងអង្គការសហប្រជាជាតិ ក៏ប៉ុន្តែមិនមែនមានន័យថា អនុស្សរណៈនោះអង្គការសហប្រជាជាតិជាអ្នក

សរសេរនោះទេ ខ្ញុំជាអ្នកសរសេរនិងរៀបចំឡើង។ ចំណុចទី២ គឺយើងត្រៀមខ្លួនរួចជាស្រេចក្នុងការគាំទ្រអង្គជំនុំជម្រះ។ ទោះបីជាអង្គជំនុំជម្រះសាលាដំបូងថាត្រូវការចៅក្រមថ្មីបន្ថែម ឬក៏បុគ្គលិកគាំទ្រថ្មីបន្ថែម ក៏យើងត្រៀមខ្លួនគាំទ្ររួចជាស្រេចជាផងដែរ។

[០៩:៣៥:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណៗណាស់នូវសំណួរចម្លើយបំភ្លឺសំណួរទី១នេះ។ បាទ ចូលទៅសំណួរទី២ ប្រសិនបើយើងខ្ញុំជាប្រធានអង្គជំនុំជម្រះសាលាដំបូងមានសមត្ថកិច្ចចាត់តាំងចៅក្រមបម្រុងដូចមានចែងនៅក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងច្បាប់ស្តីពីការបង្កើតច្បាប់ - - ច្បាប់នៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា តើចៅក្រមរូបណាខ្លះក្រៅពីចៅក្រមនៅក្នុងអង្គជំនុំជម្រះសាលាដំបូងបច្ចុប្បន្នដែលអាចឲ្យខ្ញុំធ្វើការចាត់តាំងអ្នកទាំងនោះឲ្យទទួលបន្ទុកជំនុំជម្រះសំណុំរឿង០០២/០២បាន ក្នុងករណីដែលក្រុមប្រឹក្សាជំនុំជម្រះទី២ ចាំបាច់ត្រូវបង្កើតឡើងនោះ?

បទប្បញ្ញត្តិកថាខណ្ឌ៤ នៃមាត្រា១១ថ្មី ច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានផ្តល់ឲ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមានសិទ្ធិអំណាចផ្តាច់មុខ ក្នុងការតែងតាំងចៅក្រមបម្រុងកម្ពុជាមួយចំនួនតាមតម្រូវការ ហើយប្រធានអង្គជំនុំជម្រះនីមួយៗអាចចាត់តាំងចៅក្រមបម្រុងមួយរូបឬច្រើនរូប ដែលត្រូវបានតែងតាំងរួចហើយដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ តើមានចៅក្រមបម្រុងបរទេស និងចៅក្រមបម្រុងខ្មែរប៉ុន្មានរូបនាពេលបច្ចុប្បន្ននេះ ដែលត្រូវបានតែងតាំងរួចហើយដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីជំនុំជម្រះនៅក្នុងអង្គជំនុំជម្រះសាលាដំបូង?

[០៩:៣៧:១៨]

ប្រសិនបើចៅក្រមដែលបានតែងតាំងរួចហើយនេះ មិនគ្រប់គ្រាន់ តើត្រូវចំណាយរយៈពេលប៉ុន្មានដើម្បីបញ្ចប់កិច្ចដំណើរការនីតិវិធីនៃការជ្រើសរើស និងតែងតាំងចៅក្រមថ្មីដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម? តើឯកឧត្តមប្រធាន និងលោកអនុប្រធានបានដឹងដែរឬទេ? តើអង្គលេខាធិការរបស់អង្គការសហប្រជាជាតិបានជ្រើសរើសចៅក្រមបរទេសដែលមានដាក់ឈ្មោះពាក្យសុំរួចហើយឬនៅ? ហើយតើបញ្ជីឈ្មោះអ្នកដែលត្រូវជ្រើសរើសទាំងនោះត្រូវបានបញ្ជូនមកអាជ្ញាធរកម្ពុជាជាផ្លូវការរួចហើយឬនៅ? សូមឆ្លើយបំភ្លឺ។

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ ជាថ្មីម្តងទៀតបើសិន--

**ប្រធានអង្គជំនុំ៖**

អត់ទោស សូមទោសឯកឧត្តម សូមអញ្ជើញ!

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ ជាថ្មីម្តងទៀត--

**លោក គង់ សំអុន៖**

សូមអរគុណ--

**ប្រធានអង្គជំនុំ៖**

សូមទោសឯកឧត្តមមានបញ្ហាបន្តិច ផ្អាកបន្តិចសិនបាទ។ សូមអញ្ជើញលោកមេធាវី!

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមគោរពអង្គប្រជុំ សូមគោរពលោកប្រធាន។ ដោយបញ្ហាថាចំណុចទី១ មិនទាន់អាចដោះស្រាយបានស្រួល តើលោកប្រធានអនុញ្ញាតឲ្យភាគីសួរទៅឯកឧត្តមខាងប្រធានរដ្ឋបាលសិនមុននឹងចូលទៅចំណុចទី២ ឬមួយយ៉ាងណាបាទ? សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ អង្គជំនុំជម្រះនឹងផ្តល់ឱកាសជូនទៅភាគីពាក់ព័ន្ធ ដើម្បីសាកសួរបន្ថែម។ ប៉ុន្តែមិនមែនតែមួយហ្នឹងទេ ចាំចប់បញ្ហានេះ ប្រធានរបៀបវារៈទី១នេះ គឺអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនហើយ។ សូមកុំបារម្ភអីបាទ។ សូមអញ្ជើញឯកឧត្តម!

[០៩:៣៨:៥៨]

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ សូមអរគុណលោកប្រធាន។ ចំពោះសំណួរនេះ ក្នុងរចនាសម្ព័ន្ធបច្ចុប្បន្ននៅ អ.វ.ត.ក យើងមានចៅក្រមបម្រុងប្រាំនាក់ខាងភាគីកម្ពុជា មានទាំងចៅក្រមបម្រុង ដែលមានសម្រាប់នៅក្នុងសាលាដំបូងបច្ចុប្បន្ននេះ ហើយនិងយើងមានចៅក្រមបម្រុងបួននាក់នៅខាងភាគីអន្តរជាតិដែលត្រូវបានតែងតាំងហើយ ដែលសាលាដំបូងមាននៅក្នុងដៃស្រាប់។ បើសិនជាលោកប្រធានយល់ឃើញថាត្រូវការចៅក្រមបម្រុងថ្មីក្រៅពីនេះ នោះលោកប្រធាននឹងធ្វើការចាត់តាំងទៅ ការសំណើសុំទៅតាមបែបបទជា

ធរមានទៅ រដ្ឋបាលនឹងចាត់ចែងតាមវិធានការ។

ចំពោះពេលវេលាប៉ុន្មាននោះ ខ្ញុំបាទយល់ឃើញថា វាមិន -- ជាទូទៅ អ.វ.ត.ក យើងបានតែងតាំងចៅក្រមជាតិ អន្តរជាតិមួយចំនួនហើយ។ ជាទូទៅទំនាក់ទំនងជាមួយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមដូចជាមិនសូវស៊ីពេលប៉ុន្មានទេបាទ។ យ៉ាងយូរមួយខែ អានេះតាមទម្លាប់ដែលធ្លាប់បានធ្វើកន្លងមកបាទ។ នេះជាចម្លើយបាទ។

**ប្រធានអង្គជំនុំ៖**

លោកអនុប្រធានមានមតិយោបល់អីឆ្លើយបញ្ជាក់បន្ថែមដែរឬទេលើសំណួរនេះ?

**លោក ឃុត វ៉ូសាន់ហោក៖**

ខ្ញុំគាំទ្រទៅលើអ្វីដែលបាននិយាយ ក៏ដូចជាការលម្អិត ដែលអង្គការសហប្រជាជាតិបានបញ្ជាក់ ហើយអគ្គលេខាអង្គការសហប្រជាជាតិបានបញ្ជូននូវបញ្ជីចៅក្រមដែលអាចចាត់តាំងបាន។ ប៉ុន្តែខាងអន្តរជាតិមិនមានអ្វីដើម្បីអនុវត្តទេ ព្រោះមិនមានសំណើសុំទៅខាងអង្គការសហប្រជាជាតិដើម្បីឲ្យចាត់តាំងចៅក្រមនៅឡើយនោះទេ។

[០៩:៤១:១២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរសួរបន្តដើម្បីឲ្យយើងច្បាស់ថាយើងយល់ទាំងអស់គ្នា។ ខ្ញុំទើបតែស្តាប់ឮថានឹងមានចៅក្រមបម្រុងប្រាំនាក់ដែលនឹងត្រូវចាត់តាំងសម្រាប់ផ្នែកកម្ពុជា គឺថាមានចៅក្រមបម្រុងកម្ពុជាប្រាំនាក់នឹងត្រូវចាត់តាំង ហើយប្រសិនបើខ្ញុំស្តាប់មិនច្រឡំ គឺមានចៅក្រមបម្រុងអន្តរជាតិបួនរូបទៀតដែលនឹងត្រូវចាត់តាំងផងដែរ។ ដូច្នេះ តើមានន័យថាម៉េចដែលលោកប្រើពាក្យថា “នឹងត្រូវចាត់តាំង”នេះ តើជាការចាត់តាំងដោយព្រះរាជក្រឹត្យបន្ទាប់ពីមានការពិគ្រោះយោបល់ពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយតើព្រះរាជក្រឹត្យនេះចាត់តាំងចៅក្រមបម្រុងសម្រាប់អង្គជំនុំជម្រះជាក់លាក់ណាមួយ ឬក៏យ៉ាងម៉េច? ពីព្រោះខ្ញុំស្តាប់ ខ្ញុំយល់ថារហូតមកដល់ពេលនេះ គឺថាឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមជាអ្នកចាត់តាំងចៅក្រមសម្រាប់អង្គជំនុំជម្រះនីមួយៗ។ ដូច្នេះ តើចៅក្រមបម្រុងទាំងប្រាំនាក់ គឺសម្រាប់តែសាលាដំបូង ឬក៏មានចាត់តាំងសម្រាប់អង្គជំនុំជម្រះតុលាការផ្សេងៗ

ទៀត?

ពាក់ព័ន្ធទៅនឹងចៅក្រមបម្រុងបួនរូបអន្តរជាតិ ខ្ញុំយល់ថានៅអង្គការសហប្រជាជាតិនោះ យើងមានបញ្ជីបក្ខជនចៅក្រម។ ក៏ប៉ុន្តែរហូតមកដល់ពេលនេះ យើងមិនមានការបញ្ជូនពីអគ្គលេខាធិការអង្គការសហប្រជាជាតិនូវបញ្ជីផ្លូវការនៃឈ្មោះបេក្ខជនដែលតាមរយៈនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមអាចចាត់តាំងចៅក្រមបម្រុងអន្តរជាតិបន្ថែមបាននៅឡើយទេ។ ប្រហែលជាអាចខ្ញុំយល់ប្រឡំ ឬក៏យ៉ាងម៉េច? ប្រសិនបើអ៊ីចឹងមែន ប្រសិនបើបញ្ជីនេះមិនទាន់បានបញ្ជូនទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទេ ខ្ញុំចង់ដឹងថាបើតាមអស់លោកនោះថា តើត្រូវការពេលវេលាប៉ុន្មានដើម្បីពិនិត្យមើល ផ្ទៀងផ្ទាត់មើលថាតើមានចៅក្រមបម្រុងយ៉ាងម៉េច ហើយមានពេលទំនេរបែបណាដែលអាចមកធ្វើការបាន ហើយដើម្បីអាចឱ្យយល់អំពីដំណើរការនៃការចាត់តាំងរបស់ចៅក្រមទាំងអស់នេះនោះ។ ខ្ញុំគិតថា សំណួរខ្ញុំគឺច្បាស់លាស់ហើយ។ ដោយយើងមិនគិតអំពីបញ្ហា ពីសំណួរផ្សេងទៀតពាក់ព័ន្ធទៅនឹងការចាត់តាំងបុគ្គលិកគាំទ្របន្ថែម ដែលមានភាពចាំបាច់ផងដែរសម្រាប់ជួយដល់ក្រុមប្រឹក្សាជំនុំជម្រះទី២នោះ។

[០៩:៤៤:១៥]

**ឯកឧត្តម ក្រាញ់ តូនី៖**

សូមអរគុណលោកចៅក្រម ឡាវ៉ែន៍។ ប្រហែលជាមានបញ្ហាការបកប្រែ។ ខ្ញុំបានចាប់ផ្តើមចម្លើយរបស់ខ្ញុំថា ក្នុងពេលបច្ចុប្បន្ននេះ ក្នុងអ.វ.ត.ក ចៅក្រមបម្រុងដែលយើងមានស្រាប់ក្នុងដៃ គឺមានចំនួនប្រាំ រាប់ទាំងខាងចៅក្រមបម្រុង ខាងព្រះរាជអាជ្ញាផង និងចៅក្រមបម្រុងរបស់សាលាដំបូងផង។ ប្រាំដែលមានបច្ចុប្បន្ន ហើយបើសិនជាលោកចៅក្រមចង់បានចៅក្រមបម្រុងថ្មី ក្រៅពីអ្វីដែលមាននៅក្នុងដៃស្រាប់គឺធ្វើសំណើទៅឧត្តមទៅ យើងខ្ញុំនឹងគាំទ្រតាមនីតិវិធីដែលជាធរមាន ហើយពេលវេលារឿងចាត់តាំងចៅក្រមថ្មីចាស់ យោងទៅតាមបទពិសោធន៍កន្លងមក គឺវាចំណាយពេលមិនយូរជាងមួយខែទេបាទ។ វាជាអ្វីដែលបទពិសោធន៍ធ្លាប់អនុវត្តកន្លងមក។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សុងម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

ដូច្នេះ ខ្ញុំយល់ថានៅពេលដែលលោកនិយាយយោងទៅដល់ចៅក្រមបម្រុងប្រាំនាក់នោះ គឺជាចៅក្រមបម្រុងដែលមាននៅក្នុងអង្គជំនុំជម្រះ គឺដូចជានៅទីនេះអ៊ីចឹង គឺយើងមានចៅក្រម ធូ មណី

ដែលជាចៅក្រមបម្រុង ហើយដូច្នេះ ខ្ញុំចង់ដឹងថាតើមានចៅក្រមបម្រុងផ្សេងទៀតដែលនឹងត្រូវចាត់តាំង ឬក៏យ៉ាងម៉េច ឬមួយក៏យើងត្រូវធ្វើតាមរយៈដំណើរការនៃការតែងតាំងចៅក្រមដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង?

[០៩:៤៦:០៩]

**ឯកឧត្តម ក្រាញ់ តូនី៖**

ខ្ញុំអត់មាននិយាយ -- ខ្ញុំអត់មានចង់និយាយអំពីសិទ្ធិចាត់តាំង មិនចាត់តាំង ឬក៏ស្នើសុំឱ្យមានថ្មីយ៉ាងម៉េចទេ។ អានេះជាសិទ្ធិផ្តាច់មុខរបស់សាលាដំបូង អ្វីដែលខ្ញុំរៀបរាប់ហ្នឹង គឺចំនួនដែលយើងមាននៅក្នុងដៃសព្វថ្ងៃនេះ មានលោក ធូ មណី នៅក្នុងសាលាដំបូងបច្ចុប្បន្ន នៅខាងអ្វីដែលយើងហៅថា ភី.ធី.ស៊ី ដែលយើងរាប់ទៅវាមានចៅក្រមបម្រុងដែលមានស្រាប់នៅក្នុងដៃបច្ចុប្បន្ននៅក្នុង អ.វ.ត.ក បាទ។ រីឯសិទ្ធិតែងតាំង សិទ្ធិស្នើសុំឱ្យមានថ្មី ឬយ៉ាងណាមិញនេះ ជាសិទ្ធិផ្តាច់មុខរបស់ -- ម្តងទៀតរបស់សាលាដំបូង។ ខ្ញុំគ្រាន់ជម្រាបជូនថា យើងមានប្រាំនៅក្នុងដៃ បើរាប់ទាំងអស់ បើសិនជាត្រូវការថែមរើសថ្មី យើង -- លោកប្រធាន ឬសាលាដំបូងធ្វើលិខិតស្នើសុំទៅឧត្តម យើងនឹងសម្របសម្រួលតាមនីតិវិធីច្បាប់ជាធរមានដូចតាមទម្លាប់។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសោកស្តាយ ខ្ញុំនៅតែមិនយល់ច្បាស់ ក្រៅពីចៅក្រម ធូ មណី ដែលជាចៅក្រមបម្រុងនៅទីនេះ ហើយដែលត្រូវបានតែងតាំង ដើម្បីកាន់មុខងារនៅក្នុងអង្គជំនុំជម្រះសាលាដំបូង។ តើរហូតមកដល់ថ្ងៃនេះ មានចៅក្រមបម្រុងផ្សេងទៀត ដែលត្រូវបានតែងតាំងរួចមកហើយសម្រាប់នៅអង្គជំនុំជម្រះសាលាដំបូងនេះ? លោកបានឆ្លើយថា មានចៅក្រមប្រាំរូបបម្រុងដែលអាចនៅទំនេរ អាចធ្វើការបាន។ ដូច្នេះ ខ្ញុំចង់ដឹងថា ពួកគាត់ទាំងប្រាំហ្នឹងជាអ្នកណា? ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនយល់ចម្លើយរបស់លោកទេ។

[០៩:៤៨:១៨]

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ ខ្ញុំសូម -- ធី.ស៊ី និយាយឱ្យសាមញ្ញទៅ និយាយរត់មាត់ទៅ ធី.ស៊ី មានមួយ, ភី.ធី.ស៊ី មានមួយខាងជាតិ, ខាងតុលាការកំពូលមានមួយ, ខាងអូ.ស៊ី.អាយ.ជេ មានមួយ, ខាង អូ.ស៊ី.ភី មានមួយ។

មានប្រាំដែលមានស្រាប់ដែលត្រូវបានតែងតាំងជា *បម្រុង* រួចហើយលោកចៅក្រម ឡាវែន។

**លោក ឃ្លុត រ៉ូសាន់ហោក៖**

បាទ ខ្ញុំសូមបន្ថែមបន្តិចទៀត គឺថាចំនួនដែលយើងនិយាយនេះ គឺត្រូវបានតែងតាំងរួចទៅហើយទៅតាមអង្គជំនុំជម្រះមួយៗ។ ដូច្នេះហើយ គឺមិនមានបញ្ជីបន្ថែមនៃចៅក្រម ដែលត្រូវតែងតាំងដែលត្រូវបែងចែកការងារទៅតាមអង្គជំនុំជម្រះថ្មីនៅឡើយ។ ប្រសិនបើ -- ខ្ញុំសង្ឃឹមថា ខ្ញុំអាចឆ្លើយទៅនឹងចម្លើយរបស់លោកចៅក្រម ហើយខ្ញុំគិតថាប្រហែលជាមានសំណួរបន្ថែមទៀតទាក់ទងទៅនឹងការលាឈប់ ឬក៏ការតែងតាំងថ្មីពីខាងអង្គការសហប្រជាជាតិ គឺថា ជាការពិតទៅខ្ញុំបានបញ្ជាក់ថា ខាងជាតិគឺជាបញ្ហាសំខាន់ដែលយើងត្រូវស្នើ ហើយបន្ទាប់មកទៀតយើងនឹងធ្វើការទាក់ទងទៅនឹងបុគ្គលនីមួយៗនៅក្នុងបញ្ជី ហើយយើងនឹងធ្វើការជ្រើសរើស ហើយប្រហែលជាចំណាយពេលពីរបីថ្ងៃ ឬក៏សប្តាហ៍អាចថា ដើរយ៉ាងយូរបំផុតមួយខែ។

អ្វីដែលយើងចង់បញ្ជាក់នៅពេលនេះ គឺថាខាងអង្គការសហប្រជាជាតិ និងជួយសម្រួលឲ្យបានឆាប់រហ័សបំផុតក្នុងការតែងតាំងពីការអន្តរជាតិ។

[០៩:៥០:១០]

**ប្រធានអង្គជំនុំ៖**

បាទ សូមអរគុណ។

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាត់វ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណ លោកប្រធាន។

ខ្ញុំគិតថា យើងយល់ច្បាស់ហើយ ទាក់ទងទៅនឹងចៅក្រមបម្រុងទាំងប្រាំរូប។ ក៏ប៉ុន្តែខ្ញុំមានសំណួរមួយទៀត ពាក់ព័ន្ធទៅនឹងយុត្តាធិការរបស់លោកប្រធាន នៅក្នុងការប្រើប្រាស់ ឬក៏ក្នុងការតែងតាំងចៅក្រមបម្រុងទាំងប្រាំរូប ដែលមិនមែនជាចៅក្រមរបស់សាលាដំបូងនោះ។ ដើម្បីតែងតាំងដើម្បីបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ ថាតើលោកអាចពន្យល់បន្ថែមបានដែរឬទេ? ថាតើលោកប្រធានមានយុត្តាធិការក្នុងការអនុវត្តការងារបែបនេះដែរឬទេ?

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ ខ្ញុំយល់ឃើញថា តាមការពិតកាតព្វកិច្ច និងសមត្ថកិច្ចរបស់ខ្ញុំគឺរដ្ឋបាល ហើយនិង

ហិរញ្ញវត្ថុ។ សមត្ថកិច្ចរបស់ចៅក្រមគឺផ្នែកច្បាប់។ អ៊ីចឹងយុត្តាធិការ ខ្ញុំសូមបញ្ជាក់ហើយ គឺសិទ្ធិផ្តាច់មុខរបស់ចៅក្រមទាំងអស់បាទ។ អ៊ីចឹង ប៉ុន្តែបើចៅក្រមសួរខ្ញុំ ខ្ញុំថានៅក្នុងថាមានប្រាំនាក់។ ខ្ញុំគ្រាន់តែរាប់ថា មួយ ពីរ បី បួន ប្រាំ។ បើសិនជាលោកចៅក្រម អ្នកស្រីចៅក្រម យល់ឃើញថាប្រាំនាក់ហ្នឹងមានបញ្ហាយុត្តាធិការ បញ្ហា ...។ល។ អាហ្នឹង ជាសិទ្ធិផ្តាច់មុខរបស់លោកចៅក្រម ខ្ញុំអត់មានវាយតម្លៃថាបុគ្គលទាំងអស់នោះ *រេប៉ែរ្យូរ* ទាំងអស់នោះ ត្រូវអាចមានធ្វើបានទេ អាហ្នឹងជា ខ្ញុំឃើញថា *រេប៉ែរ្យូរ* នៃរបស់ -- និយមន័យចៅក្រមបម្រុង គឺគាត់នឹងចូលមកធ្វើការនៅពេលណាដែលត្រូវការ ពេលណាដែលមានការចាត់តាំង។ អ៊ីចឹងខ្ញុំយល់ឃើញជា ដោយសារហ្នឹងសំណួរ ទើបខ្ញុំឆ្លើយយ៉ាងហ្នឹង។ ប៉ុន្តែអ្វីដែលថាគាត់ធ្វើបាន មិនបាន មានបញ្ហាច្បាប់អីហ្នឹង អាហ្នឹងជា មិនមែនជាការវាយតម្លៃរបស់ខ្ញុំទេបាទ។

[០៩:៥២:២០]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

តើលោកអនុប្រធាន លោកចង់ពន្យល់បន្ថែម ឬមួយក៏លោកចង់ឆ្លើយឲ្យបញ្ជាក់លម្អិតបន្ថែមទៅលើសំណួរខ្ញុំដែរឬទេ?

**លោក ឃ្យូត រ៉ូសាន់ហោក៖**

ខ្ញុំយល់ឃើញថា លោកប្រធានអង្គជំនុំជម្រះមានយុត្តាធិការបែបនេះ។ ប៉ុន្តែប្រសិនបើគាត់គិតថាមិនមានយុត្តាធិការបែបនេះទេ យើងនឹងព្យាយាមស្វែងរកការបកស្រាយពីខាងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីឲ្យឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ធ្វើការឆ្លើយ ឬក៏បកស្រាយទៅលើសំណួរនេះ។

សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ រហូតមកដល់ពេលនេះ យើងបាននិយាយច្រើនមកហើយ អំពីការចាត់តាំងចៅក្រមថ្មី។ ក៏ប៉ុន្តែយើងនិយាយតិចតួចអំពីបញ្ហាបុគ្គលិកគាំទ្រ ដែលមានភាពចាំបាច់ក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២។ លោកប្រធាន បានផ្តល់សេចក្តីចង្អុលបង្ហាញ ហើយនិងទូរលេខច្បាស់លាស់រួចមកហើយ។ ពាក់ព័ន្ធទៅនឹងបុគ្គលិកដែលត្រូវការចាំបាច់សម្រាប់ដំណើរការនោះ។ ដូច្នេះខ្ញុំចង់សួរថា តើនេះជាបញ្ហាដែលពាក់ព័ន្ធទៅនឹងការពិនិត្យរបស់អស់លោកដែរឬទេ? តើអស់លោកអាច

បញ្ជាក់បានទេ ថាភាពឆាប់រហ័សនៃការចាត់តាំង នៃការតែងតាំង ឬក៏ចាត់តាំងបុគ្គលិកគាំទ្រនេះ តើត្រូវការពេលប៉ុន្មានដែរ?

[០៩:៥៤:០១]

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ ក្នុងការធ្វើការពង្រាងថវិកាឆ្នាំ២០១៤-១៥ យើងបានតែងតែបានគិតគូរនៅក្នុងកញ្ចប់ថវិកាមួយ ដែលយើងហៅថា ថវិកាដែលមិនមែនសម្រាប់លក្ខណៈចៃដន្យមួយចំនួន។ អ៊ីចឹង បើខ្ញុំយល់ឃើញថា សាលាដំបូងធ្វើជម្រើសដើរទៅលើផ្លូវយកសភាទី២នោះ យើង ចំពោះចំនួនបុគ្គលិកដែលលោកចៅក្រមទាមទារ ប្រាំ ឬប្រាំមួយ ឬបី ឬពីរ ខ្ញុំមិនដឹងថាបច្ចុប្បន្ននេះ យើងអាចកំណត់ថាចំនួនជាក់លាក់បានហើយឬនៅ បើយើងមិនទាន់បានសម្រេចថាមានផង ហើយយើងមិនទាន់សម្រេចក្នុងការធ្វើការវិភាគផែនការសកម្មភាព។ ប៉ុន្តែជាគោលការណ៍ យើងមានភាពទន់ភ្លន់ និងអាចបត់បែនបានទៅតាមគម្រោងថវិកាដែលបានធ្វើ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំយល់ហើយថា បញ្ហាហិរញ្ញវត្ថុនេះជាបញ្ហាសំខាន់បំផុតដែលថា មិនមែនពាក់ព័ន្ធនឹងចៅក្រម។ ក៏ប៉ុន្តែខ្ញុំហាក់ដូចជាស្តាប់ឮថា មានបញ្ហាក្នុងការបង្កកការតែងតាំងបុគ្គលិក។ តើចំណុចនេះត្រូវបានដកចេញរួចទៅហើយ ឬនៅតែមានទេបញ្ហាបង្កកការតែងតាំង ឬក៏ចាត់តាំងបុគ្គលិកនោះ?

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ អ្វីដែលយើងបានធ្វើ និងកំពុងធ្វើហ្នឹងគឺមានធ្វើអ្វីឱ្យរដ្ឋបាលមួយមានសុពលភាពជាមុន។ ការបង្កកបុគ្គលិកមិនមានន័យថា មាន -- ជាអង្គភាពទូទៅមានការចេញ មានការចូល មានបុគ្គលិកមានការធ្វើឱ្យតូចជាមុន មានប្រសិទ្ធភាពជាងមុន មិនមែនថាត្រូវតែបង្កកជារឹងកំព្រឹសទេបាទ ប៉ុន្តែអ្វីដែលយើងដាក់ឧត្តមភាពខ្ពស់ជាងគេនោះលើ អ.វ.ត.ក គឺសាលាដំបូងនេះហើយបាទ។ អ៊ីចឹង នេះមិនមាន មិនមានភាពប៉ះពាល់អីទៅដល់លើការងារ ដែលយើងកំពុងសម្រេចនោះទេបាទ។

[០៩:៥៦:៣៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀល ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណ ហើយជាការល្អដែលយើងបានស្តាប់ឮខាងរដ្ឋបាលបានបញ្ជាក់ថា មានថវិកាសង្គ្រោះបន្ទាន់ ដែលក្នុងករណីនេះគឺខាងរដ្ឋបាលអាចជួយដល់ការជ្រើសរើសបុគ្គលិកថ្មីសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះថ្មី។ នៅក្នុងឯកសារ A/68/532 ដែលគេស្គាល់ថា ជាសំណើសុំអន្តរាគមន៍ នៅត្រង់កថាខណ្ឌ២០ ឯកសារបាននិយាយថា "ដោយរង់ចាំការសម្រេចថ្មីរបស់ខាងតុលាការកំពូល ដែលជាការនិយាយយោងទៅលើសេចក្តីសម្រេចរបស់តុលាការកំពូល ក្នុងការទាមទារឲ្យមានការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ នៅក្នុងអង្គជំនុំជម្រះសាលាដំបូង – ប៉ុន្តែតាមពិតទៅគឺតុលាការសាលាកំពូលមិនទាន់បានធ្វើនោះទេ – ដោយរង់ចាំការសម្រេចរបស់តុលាការកំពូល ថវិកាសម្រាប់ឆ្នាំ២០១៤ និង ២០១៥ គឺមិនរួមបញ្ចូលនៅក្នុងការគណនាថវិកាសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះទី២ នោះទេ។ ដូច្នេះ ខ្ញុំព្រួយបារម្ភថាតើការរៀបចំថវិកាសង្គ្រោះបន្ទាន់របស់លោកហ្នឹង តើវាអាចគ្របដណ្តប់ ឬក៏អាចជួយចំណាយចំពោះការខ្វះខាតសម្រាប់ឆ្នាំក្រោយដែលយើងនឹងត្រូវមានការគ្រោងបង្កើតថ្មីដែរឬទេ តើលោកចង់បញ្ចេញមតិយោបល់អ្វីដែរឬទេ ទាក់ទងទៅនឹងចំណុចនេះ។

[០៩:៥៨:១៧]

**លោក ឃ្មុត រ៉ូសាន់ហោក៖**

សូមអរគុណលោកស្រីចៅក្រម។ ឯកសារអន្តរាគមន៍ដែលលោកស្រីនិយាយឡើង គឺជាសំណើរបស់ខាងអង្គការសហប្រជាជាតិ មិនមែនជាគម្រោងថវិកានោះទេ។ គឺថាគម្រោងថវិកា យើងមិនបាននិយាយអំពីការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ ព្រោះថាយើងមិនទាន់មានការសម្រេចបែបនេះ។ ប៉ុន្តែផែនការសង្គ្រោះបន្ទាន់ គឺអាស្រ័យទៅឆន្ទានុសិទ្ធិរបស់យើង។ យើងមានក្រុមប្រទេសផ្តល់ជំនួយដែលអាចជួយដល់ការឧបត្ថម្ភថវិកានៅក្នុងហេតុការណ៍ ឬក៏នៅក្នុងព្រឹត្តិការណ៍ដែលយើងមិនអាចប្រមើលមើលបាន។ នៅពេលដែលមានបញ្ហាបែបនេះ គឺយើងនឹងទៅជួបជាមួយប្រទេសផ្តល់ជំនួយទាំងអស់នោះ ដើម្បីបង្ហាញអំពីតម្រូវការជាបន្ទាន់របស់យើង ហើយយើងនឹងអាចស្នើសុំជំនួយបន្ថែមក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២។ ហេតុដូច្នេះហើយទើបយើងមិនដាក់បញ្ចូលទាំងអស់ បញ្ហាទាំងអស់នេះនៅក្នុងផែនការថវិការបស់យើង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយខ្ញុំសូមកត់សម្គាល់ដូច្នេះ សូមឯកឧត្តមប្រធាន ហើយនិងលោកអនុប្រធានជ្រាបថា មូលហេតុដែលអង្គជំនុំជម្រះយកសំណួរនេះមកតាំងសួរ ដោយសារសំអាងហេតុនៃត្រង់កថាខណ្ឌ៧២, ៧៣ ជាពិសេស ៧៤ នៃសេចក្ដីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលបានផ្អែក ដកស្រង់ទាំងស្រុងទៅលើអនុស្សរណៈរបស់រដ្ឋបាលដែលផ្ញើជូនអង្គជំនុំជម្រះតុលាការកំពូល។ គាត់ដកស្រង់ទាំងស្រុងតែម្ដង។ នៅក្នុងនោះគឺបានបញ្ជាក់ច្បាស់ថា ពុំមានឧបសគ្គក្នុងការដែលប្រធានកោះអញ្ជើញចៅក្រមសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះទី២ទេ។ នេះដែលធ្វើឲ្យខ្ញុំឆ្ងល់ និងខ្ញុំមានការព្រួយបារម្ភអំពីការបំពេញមុខងាររបស់ខ្លួននៅទីនេះឲ្យបានត្រឹមត្រូវ ឲ្យបានម៉ត់ចត់ និងមានប្រសិទ្ធភាព។ ដោយឃើញភាពចម្លែកនៃការចង្អុលបង្ហាញដូចនេះ ទើបយើងយកបញ្ហានេះដាច់ខាតត្រូវតែដាក់ពិភាក្សាដេញដោលជជែកគ្នាឲ្យបានច្បាស់លាស់លើដំណោះស្រាយនោះ បើពុំដូច្នោះទេវាជាបន្ទុកធ្ងន់របស់ខ្ញុំដែលខ្ញុំមិនដឹងខ្លួនឯងថាតើខ្ញុំមានគុណសម្បត្តិកម្រិតណា ដែលច្បាប់ឲ្យខ្ញុំអញ្ជើញចៅក្រមបម្រុងទាំងឡាយ ទាំងជាតិ ទាំងអន្តរជាតិនៅក្នុង អ.វ.ត.ក នេះមកបង្កើតដោយឯកឯងនូវក្រុមប្រឹក្សាទី២ សម្រាប់អង្គជំនុំជម្រះសាលាដំបូងនោះ។

[១០:០១:១០]

នៅក្នុងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានចែងច្បាស់អំពីតម្រូវការនៃការចាត់តាំងចៅក្រមជាតិ និងចៅក្រមអន្តរជាតិទាំងពេញសិទ្ធិ ទាំងបម្រុងដោយឆ្លងកាត់តាមឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម គឺចៅក្រមភាគីអន្តរជាតិប្រាំរូប ប្រាំរូបពេញសិទ្ធិហើយនិងពីររូបបម្រុងសម្រាប់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល។ ចំណែកឯភាគីជាតិប្រាំបួនរូប ប្រាំពីររូបពេញសិទ្ធិ ហើយនិង ពីររូបសម្រាប់ចៅក្រមបម្រុង នៅក្នុងអង្គជំនុំជម្រះសាលាដំបូងហើយនិងអង្គជំនុំជម្រះតុលាការកំពូល។ ដូច្នេះ នៅក្នុងកិច្ចព្រមព្រៀងនេះគឺបានកំណត់ច្បាស់លាស់លើក្របខ័ណ្ឌនៃចំនួនបរិមាណចៅក្រមដែលត្រូវបំពេញការងារនៅទីនេះពេញសិទ្ធិ។ ពិតមែនហើយបម្រុងបានបើកទូលាយ បានន័យថានិយាយមានលក្ខណៈមិនដាច់ខាតថាមួយទេ គឺអាចលើសពីមួយ។

បញ្ហាទីពីរ ផ្អែកលើព្រះរាជក្រឹត្យតែងតាំងចៅក្រម ព្រះរាជអាជ្ញានៅក្នុងដំណើរការសម្រាប់សំណុំរឿងក្ដីនៅអ.វ.ត.កនេះ ព្រះរាជក្រឹត្យ ន.ស.រ.ក.ត ០៥០៦២១៤ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ

២០០៦ បានកំណត់បញ្ជីយ៉ាងច្បាស់លាស់ ទី១ ចៅក្រមសាលាដំបូងរួមមានៈ នៅក្នុងនោះគឺចៅក្រមពេញសិទ្ធិប្រាំរូប ចៅក្រមបម្រុងពីររូប ជាតិមួយរូប អន្តរជាតិមួយរូប។ ទី២ ចៅក្រមតុលាការកំពូលប្រាំបួនរូប ប្រាំពីររូបពេញសិទ្ធិ ហើយនិងពីររូបបម្រុង។

សំណួរដែលខ្ញុំចង់សួរនេះគឺសួរថា តាមអ្វីដែលជាសំអាងហេតុរបស់តុលាការកំពូលបានយកដកស្រង់ទាំងស្រុងនូវខ្លឹមសាររបស់អនុស្សរណៈរបស់រដ្ឋបាលយកមកចម្លងចូលនៅក្នុងកថាខណ្ឌ៧៤ ដែលផ្តល់អំណាចមកដោយការទទួលខុសត្រូវក្នុងការបង្កើតក្រុមប្រឹក្សាទី២ ដល់យើងខ្ញុំផ្ទាល់ដែលជាប្រធានអង្គជំនុំជម្រះសាលាដំបូងនេះ។ សំណួរសួរថា តើខ្ញុំមានគុណភាពអាចចាត់តាំងពីចៅក្រមពីអង្គភាពផ្សេងៗមកធ្វើការនៅក្នុងអង្គជំនុំជម្រះសាលាដំបូងដើម្បីក្នុងន័យបង្កើតឲ្យបានក្រុមប្រឹក្សាជំនុំជម្រះ ទី២ ដែរឬទេ? ពីព្រោះនេះគឺជាការសំអាងហេតុដែលយកចេញពីការពន្យល់អំពីផ្លូវច្បាប់របស់រដ្ឋបាលផ្ញើជូនអង្គជំនុំជម្រះតុលាការកំពូលបានជាយើងសួរខាងរដ្ឋបាល។

[១០:០៤:៣៥]

**លោក ឃ្នុត វ៉ូសាន់ហោកៈ**

អនុស្សរណៈនេះចុះហត្ថលេខាដោយខ្ញុំ ដូច្នេះជាយោបល់របស់ខ្ញុំនៅក្នុងហ្នឹង។ ប្រសិនបើប្រធានសាលាដំបូងមិនឯកភាពជាមួយនឹងយោបល់របស់ខ្ញុំនោះទេ គឺខ្ញុំនឹងគោរពតាមការបកស្រាយតាមផ្លូវច្បាប់ណាមួយប្រសិនបើមាននោះ។ សូមអរគុណ។

**ប្រធានអង្គជំនុំៈ**

នៅទីនេះយើងមិនជជែកថា ឯកភាព ឬមិនឯកភាពទេ។ ការរៀបចំដូច្នេះវានាំឲ្យការយល់ឃើញរបស់អង្គជំនុំជម្រះសាលាកំពូលទម្លាក់បេសកកម្មនេះមកខ្ញុំ។ អរគុណតុលាការកំពូលយ៉ាងអនេកបានផ្តល់បេសកកម្មដ៏ឧត្តុង្គឧត្តមដល់ខ្ញុំនៅក្នុងការរៀបចំបង្កើតនូវក្រុមប្រឹក្សាជំនុំជម្រះទី២។ ប៉ុន្តែខ្ញុំមិនបានមើលឃើញថា តើច្បាប់ណាដែលផ្តល់អំណាចឲ្យខ្ញុំគ្រប់គ្រាន់ ពេញសមត្ថភាពក្នុងការចាត់តាំងចៅក្រមទាំងឡាយនៅទីនេះ ដើម្បីបង្កើតអង្គជំនុំជម្រះតុលាការកំពូល -- ដោយបង្កើតនូវក្រុមប្រឹក្សាជំនុំជម្រះទី២នេះ។

ខ្ញុំគិតថានៅក្នុងកិច្ចព្រមព្រៀងក្តី ច្បាប់ អ.ត.វ.ក ក្តី ទាំងសំណើរបស់អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ ទាំងក្រុមចៅក្រមរបស់អង្គជំនុំជម្រះរបស់កម្ពុជា សុទ្ធតែត្រូវបានធ្វើសំណើឆ្លងកាត់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយសុំព្រះមហាក្សត្រចេញព្រះរាជក្រឹត្យតែងតាំងទាំងអស់។

សូម្បីតែនៅក្នុងអង្គជំនុំជម្រះសាលាដំបូងខ្លួនឯង នៅពេលដែលត្រូវការកែសម្រួលភារកិច្ចពីចៅក្រមមួយរូបដែលជាចៅក្រមបម្រុងទៅជាចៅក្រមពេញសិទ្ធិ ហើយនិងចៅក្រមពេញសិទ្ធិមកជាចៅក្រមបម្រុង ក៏ត្រូវបានរៀបចំឡើងដោយព្រះរាជក្រឹត្យដែរ។ ប្រធានខ្លួនឯងនេះគ្មានសមត្ថភាពតាមផ្លូវច្បាប់ណាមួយអាចចាត់តាំង តែងតាំងអ្នកណាមួយដោយឯងៗបានទេ។ លើកលែងតែការតែងតាំងបណ្ដោះអាសន្ន ដែលអនុវត្តតាមវិធាន៧៩(៤) នៅក្នុងអំឡុងពេលដំណើរការសវនាការ ដែលមានធុរៈ ឬក៏មានជំងឺមិនអាចចូលរួមបាននៅក្នុងរយៈពេលខ្លី រយៈពេលមធ្យម គឺយើងអនុវត្តបានតាមវិធាន៧៩(៤) នៃវិធានផ្ទៃក្នុងប៉ុណ្ណោះ។ ហើយកន្លងមកយើងបានអនុវត្តករណីនេះច្រើន ដោយសារអំណាចនៃវិធានផ្ទៃក្នុងនុំងបានកំណត់ឲ្យដូច្នេះ។

[១០:០៧:៤៣]

បាទ អរគុណនូវចម្លើយបញ្ជាក់បន្ថែមចុងក្រោយអម្បាញ់មិញនេះ។ សំណួរអំមិញដូចមានអាចឆ្លើយរួចហើយ បើអាចបញ្ជាក់បានថែមទៀតក៏អាចបញ្ជាក់ទៅ ដើម្បីឲ្យភាគីពាក់ព័ន្ធ និងសាធារណជនបានយល់ផង ថាតើបើមានយល់ចៅក្រមដែលយើងខ្ញុំជាប្រធានអង្គជំនុំជម្រះសាលាដំបូង ឬក៏ស្ថាប័នផ្សេងទៀតអាចចាត់តាំងបាននោះ តើចៅក្រម និងបុគ្គលិកគាំទ្រទាំងអស់នោះអាចមកបំពេញតួនាទី និងការងាររបស់ខ្លួននៅទីនេះរយៈពេល នៅក្នុងអំឡុងពេលណាបាន?

**លោក ឃ្នុត វ៉ូសាន់ហោក៖**

ដូចដែលខ្ញុំបានបញ្ជាក់ពីខាងដើម នៅពេលដែលសំណើសុំនោះបានធ្វើឡើងនោះ បានស្នើសុំមកនោះ គឺថាយើងនឹងដាក់អត្ថិភាពខ្ពស់បំផុត។ ហើយយើងនឹងស្នើសុំ និងពិភាក្សាជាមួយនឹងភាគីដែលពាក់ព័ន្ធត្រូវធ្វើយ៉ាងម៉េច។ ដូច្នេះ យើងខ្ញុំត្រៀមខ្លួនរួចជាស្រេចក្នុងការឆ្លើយតបទៅនឹងសំណើណាមួយប្រសិនបើស្នើឡើងនោះ។ ខ្ញុំមិនអាចកំណត់កាលបរិច្ឆេទថាតើអាចលឿនប៉ុនណានោះទេ ក៏ប៉ុន្តែវាអាស្រ័យទៅលើអ្វីដែលយើងមាននិងអ្វីដែលយើងអាចធ្វើទៅបាន។ ក៏ប៉ុន្តែចំពោះបុគ្គលិកវាមានលក្ខណៈងាយ គឺថាយើងអាចរកបានងាយ ហើយចំណាយពេលក៏ខ្លីដែរ យើងអាចរកបានហើយ។ ដូច្នេះ ហើយដំណើរការនីតិវិធីដែលយើងអាចជ្រើសរើសវាអាចលឿនជាងបុគ្គលិកអចិន្ត្រៃយ៍។

ហើយប្រសិនបើអង្គជំនុំជម្រះនោះ គឺថាគាត់សុំរក្សាបុគ្គលិកបច្ចុប្បន្នធ្វើការងារទៅនឹងសាលក្រម ហើយប្រសិនបើត្រូវការបុគ្គលិកថ្មីនោះ គឺថាយើងត្រៀមខ្លួនក្នុងការជ្រើសរើស។

[១០:១០:១១]

**ប្រធានអង្គជំនុំ៖**

អរគុណ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

លោកអនុប្រធានរដ្ឋបាល សូមអរគុណចំពោះចម្លើយតបរបស់លោក។ យើងខ្ញុំយល់ទាំងអស់គ្នាថារដ្ឋបាលមានឆន្ទៈ ហើយនិងរីករាយក្នុងការគាំទ្រផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាលដល់អង្គជំនុំជម្រះសាលាដំបូង។ ប្រសិនបើអង្គជំនុំ -- លោកប្រធានសម្រេចទៅលើក្រុមប្រឹក្សាជំនុំជម្រះទី២។ ក៏ប៉ុន្តែបទពិសោធន៍ដែលយើងឆ្លងកាត់មកហើយនោះ គឺខ្ញុំលើកឧទាហរណ៍មួយ ជាពិសេសនៅក្នុងការសុំជំនួសបុគ្គលិកមន្ត្រីច្បាប់ សុំជំនួសមន្ត្រីច្បាប់ គឺវាបានបង្ហាញថាវាមិនជាដំណើរមួយដែលយើងធ្វើទៅបានលឿននោះទេ។ ហើយអាចចំណាយពេលបីទៅប្រាំមួយខែឯណោះ ជំនួសបុគ្គលិកច្បាប់ មន្ត្រីច្បាប់ម្នាក់។ ដូច្នេះ បីទៅប្រាំមួយខែនេះ គឺបានន័យថាជាពេលវេលាលឿនក្នុងការជ្រើសរើសបុគ្គលិកច្បាប់មកជំនួស ឬក៏យ៉ាងម៉េច? ហើយតើបីទៅប្រាំមួយខែនេះ គឺជានីតិវិធីមួយដែលលោកគិតថាវាសាមញ្ញ និងងាយស្រួលនោះ ឬក៏យ៉ាងម៉េច?

[១០:១១:៣៣]

**លោក ឃុត វ៉ូសាន់ហោក៖**

នៅពេលនេះលោកស្រីលើកឡើងអំពីបុគ្គលិកអន្តរជាតិ ចំពោះខាងបុគ្គលិកជាតិគឺខ្ញុំគិតថា លឿនទេ ក៏ប៉ុន្តែខាង យូ.អិន វាអាស្រ័យទៅលើប្រភេទនៃកិច្ចសន្យា ប្រសិនបើកិច្ចសន្យាបណ្តោះអាសន្នក្នុងនាមជាកុងសុលតង់ បានន័យថាយើងអាចរកបានងាយទេ មិនជាថ្វីនោះឡើយ។ សូមអរគុណ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

តើលោកអាចបញ្ជាក់ទេ បើសិនជាបុគ្គលោកបែបហ្នឹង លោកគិតថាអាចរកបានលឿនហ្នឹង គឺបានន័យយ៉ាងម៉េច? ភាគីគឺប្រហែលជាគិតមិនយល់ ហើយសាធារណជនក៏គាត់មិនយល់ដែរ នៅពេលដែលលោកនិយាយថាវាអាចលឿនជាពេលវេលាដែលខ្ញុំលើកឡើងនោះ បានន័យថាពីរខែ ឬក៏ប៉ុន្មានពីរឆ្នាំ ឬយ៉ាងម៉េច រយៈពេលដែលអាចជ្រើសរើសបាន?

**លោក ឃុត វ៉ូសាន់ហោក៖**

ដូចដែលខ្ញុំបានបញ្ជាក់នៅក្នុងចម្លើយរបស់ខ្ញុំ ខ្ញុំមិនអាចបញ្ជាក់ពេលវេលាទេ។ វាអាស្រ័យទៅ

លើបុគ្គលិកដែលយើងត្រូវជ្រើសរើស។ ប្រសិនបើកុងសុលតង់នោះ គឺរើសក្នុងប្រទេសនេះ គឺថាខ្ញុំមានសិទ្ធិក្នុងការជ្រើសរើសតែមួយថ្ងៃក៏បានដែរ។

[១០:១២:៤៦]

**ប្រធានអង្គជំនុំ៖**

បាទសូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លើកលែងតែខ្ញុំស្ដាប់ច្រឡំ។ កិច្ចសន្យារបស់បុគ្គលិកអង្គការសហប្រជាជាតិនោះគឺត្រូវបានបន្តឲ្យបីខែម្ដងៗ។ ខ្ញុំយល់ថាលោកបាននិយាយថាមានដំណើរការខុសគ្នា ក្នុងដំណើរការតែងតាំងបុគ្គលិកជាលក្ខណៈបណ្ដោះអាសន្ន ឬក៏ជាលក្ខណៈរយៈពេលវែង។ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំមិនសូវយល់ទេអំពីបញ្ហានេះ ខ្ញុំមិនដឹងថាហេតុអ្វីបានជាបុគ្គលិកច្បាប់ដែលមកគាំទ្រដល់ក្រុមប្រឹក្សាជំនុំជម្រះទី២ ដែលនឹងអាចដំណើរការក្នុងរយៈពេលវែង គឺថាមួយឆ្នាំ ពីរឆ្នាំអ៊ីចឹង គឺថាអាចមានរយៈពេលកំណត់វែងមួយ។ ហេតុអ្វីបានជា -- ខ្ញុំមិនយល់ថាហេតុអ្វីបើសិនជាដំណើរការវែង ហេតុអ្វីបានជាជ្រើសរើសបុគ្គលិកក្នុងរយៈពេលតែប៉ុណ្ណោះអាសន្ន ឬរយៈពេលខ្លី? លោកគិតថាមានបុគ្គលិករយៈពេលខ្លីសម្រាប់មកធ្វើការឧទាហរណ៍ បីខែ ប្រាំមួយខែដែលថាចប់រយៈពេលបីខែ ប្រាំមួយខែហ្នឹងទៅ តើពួកគាត់ម៉េចនឹងយល់អំពីដំណើរការច្បាប់ ហើយនិងយល់អំពីសំណុំរឿងដែលអង្គជំនុំជម្រះថ្មីនឹងវិនិច្ឆ័យនោះ។ បើសិនជាយើងរើសបីខែ ប្រាំមួយខែចប់ ចេញមករើសអ្នកថ្មីទៀត។ អ៊ីចឹងតើពួកអ្នកទាំងអស់ហ្នឹង គាត់ម៉េចអាចយល់អំពីដំណើរការ គឺថាបីខែ បើសិនឧទាហរណ៍ចប់អ៊ីចឹងទៅវិញ ហើយមានអ្នកថ្មីមកទៀត។ អ៊ីចឹងដូចខ្ញុំមិនយល់អំពីដំណើរការនេះ។

[១០:១៤:៥២]

**លោក ឃ្នុត វ៉ូសាន់ហោក៖**

ខ្ញុំដឹងថាវាពាក់ព័ន្ធបច្ចេកទេសខ្លាំងនៅត្រង់នេះ អង្គជំនុំជម្រះបច្ចុប្បន្នមានកម្លាំងការងាររបស់ខ្លួនរួចមកហើយ។ ខ្ញុំសន្មតថា បុគ្គលិកបច្ចុប្បន្ននេះ ឲ្យធ្វើការងារបន្តទៅទៀតមិនមែនថា បន្ទាប់មកបញ្ចប់ការងារគាត់ក្រោយចេញសាលក្រមទី១នោះទេ។ នេះជាការសន្មតរបស់ខ្ញុំ។ បានន័យថារក្សាទុកបុគ្គលិកដដែលដែលគាត់មានចំណេះដឹង ដឹងអំពីសំណុំរឿងរួចមកហើយ។ ចំពោះបុគ្គលិកបន្ថែមនោះ គឺថាយើងជ្រើសរើសក្នុងករណី -- ក្នុងមូលដ្ឋានបណ្ដោះអាសន្នតែប៉ុណ្ណោះ។ ដូច្នេះបើសិនជាពួកគាត់ជាបុគ្គលិក

បណ្ដោះអាសន្ន យើងមិននិយាយអំពីមុខតំណែងអចិន្ត្រៃយ៍នោះទេ។ ដូច្នេះបានន័យថា យើងធ្វើការជ្រើសរើសក្រុបខ័ណ្ឌមួយខុសពីបុគ្គលិកអចិន្ត្រៃយ៍ ដែលវាអាចជ្រើសរើសតែក្នុងមួយយប់ក៏បានដែរ។

ហើយបើសិនជាអង្គជំនុំជម្រះចង់រក្សាទុកបុគ្គលិកបន្ថែមថ្មីនោះ គឺថាយើងនឹងរកក្របខ័ណ្ឌជ្រើសរើសមួយផ្សេងវិញទៀត ហើយចំណុចដែលខ្ញុំលើកឡើងចុងក្រោយនេះ គឺខ្ញុំ មិនមែនជាការសន្មតរបស់ខ្ញុំនោះទេ។ ដូច្នេះ និយាយមកវិញយើងនឹងធ្វើការងារបំពេញទៅតាមការងារគាំទ្ររបស់អង្គជំនុំជម្រះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ដូច្នេះ ខ្ញុំយល់ច្បាស់អំពីសំណើរបស់លោក គឺថាលោកគាំទ្រអង្គជំនុំជម្រះនុំង គឺមានន័យថាវាអាច -- យើងអាចមានលទ្ធភាពជ្រើសរើសបុគ្គលិកបណ្ដោះអាសន្នបាន ហើយយើងអាចនឹងបញ្ជាក់ជូនថាតើយើងទុកបុគ្គលិកហ្នឹងបន្ត ឬក៏យ៉ាងម៉េច គឺខាងជំនុំ -- អង្គជំនុំជម្រះនឹងជូនដំណឹងដល់ខាងរដ្ឋបាលតទៅទៀត។ តើអ៊ីចឹងទេ?

[១០:១៦:៥៤]

**លោក ឃ្នុត វ៉ូសាន់ហោក៖**

វា -- ចម្លើយ វាអាស្រ័យទៅលើកិច្ចសន្យាការងារតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

បាទ ហើយជាបន្តទៅទៀត បទប្បញ្ញត្តិនានានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធនឹងការតែងតាំងចៅក្រមបម្រុង ត្រូវតែអានឲ្យស្របគ្នានឹងវិធាន៧៩(៤) នៃវិធានផ្ទៃក្នុង ដែលចែងដូចខាងក្រោមនេះ៖

"ក្នុងករណីអវត្តមានចៅក្រមពេញសិទ្ធិណាម្នាក់ ប្រធានរបស់អង្គជំនុំជម្រះសាលាដំបូងបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយនឹងចៅក្រមដទៃទៀត អាចសម្រេចឲ្យលើកពេលវេលាសវនាការ ឬតែងតាំងចៅក្រមបម្រុងឲ្យជំនួសកន្លែងរបស់ចៅក្រមដែលអវត្តមានសម្រាប់កិច្ចបន្តនៃនីតិវិធី។ ប៉ុន្តែទោះជាយើងណាក៏ដោយ នៅពេលដែលចៅក្រមពេញសិទ្ធិដែលអវត្តមាន មានលទ្ធភាពអាចត្រឡប់មកបំពេញការងារវិញ អង្គជំនុំជម្រះសាលាដំបូងអាចសម្រេចជំនួសចៅក្រមបម្រុងដោយចៅក្រមពេញសិទ្ធិវិញ បន្ទាប់ពីបានពិចារណាលើកត្តាទាំងអស់ដែលពាក់ព័ន្ធទៅនឹងសំណុំរឿងក្ដី និងបន្ទាប់ពីយល់ឃើញថាចៅក្រមពេញសិទ្ធិដែលត្រឡប់មកវិញបានទទួលដំណឹងយ៉ាងពេញលេញអំពីការវិវត្តន៍នៃរឿងក្ដីនោះក្នុង

អំឡុងពេលដែលខ្លួនអវត្តមាន”។

[១០:១៨:១៦]

ដោយសន្មតថា នីតិវិធីនៃការតែងតាំងចៅក្រមថ្មីត្រូវបានធ្វើឡើងរួចរាល់ដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម នៅក្នុងករណីនេះ មានលទ្ធភាពច្រើនយ៉ាង ឬសេណារីយ៉ូ ចំពោះរយៈពេល -- ចំពោះប្រធានអង្គជំនុំជម្រះចាត់តាំងចៅក្រមជំនួសចៅក្រមបច្ចុប្បន្ន។ ឧទាហរណ៍ ប្រសិនបើសវនាការលើអង្គសេចក្ដីមិនទាន់ត្រូវបានចាប់ផ្ដើមនៅមុនពេលដែលអង្គជំនុំជម្រះប្រកាសសាលក្រមលើសំណុំរឿង ០០២/០១ តើឯកឧត្ដមប្រធាន លោកអនុប្រធានការិយាល័យរដ្ឋបាលយល់ឃើញថា ក្រុមប្រឹក្សាជំនុំជម្រះនៃអង្គជំនុំជម្រះសាលាដំបូងសម្រាប់សំណុំរឿង០០២/០២ អាចត្រូវមានចៅក្រមពេញសិទ្ធិបច្ចុប្បន្នចំនួនប្រាំរូប បូករួមនិងចៅក្រមបម្រុងបន្ថែមចំនួនប្រាំរូប ឬ ប្រាំពីររូបទៀតដែរឬយ៉ាងណា? តើឯកឧត្ដមប្រធាន ឬក៏លោកអនុប្រធានអាចបញ្ជាក់បានដែរឬទេ អំពីផែនការរបស់ខ្លួនក្នុងការត្រៀមអនុវត្តសេចក្ដីសម្រេចរបស់យើងខ្ញុំ ដែលជាប្រធានអង្គជំនុំជម្រះសាលាដំបូងលើករណីបែបនេះ?

[១០:១៩:៣០]

**ឯកឧត្ដម ក្រាញ់ តូនី៖**

បាទ សូមអរគុណលោកប្រធាន។ ជាថ្មីម្ដងទៀត យើងខ្ញុំត្រៀមខ្លួនចាំគាំទ្រនូវរាល់សេណារីយ៉ូដែលលោកប្រធាននឹងដាក់មក។ វាបើសេណារីយ៉ូ ដែលតិចបំផុតគប្បីយើងមើលនៅក្នុងអ្វីដែលយើងមានក្នុងដៃស្រាប់។ បានសេចក្ដីថា ចៅក្រមបម្រុងដែលមានស្រាប់ តែបើលោកប្រធានយល់ឃើញថាត្រូវតែមានចៅក្រមបន្ថែម ក៏វានៅក្នុងក្របខ័ណ្ឌដែលយើងអាចគ្រប់គ្រងបាននៅក្នុងផ្នែករដ្ឋបាល និងផ្នែកហិរញ្ញវត្ថុ។ ដោយហេតុថា អ.វ.ត.ក យើងមានក្បាលម៉ាស៊ីនស្រាប់ហើយ។ អ្វីដែលមានបន្ថែមហ្នឹង សេណារីយ៉ូដែលអាក្រក់បំផុតហ្នឹង គឺចៅក្រមមួយចំនួនតូច ហើយនិងបុគ្គលិកគាំទ្របាទ។ អ៊ីចឹងយើងមានក្បាលម៉ាស៊ីនដំណើរការដោយរលូនហើយ យើងមានសាលជំនុំ មានអេ.វី មានផ្នែកគ្រប់គ្រាន់ហើយ។ អ៊ីចឹងអ្វីដែលលើសហ្នឹង ខ្ញុំយល់ឃើញថា វានៅក្នុងកម្រិតមួយដែលយើងអាចគ្រប់គ្រងដោយរលូននៃផ្នែកហិរញ្ញវត្ថុ និងរដ្ឋបាល។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ មានអីបន្ថែមទៀត លោកអនុប្រធានការិយាល័យរដ្ឋបាល?

**លោក ឃ្លុត វ៉ូសាន់ហោក៖**

យោបល់បន្ថែមរបស់ខ្ញុំ គឺចៅក្រមដែលត្រូវបានតែងតាំងសម្រាប់ពេលបំពេញការងារនៅ អ.វ.ត.ក ទាំងអស់នោះ គឺថាចៅក្រមនេះ នៅបំពេញការងារដដែល។ ដូច្នេះ ប្រធាននៃអង្គជំនុំជម្រះផ្សេងដែលមានសិទ្ធិក្នុងការបែងចែកទំហំនៃការងារ។ ដូច្នេះហើយ វាអាស្រ័យទៅលើផែនការការងាររបស់ប្រធាន ដែលនៅពេលនោះ និងពិចារណាថាត្រូវតែងតាំង ចាត់តាំងចៅក្រម ឬក៏យ៉ាងណា។ ប្រសិនបើមានការស្នើសុំសម្រេចណានោះ គឺថាយើងខ្ញុំនឹងគាំទ្រ។ ហើយនៅពេលដែលមានសំណើសុំ ឬការសម្រេចណាមួយនៅពេលក្រោយទៀតនោះ ថាយើងខ្ញុំនឹងរក្សាការគាំទ្រ និងផ្តល់ការគាំទ្រដដែល។ សូមអរគុណ។

[១០:២១:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ តើលោកស្រីមានសំណួរអីសួរដែរឬទេ?

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅភាគី ដើម្បីមានឱកាសនៅក្នុងការសាកសួរៗទៅឯកឧត្តមប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល ពាក់ព័ន្ធនឹងបញ្ហាទាំងឡាយដែលបានលើកអម្បាញ់មិញនេះ។ ដោយដំបូងនេះ គឺសូមផ្តល់វេទិកាទជូនទៅសហព្រះរាជអាជ្ញា មុនភាគីដទៃទៀត។

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន មានសំណួរមួយចំនួនតែប៉ុណ្ណោះ ទៅកាន់ខាងការិយាល័យរដ្ឋបាល។ សំណួរទី១ ដើម្បីឱ្យច្បាស់នៅក្នុងរបៀបវារៈរបស់អង្គជំនុំជម្រះនាពេលនេះ បានសួរសំណួរជាក់លាក់ចំពោះចំនួនមន្ត្រីច្បាប់ដែលត្រូវការសម្រាប់អង្គជំនុំជម្រះថ្មី គឺថាជាតិប្រាំរូប អន្តរជាតិប្រាំរូប។ មន្ត្រីច្បាប់ត្រូវការ១០រូបជារួម។ ក្នុងការយល់ឃើញរបស់អង្គជំនុំ -- របស់ការិយាល័យរដ្ឋបាល តើការិយាល័យរដ្ឋបាលអាចមានលទ្ធភាពផ្តល់បុគ្គលិកដូចដែលបានកំណត់ថា ប្រាំរូបខាងជាតិ និងប្រាំរូបអន្តរជាតិដែរឬទេ? ដូច្នេះ សួរម្យ៉ាងទៀត បានន័យថាកញ្ចប់ថវិកាដែលសង្គ្រោះបន្ថែមនោះ តើវាមានគ្រោងទុកសម្រាប់ការផ្គត់ផ្គង់សម្រាប់បុគ្គលិក១០រូបជារួម បើសិនជាមានអង្គជំនុំជម្រះថ្មីដែរឬទេ?

**លោក ឃ្លុត វ៉ូសាន់ហោក៖**

ខ្ញុំសូមឆ្លើយតប គឺចម្លើយខ្លី គឺថាអាចធ្វើទៅបាន។

**លោក នីកូឡាស គូមជែន៖**

សំណួរបន្ថែម គឺប្រសិនបើការិយាល័យសហព្រះរាជអាជ្ញាស្នើសុំផែនការអង្គជំនុំជម្រះមួយទៀត បានន័យថាឲ្យអង្គជំនុំជម្រះនេះ សូមចាប់ផ្ដើមសំណុំរឿង០០២/០២ ដំណាលគ្នាជាមួយនឹងពេលចេញសាលក្រមតែម្ដង ហើយវាជាបន្ទុកមួយបន្ថែមទៅដល់សាលាដំបូង។ ដូច្នេះតើការិយាល័យរដ្ឋបាលអាចជួយក្នុងការផ្ដល់បុគ្គលិកជាតិ មន្ត្រីជាតិប្រាំរូប និងមន្ត្រីអន្តរជាតិប្រាំរូបបន្ថែមក្នុងពេលដំណាលគ្នាដើម្បីឲ្យធ្វើការងាររួមជាមួយគ្នាដែរឬទេ?

[១០:២៤:២២]

**លោក ឃ្នុត រ៉ូសាន់ហោក៖**

ចម្លើយខ្លីគឺថាអាចធ្វើទៅបាន។ គឺធនធានយើងមានដូចគ្នាដដែល។

**លោក នីកូឡាស គូមជែន៖**

ដោយយើងទទួលស្គាល់ថា មានបញ្ហាចរិកា អំពីថាតើនៅពេលណាដែលរឿង០០២/០២ចាប់ផ្ដើម និងបុគ្គលិកបន្ថែម? តើលោកអាចផ្ដល់យោបល់អំពីការចំណាយបន្ថែមដែលពាក់ព័ន្ធទៅនឹងការជំនុំជម្រះវគ្គទី២ និងការចំណាយបន្ថែមទៅលើបុគ្គលិកបន្ថែមដែរឬទេ នៅពេលដែលអង្គជំនុំជម្រះនឹងចាប់ផ្ដើមសំណុំរឿង០០២/០២ ប៉ុន្មានខែមុននេះ? ហើយតើលោកអាចប៉ាន់ស្មានការចំណាយបន្ថែមទៅលើអ្វីដែលយើងលើកឡើងនេះដែរឬទេ ហើយលោកអាចប្រៀបធៀបយ៉ាងម៉េចទៅនឹងការចំណាយបន្ថែមដែលថាវាអាចពាក់ព័ន្ធទៅនឹងការធ្វើការចាប់ផ្ដើមសំណុំរឿង ០០២/០២ ឲ្យបានលឿននោះ?

**លោក ឃ្នុត រ៉ូសាន់ហោក៖**

ចម្លើយខ្លី ចំណាយ -- ការចំណាយ ប្រសិនជាយើងចាប់ផ្ដើមវគ្គទី២នេះឲ្យបានលឿននោះវាចំណាយតិចជាង ប្រសិនបើយើងពន្យារពេលយូរជាងនោះ។

**លោក នីកូឡាស គូមជែន៖**

បាទ ចំពោះខ្ញុំ យើងខ្ញុំអស់មានសំណួរទៀតហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកជំទាវ!

**លោកស្រី ជា លាង៖**

ខ្ញុំមានការសប្បាយចិត្ត ដោយមានការក្រោយពីស្ដាប់អំពីប្រធានរដ្ឋបាល ក៏ដូចជាអនុប្រធានរដ្ឋ

បាលក្នុងការគាំទ្រ និងការបង្កើតនូវ *ផាន៍ែល*ទី២នេះ។ ប៉ុន្តែចំពោះខ្ញុំបានស្តាប់អម្បាញ់មិញនេះថា មិនមានបញ្ហាអំពីថវិកានិងរដ្ឋបាលទេ។ អ៊ីចឹងបញ្ហានេះ ខ្ញុំមានសំណួរខ្លះដែលពាក់ព័ន្ធនឹង តើថវិកានេះ ថវិកាដែលបានអនុម័តហើយសម្រាប់ឆ្នាំ២០១៤ និង ២០១៥ហ្នឹងសម្រាប់តែអ្វីដែលមិនទាន់បង្កើតនៅសំណុំរឿង០០២/០២ ទេមែនទេ?

**ឯកឧត្តម ក្រាញ់ តូនី៖**

ទី១ លោកជំទាវ ខ្ញុំសូមបញ្ជាក់ឡើងវិញថា ថវិកាសម្រាប់២០១៤-២០១៥ មិនទាន់បានអនុម័តទេបាទ វាកំពុងនៅក្នុងការពិនិត្យ ពិចារណារបស់ប្រទេសផ្តល់ជំនួយនៅញូវយ៉កបាទ។ ហើយ--

**លោកស្រី ជា លាង៖**

ខ្ញុំមានសំណួរបន្តទៀត។ ក្នុងករណីដែលសាលាដំបូងបានសម្រេចបង្កើតឲ្យមានសំណុំរឿង ០០២/០២ នេះ តើអង្គជំនុំជម្រះក៏ដូចជាភាគីទាំងអស់មានលទ្ធភាពក្នុងការស្នើសុំធនធានមនុស្សបន្ថែមបានដែរឬទេ? បើបាន តើក្នុងរយៈពេលប៉ុន្មានដែលយើងអាចរើសបុគ្គលិកទាំងនោះមកបម្រើការនៅក្នុងការិយាល័យនីមួយៗ?

**លោក ឃ្នុត វ៉ូសាន់ហោក៖**

ថវិកាបច្ចុប្បន្ន គឺផ្អែកទៅលើគម្រោងថវិការបស់យើងបច្ចុប្បន្ន ហើយចំពោះក្រុមប្រឹក្សាជំនុំជម្រះទី២ មិនបានគ្រោងនៅក្នុងគម្រោងថវិការបស់យើងបច្ចុប្បន្ននោះទេ។ ក៏ប៉ុន្តែយើងមានកញ្ចប់ថវិកាសង្គ្រោះ ឬក៏បន្ថែមនេះ។ ហើយបើសិនជាមានសេចក្តីសម្រេចក្នុងការបង្កើតអង្គជំនុំជម្រះបន្ថែមនោះ ឬក៏មានការជ្រើសរើសបុគ្គលិកបន្ថែមក្នុងការបំពេញសំណុំរឿង០០២/០២នោះ គឺថាយើងមានកញ្ចប់ថវិកាសង្គ្រោះ ហើយយើងនឹងធ្វើការពន្លឿននីតិវិធីក្នុងករណីមានសេចក្តីសម្រេច ឬសំណើសុំបែបនេះ។ ហើយយើងនឹងធ្វើការលឿន ដើម្បីធ្វើជាមួយនឹងភាគីពាក់ព័ន្ធឲ្យដំណើរការនេះអាចលឿន អាចធ្វើទៅបាន ហើយឲ្យយើងអាចជួយជ្រោមជ្រែងទៅលើការងារទាំងអស់នេះបាន។

[១០:២៨:៣៧]

**លោកស្រី ជា លាង៖**

សំណួរខ្ញុំមួយទៀត។ នៅក្នុងថវិកាសង្គ្រោះនេះ ខ្ញុំបានស្តាប់ថា វាមានមិនចូលនៅក្នុងថវិកាហ្នឹងក៏ដោយ ប៉ុន្តែទោះក្នុងករណីដែលការិយាល័យសហព្រះរាជអាជ្ញាត្រូវការធនធានមនុស្ស ដើម្បីប្រើប្រាស់នូវថវិកាសង្គ្រោះនេះ តើមានលទ្ធភាពប្រើប្រាស់ក្នុងថវិកានេះដែរអត់?

**លោក ឃ្លុត រ៉ូសាន់ហោក៖**

សំណើសុំណាមួយ គឺយើងនឹងយកមកពិចារណា ហើយប្រសិនបើការិយាល័យ អង្គជំនុំជម្រះស្នើសុំជាក់លាក់ណាមួយ គឺថាយើងនឹងធ្វើការពិនិត្យ និងពិចារណាទៅលើសំណើសុំទាំងអស់នោះ។

**លោកស្រី ជា លាង៖**

សំណួរខ្ញុំមិនពាក់ព័ន្ធទៅក្នុងអង្គជំនុំជម្រះ សំណើអង្គជំនុំជម្រះទេ។ ក្នុងករណីដែលអង្គជំនុំជម្រះបានសម្រេចបង្កើតនូវអង្គជំនុំជម្រះទី២នេះ ប៉ុន្តែកាលណាបង្កើតអង្គជំនុំជម្រះហាក់ដូចជាបង្កើតតុលាការមួយជាន់ ដែលត្រូវការភាគីទាំងអស់ចូលរួម មិនមែនតែអង្គជំនុំជម្រះសាលាដំបូង គាត់ចូលរួមតែចៅក្រមដដែលខ្លួនគាត់បានទេ ត្រូវតែភាគីក្នុងការចូលរួម។ ដូច្នេះ ក្នុងករណីដែល -- អាហ្នឹងវាកើតឡើងមានមែន -- តើភាគីនេះ ដែលខ្ញុំជាភាគីដែរនៅក្នុងរឿងនេះ ដែលត្រូវចូលរួមក្នុងសវនាការក្នុងសំណុំរឿង០០២/០២នេះ តើខ្ញុំអាចមានលទ្ធភាពប្រើប្រាស់ក្នុងថវិកានេះដែរឬអត់?

[១០:៣០:១៥]

**លោក ឃ្លុត រ៉ូសាន់ហោក៖**

ពាក្យថា“យើង”ហ្នឹង មិនដឹងថាខាងអន្តរជាតិ ឬក៏ជាតិនោះឡើយ។ ចំពោះកញ្ចប់ថវិកាសង្គ្រោះនេះ គឺសម្រាប់តែអន្តរជាតិតែប៉ុណ្ណោះ។

**លោកស្រី ជា លាង៖**

ខ្ញុំប្រហែលជាមានការយល់ច្រឡំផ្នែកខ្លះហើយមិញ ដោយសារខ្ញុំស្តាប់មក ខ្ញុំថាថវិកាសង្គ្រោះនោះសម្រាប់តែជាតិផងនិងអន្តរជាតិផង។ អ៊ីចឹងហើយបានជាខ្ញុំសួរសំណួរនេះរួមតែម្តង។ ដូច្នេះ ឥឡូវខ្ញុំយល់ដោយសារអនុប្រធានរដ្ឋបាលបានបញ្ជាក់ថាថវិកាសង្គ្រោះនេះសម្រាប់តែអន្តរជាតិទេ។ អ៊ីចឹងខ្ញុំងាកទៅសួរផ្នែកប្រធានរដ្ឋបាលខាងជាតិតែម្តង តើក្នុងករណីដែលបង្កើតហ្នឹងខ្ញុំសូមឱ្យប្រធានរដ្ឋបាលខាងជាតិឆ្លើយតបនូវសំណួរនេះចាស។

**ឯកឧត្តម ក្រាញ់ តូនី៖**

សូមអរគុណលោកជំទាវ។ ខ្ញុំសូមឆ្លើយដោយរីករាយ។ បញ្ហាដែលយើងធ្វើមកពិភាក្សាថ្ងៃនេះគឺជាឧត្តមភាពយើងមើលលើចំណាយជាយថាហេតុសម្រាប់សាលាដំបូងហើយយើងបានឆ្លើយជូនហើយថាយើងនៅតែមានលទ្ធភាពទន់ភ្លន់គ្រប់គ្រាន់ដើម្បីគ្រប់គ្រងនូវអ្វីដែលត្រូវការចំណាយលើស ក្នុងករណីដែលសាលាដំបូងសម្រេចយកជម្រើសនៃសភាទី២នេះ។ យើងនៅក្នុងថវិកា យើងមានអ្វីដែលយើងថា

ជាកញ្ចប់មិនសង្គ្រោះបន្ទាន់ទេ កញ្ចប់មួយចំនួនដែលយើងសម្រាប់គ្រប់គ្រងដូចជាថែដន្យណាមួយត្រូវការកុងសុលតង់...។ល។ និងហើយយើងយល់ឃើញថា ជាការពិត គ្រប់សំណើដែលមានភាពច្បាស់លាស់យើងនឹងធ្វើការជាមួយគ្នាតទៀត។ ជាទ្រឹស្តីគឺគ្មានឧបសគ្គអ្វីដែលយើងមិនផ្តល់ទៅនឹងភាគីដទៃទៀតដែលមានភាពចាំបាច់ក្នុងការជ្រើសរើសបុគ្គលិកថ្មី ឬពេញសិទ្ធិក្នុងរយៈពេលណាមួយទេបាទ។

[១០:៣២:០៨]

**លោកស្រី ជា លាង៖**

អ៊ីចឹងខ្ញុំសូមសួរសំណួរទៅឯកឧត្តមប្រធានដើម្បីបញ្ជាក់ឲ្យបានច្បាស់តែម្តង។យើងមានបំណងគាំទ្រនឹងការបង្កើតឲ្យសាលាក្តីក្នុងសំណុំ០០២/០២ កើតមានមែន។ ហើយអាស្រ័យទៅលើរដ្ឋបាល និងថវិកា អ៊ីចឹងចំណុចមួយទៀតក្នុងករណីដែលកើតនូវអ្វីដែលយើងមានបំណងទាំងអស់គ្នាទាំងផ្នែករដ្ឋបាលក៏ដូចជាចៅក្រមទាំងអស់ បានន័យថា នឹងបង្កើតដូចការចង្អុលបង្ហាញរបស់តុលាការកំពូល។ អ៊ីចឹងក្នុងករណីដែលកើតដូចខ្ញុំលើកឡើងអម្បាញ់មិញ ហាក់ដូចជាតុលាការមួយជាន់ដែលនឹងកើតសាជាថ្មីអ៊ីចឹងត្រូវការចៅក្រម ត្រូវការក្រឡាបញ្ជី ត្រូវការព្រះរាជអាជ្ញាឡើងជំនុំជម្រះ ត្រូវការមន្ត្រីអ្នកជំនួយ។ ដូច្នេះក្នុងសវនាការមួយបើកើតសំណុំរឿងហ្នឹង វាមិនអាចដែលជាព្រះរាជអាជ្ញារងម្នាក់ដើម្បីការពារនៅក្នុងសំណុំរឿងហ្នឹងបានទេ វាអាចពាក់ព័ន្ធនឹងការយ៉ាងហោចណាស់ក៏មាន *វេរប្ដូរ* ដើម្បីឡើងជំនុំជម្រះដើម្បីផ្លាស់ប្តូរ។ ឧទាហរណ៍ឈឺអីទៅគ្មានអ្នកណាអាចជំនួសបាន ហើយត្រូវការមន្ត្រីដើម្បីជួយទៀត។ អាបញ្ហានេះ បើសិនជាកើតយើងនឹងជួបបញ្ហាតើថវិកាដែលអត់ចំពោះបុគ្គលិកជាតិ?

[១០:៣៣:២៦]

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ លោកជំទាវ ជាថ្មីម្តងទៀត យើងខ្ញុំរដ្ឋបាលនឹងគាំទ្រគ្រប់សំណើដែលសមស្រប នឹងយោងទៅតាមផែនការសកម្មភាពការងារ។ អ្វីដែលលោកជំទាវលើកឡើងហ្នឹងគឺបញ្ហាកង្វះសាច់ប្រាក់ យើងសុំកុំឲ្យច្រឡំថា បញ្ហាថវិកាលើតួលេខជារឿងមួយ បញ្ហាកង្វះសាច់ប្រាក់ជារឿងមួយទៀតបាទ ហើយតាំងពីឆ្នាំ២០០៨ , ២០០៩ មកតុលាការយើងតែងតែប្រឈមនឹងបញ្ហាកង្វះសាច់ប្រាក់ *ខាសហ្វ្លូ* ប៉ុន្តែជាងមួយឆ្នាំទៅមួយឆ្នាំប្រាក់ខែមួយខែ ១២ខែយើងតែងតែមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបើកប្រាក់ខែជូនបុគ្គលិកនិងមន្ត្រីតុលាការរបស់យើងបាទ។ អ៊ីចឹងនេះជាថ្មីម្តងទៀត យើងនឹងគាំទ្រគ្រប់លទ្ធភាពក្នុងការងាររដ្ឋបាលនិងហិរញ្ញវត្ថុគ្រប់ផ្នែកទាំងអស់ យោងទៅតាមផែនការសកម្មភាពការងារ និងការតម្រូវ

ការជាក់ស្តែង។ អានេះយើងទាមទារឲ្យមានការជួបគ្នាជជែកគ្នាស៊ីជម្រៅទៀតទៅតាមផ្នែកបច្ចេកទេស ពេលណាដែលសាលាដំបូងសម្រេចថាត្រូវដើរផ្លូវណានោះបាទ។

**លោកស្រី ជា លាង៖**

ខ្ញុំអរគុណណាស់លោកឯកឧត្តមប្រធានចំពោះបញ្ហានេះ។ ហើយសំណួរមួយទៀតដែលពាក់ព័ន្ធអំពីបញ្ហាថវិកានេះដែរ ក្នុងករណីដែលមានសេចក្តីសម្រេចណាមួយរបស់សាលាដំបូងដែលសម្រេចថា បង្កើតដោយវិធីណាមួយដោយពិចារណាទៅលើផ្លូវច្បាប់ក្នុងការបង្កើតអ្វីក៏ដោយ ខ្ញុំចង់ដឹងថាអំពីការតែងតាំងបុគ្គលិក ខ្ញុំមិននិយាយទៅលើចៅក្រម និងព្រះរាជអាជ្ញាដែលតែងតាំងដែលមានការពាក់ព័ន្ធទៅលើព្រះរាជក្រឹត្យទេ។ ខ្ញុំនិយាយអំពីបុគ្គលិកក្នុងការជំនួយ ដូច្នេះក្នុងរយៈពេលហ្នឹង តើអាចជារយៈពេលមួយវែង ពីព្រោះកន្លងមកដូចចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ លើកឡើងអ៊ីចឹង ខ្ញុំសង្កេតឃើញក្នុងការជ្រើសរើសបុគ្គលិកហ្នឹងមានត្រូវការរយៈពេលណាស់ ទម្រាំបានបុគ្គលិកហ្នឹង។ ដូច្នេះយើងបើសិនជាគោរពទៅលើសេចក្តីសម្រេចរបស់តុលាការកំពូល យើងថានឹងដំណើរការឲ្យបានលឿនបំផុតដែលអាចធ្វើទៅបាន។ អានេះដែលយើងមានឆន្ទៈចង់ធ្វើ។ បើសិនជាយើងក្នុងករណីដែលវាកើតលឿន ហើយយើងត្រូវការបុគ្គលិកដើម្បីធ្វើការលឿន តើខាងរដ្ឋបាលខាងជាតិនេះ តើរយៈពេលប៉ុន្មានដែលយើងអាចរើសបុគ្គលិកជាតិនោះមកធ្វើការបាន?

[១០:៣៥:៥៥]

ហើយភ្ជាប់ជាមួយគ្នានឹងដែរ ជាបញ្ហាមួយការព្រួយបារម្ភរបស់ខ្ញុំ ការដែលបុគ្គលិកថ្មីមកធ្វើការទីនេះ វាជារឿងមួយដែលខ្ញុំយល់ថា វាជាការមួយលំបាក។ ដោយសារអី? សំណុំរឿងនេះសំណុំរឿងដែលធំណាស់។ ដូច្នេះទោះបីអ្នកជំនួយការក៏ដោយ អ្នករៀបឯកសារក៏ដោយត្រូវមកហ្នឹងថ្មី គឺថាសិក្សាទាំងអស់ៗ ទម្រាំយល់សាច់រឿងហ្នឹង។ ទោះបីឡើងជម្រះព្រះរាជអាជ្ញារងថ្មីក៏ដោយ សិក្សារឿងទាំងមូល រឿងហ្នឹងមិនមែនយើងសិក្សាមួយខែបានទេ។ ដូច្នេះយើងគប្បី យើងថាពិចារណាតើអត្ថិភាពរើសយ៉ាងដូច្នេះដើម្បីយើងចំណេញពេល។ ព្រោះខ្ញុំមិនថាទេ បីខែខ្ញុំឲ្យចៅក្រមថ្មីដែលសុទ្ធសាធ បុគ្គលិកថ្មីសុទ្ធសាធដែលមកធ្វើការទីនេះសិក្សាតែ *ហ្វាយឡេប* ហើយនិង*ខេសមេហ*បីករកឯកសារ ខ្ញុំសឹងថារកមិនទាន់ឃើញក្នុងរយៈពេលមួយខែ។ ដូច្នេះ ខ្ញុំចង់ដឹងពីនីតិវិធីក្នុងការផ្តល់បុគ្គលិកឲ្យខ្ញុំ តើអាចជាបុគ្គលិកយ៉ាងម៉េច? ហើយរយៈពេលៗប៉ុនណា បើសិនជាកើតមែន?

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទលោកជំទាវ យើងធ្វើការជាមួយគ្នាជាងប្រាំ-ប្រាំមួយឆ្នាំហើយ ការជ្រើសរើសបុគ្គលិកហ្នឹង វាចំណុះទៅនឹងនីតិវិធីរបស់ផ្នែកបុគ្គលិក។ វាមានបែបបទរបស់វា យើងត្រូវផ្សព្វផ្សាយ អាហ្នឹង សម្រាប់បុគ្គលិកពេញសិទ្ធិ។ វាទាមទារពេលវេលារយៈពេលមួយ រយៈពេលមួយប៉ុន្តែវាមិនដល់ថ្នាក់ ថាយូរហួសហេតុទេបាទ មួយខែ ដូចផ្សព្វផ្សាយ១៥ថ្ងៃ ជ្រើសរើស សម្ភាស...។ល។ វាមានបែបបទ របស់វា ជាទម្លាប់របស់វាក្នុងការធ្វើការឲ្យស្របតាមនីតិវិធី។ ហើយប៉ុន្តែបុគ្គលិកបើត្រូវការចាំបាច់មែន *កង់សុលតង់* គឺវាមួយពព្រិចភ្នែកទេ យើងនៅលើទីផ្សារជាតិយើងហើយ។ ដូចបើតម្រូវការត្រូវមានមែន យើងនឹងសម្របសម្រួលទៅតាមអ្វីដែលលោកជំទាវបានមានក្តីបារម្ភក្នុងការរឿងជ្រើសរើសបុគ្គលិក កម្ពុជា។

[១០:៣៨:០០]

**លោកស្រី ជា លាង៖**

សូមអរគុណណាស់។ ដូច្នេះ ខ្ញុំជាភាគីមួយដែរនៅក្នុងរឿងក្តីនេះ ហើយខ្ញុំនឹងរង់ចាំនូវសេចក្តី សម្រេចរបស់សាលាដំបូងដោយវិធីណាក៏ដោយ ទោះបីដោយចៅក្រម*រេវ៉េហ្សូរ* ក៏ដោយ ដោយចៅក្រម ដែលតែងតាំងថ្មី ឬចៅក្រមដែលមានស្រាប់សព្វថ្ងៃនេះ ហើយក្នុងសេចក្តីសម្រេចណាមួយដែលឲ្យ បង្កើត គឺខ្ញុំនឹងធ្វើលិខិតភ្លាមទៅរដ្ឋបាល ដើម្បីផ្តល់ធនធានមនុស្សឲ្យខ្ញុំគ្រប់គ្រាន់ក្នុងការប្រើប្រាស់។ បើសិនជាយើងមានថវិកា ហើយសម្រេចថាមិនមានបញ្ហាអីក៏ដោយ បើយើងមិនមានធនធានមនុស្សទេ ក៏យើងអត់អាចដំណើរការបានដែរ។ យើងមានតែលុយអត់មានមនុស្សប្រើ ដែលគិតថាមនុស្សហ្នឹង ហួស។ ហើយខ្ញុំសូមជម្រាបផងដែរថា ការិយាល័យសហព្រះរាជអាជ្ញាវាមានលក្ខណៈចម្លែកខ្លះ ដោយ ថាយើងការពារតាំងពីសាលាដំបូងរហូតតុលាការកំពូល។ ដូច្នេះយើងធ្វើការតាំងពីជាមួយភី.ធី.ស៊ី ផង, ធ្វើការជាមួយ អូ.ស៊ី.អាយ.ជេ ផង រហូតដល់ទោះបីយើងមានការខ្វែងគំនិតគ្នាក្នុងសំណុំរឿង០០៣, ០០៤ ក៏ដោយ ក៏យើងត្រូវការធនធានមនុស្សដើម្បីពិនិត្យទៅលើសំណុំរឿង។ ដូច្នេះទោះបី តុលាការ កំពូលក៏ដោយ។ ដូច្នេះថាតើសហព្រះរាជអាជ្ញាមានតួនាទីនៅការពារនៅក្នុងរឿងការងារស្អីខ្លះ ដែល យើងត្រូវការធនធានមនុស្សដើម្បីបែងចែក។ ក្នុងផ្នែកនីមួយៗរកតែមនុស្សពីរនាក់អត់បានផង។ ដូច្នេះ ថា តើយើងអាចមានធនធានមនុស្សគ្រប់គ្រាន់ក្នុងការប្រើប្រាស់ដែរអត់? អានេះជាអ្វីដែលខ្ញុំមានការ កង្វល់។ យើងត្រូវការមនុស្សដើម្បីមកប្រើ យើងមិនអាចប្រើរហូតថ្ងៃបុណ្យ និងថ្ងៃឈប់ដោយមិន

មានឈប់សម្រាកនោះទេ។ ទោះបីបុគ្គលិកហ្នឹងយ៉ាងម៉េចក៏ដោយ គឺយើងត្រូវពិចារណាអំពីបញ្ហានេះដែរ។ អ៊ីចឹងខ្ញុំសប្បាយចិត្ត ហើយបើសិនជាសេចក្តីសម្រេចសម្រេចយ៉ាងណានោះ ខ្ញុំនឹងគោរពតាម ហើយខ្ញុំធ្វើលិខិតភ្លាមដើម្បីឱ្យរដ្ឋបាលរកវិធីដោះស្រាយឱ្យបានជាប្រញាប់ទៅតាមអ្វីដែលសេចក្តីសម្រេចរបស់សាលាដំបូង។ អានេះជាសំណូមពររបស់ខ្ញុំ។

[១០:៣៩:៤៧]

ដោយឡែកមួយទៀត ខ្ញុំគ្រាន់ឱ្យជាយោបល់ទេ ឬក៏អំពីបញ្ហាទាក់ទងនឹងការតែងតាំងនេះ។ ដូចសាលាដំបូង ប្រធានសាលាដំបូងគាត់លើកឡើងហើយ ការតែងតាំងនេះខ្ញុំក៏ជាសមាជិកឧត្តមម្នាក់នៅក្នុងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ដូច្នេះការតែងតាំងអ្វីៗក៏ដោយ នៅកម្ពុជាគឺមានព្រះមហាក្សត្រគាត់ជាប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ សូម្បីថាបង្កើតតុលាការនេះ ការតែងតាំងចៅក្រម និងព្រះរាជអាជ្ញានៅទីនេះគឺការសម្រេចដោយព្រះរាជក្រឹត្យរបស់ព្រះករុណា។

ដូច្នេះ កន្លងមកសូម្បីដូចគាត់លើកឡើងអ៊ីចឹង សូម្បីប្តូរពី រវៀហ្សេរទៅពេញសិទ្ធិ, ពេញសិទ្ធិមករវៀហ្សេរ ដែលនៅក្នុងជាន់ហ្នឹងក្នុងសាលារបស់គាត់ ដែលជាសាលាដំបូងក៏ត្រូវមានព្រះរាជក្រឹត្យដែរ។ ដូច្នេះ ខ្ញុំគ្រាន់តែជាចំណុចមួយឱ្យមានការចាប់អារម្មណ៍ ហើយមានលក្ខណៈស៊ីសង្វាក់ទៅនឹងនៃកិច្ចព្រមព្រៀង ក៏ដូចជាច្បាប់នៃ អ.វ.ត.ក ដែរ។ អានេះជាយោបល់របស់ខ្ញុំទេ។ កុំឱ្យយើងមានការបង្កើតហើយ មានបញ្ហារាំងស្ទះ យើងមិនអាចដំណើរការបាន។ អានេះខ្ញុំគ្រាន់តែពិភាក្សាអំពីផ្លូវច្បាប់ និងឱ្យបានស៊ីជម្រៅផង។ ចាសអរគុណ។

**ប្រធានអង្គប្រជុំ៖**

បាទ អរគុណលោកជំទាវ។ ឥឡូវនេះដល់ពេលសម្រាកហើយ ហើយប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចប្រជុំពិភាក្សារបស់យើង។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៤១ នាទី ដល់ម៉ោង ១១:០៤ នាទី)*

[១១:០៤:៣៥]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ!

បាទ យើងបន្តកិច្ចប្រជុំពិភាក្សារបស់យើងតទៅទៀត។ សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

ជាដំបូងខ្ញុំសូមសូមថ្លែងអំណរគុណចំពោះសហព្រះរាជអាជ្ញាដែលបានចោទជាសំណួរ និងផ្តល់ជាយោបល់។ ខ្ញុំមានចំណុចមួយចំនួនដែលខ្ញុំចង់ដឹងឲ្យបានស៊ីជម្រៅជាងនេះពីខាងសហព្រះរាជអាជ្ញាណាមួយក៏បានដែរ។

ចំណុចទី១ ពាក់ព័ន្ធទៅនឹងសំណើរបស់រដ្ឋបាលដែលបានស្នើសុំមកខាងប្រធានអង្គជំនុំជម្រះសាលាដំបូង ដែលថាលោកប្រធានមានអំណាចផ្លូវច្បាប់ ហើយអាចចាត់តាំង តែងតាំងចៅក្រមជាក្រុមប្រឹក្សាជំនុំជម្រះទី២បាន។ ខ្ញុំសូមសួរយោបល់ពីខាងសហព្រះរាជអាជ្ញា ក្នុងចំណោមចៅក្រមបម្រុងទាំងប្រាំដែលបានលើកឡើងពីខាងដើម គឺម្នាក់ៗ ចៅក្រមម្នាក់មកពីអង្គជំនុំជម្រះសាលាដំបូង ម្នាក់មកពីតុលាការកំពូល ម្នាក់មកពីអង្គបុរេជំនុំជម្រះ ហើយក៏មកពីខាងការិយាល័យសហចៅក្រមស៊ើបអង្កេត និងការិយាល័យសហព្រះរាជអាជ្ញា។ តើលោកសហព្រះរាជអាជ្ញា លោក លោកស្រីសហព្រះរាជអាជ្ញាមានយោបល់យ៉ាងម៉េចដែរ ប្រសិនបើចៅក្រមបម្រុងម្នាក់ពីខាងការិយាល័យសហព្រះរាជអាជ្ញាត្រូវបានតែងតាំងចាត់តាំងឲ្យមកចូលរួមជាក្រុមប្រឹក្សាជំនុំជម្រះទី២ តើមានបញ្ហាឧបសគ្គអ្វីមួយដែរឬទេចំពោះខាងសហព្រះរាជអាជ្ញា?

[១១:០៦:៣៣]

**លោកស្រី ជា លាង៖**

ចាសសូមអរគុណណាស់ លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍។ ខ្ញុំទុកឲ្យភាគីខាងអន្តរជាតិគាត់នឹងឆ្លើយពាក់ព័ន្ធអំពីបញ្ហាផ្លូវច្បាប់នេះ ប៉ុន្តែគ្រាន់ខ្ញុំចង់បញ្ជាក់បន្តិចអំពីករណីជាក់ស្តែង អំពីរេហ្សែវនៅខាង អូ.ស៊ី.ភី នេះ គឺលោក ជួន ស៊ុនឡេង សព្វថ្ងៃគាត់មិនមានសមត្ថភាពធ្វើការ គាត់ឈឺធ្ងន់។ ដូច្នេះចាត់ទុកថាគាត់អត់ទាន់ធ្វើការងារបានទេ នៅពេលបច្ចុប្បន្ន គឺគាត់សម្រាកនៅផ្ទះ ដោយសារគាត់មាន

ជំងឺលើសសរសៃឈាមងាប់មួយចំហៀងខ្លួនហើយ ដូច្នេះគាត់អត់អាចធ្វើការកើតទេ។ អានេះជាព័ត៌មានមួយជាក់ស្តែង ខ្ញុំគ្រាន់តែជាជូនដំណឹងទេ។ អ្វីដែលខាងរដ្ឋបាលរៀបរាប់ប្រាំនោះ គឺគាត់រាប់ទាំងលោកជួន ស៊ុនឡេង ហ្នឹងផងដែរ។ អ៊ីចឹងខ្ញុំជូនបញ្ហានេះ។ ហើយចំពោះខាងជាតិដែលក្នុងការរើសជំនួសគាត់ជាអ្នកបម្រុងនៅកន្លែង អូ.ស៊ី.ភី នេះ ឧត្តមក្រុមប្រឹក្សានឹងយកទៅពិចារណា។ ដោយឡែកអំពីផ្លូវច្បាប់អំពីការបង្កើតនៅផ្នែលទី២ នេះ ខ្ញុំទុកខាងឲ្យ នីកូ គាត់នឹងឆ្លើយសំណួររបស់លោកស្រីចៅក្រមនេះ។

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រីចៅក្រម លោក លោកស្រីដឹងហើយថា ខាងសហព្រះរាជអាជ្ញាអន្តរជាតិមិនមានបម្រុងនោះទេ។ ដូច្នេះវាមិនមានលទ្ធភាពតែងតាំងចៅក្រមបម្រុងទាំងជាតិ និងអន្តរជាតិពីខាងសហព្រះរាជអាជ្ញានោះទេ។ ទោះបីជាយ៉ាងណាក៏ដោយប្រសិនបើសហព្រះរាជអាជ្ញា មានការចូលរួម អ៊ីចឹងមែនគឺថា វាអាចមានទំនាស់ផលប្រយោជន៍ដដែល ហើយមិនមានបេក្ខជនណាមួយបម្រុងពីខាងសហព្រះរាជអាជ្ញាអាចទៅបំពេញជាសមាជិកនៃក្រុមប្រឹក្សាជំនុំជម្រះទី២ នោះទេ។

[១១:០៨:២២]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សំណួរបន្ថែម តើលោកមានយោបល់យ៉ាងម៉េចចំពោះសមត្ថកិច្ចរបស់ខាងលោកប្រធាន ក្នុងការចាត់តាំងចៅក្រមជាសមាជិកក្រុមប្រឹក្សាជំនុំជម្រះទី២ ចេញពីបញ្ជីបេក្ខជនរងនោះ?

**លោក នីកូឡាស គូមជែន៖**

ខ្ញុំលើកឡើងនៅក្នុងកថាខណ្ឌ៧៤ នៃសេចក្តីសម្រេចរបស់តុលាការកំពូល នៅក្នុងនោះតុលាការកំពូលបានបញ្ជាក់ថា មិនមានការឧបសគ្គក្នុងការតែងតាំង ព្រមទាំងជំនុំជម្រះទី២នោះទេ ហើយដែលវាធ្វើយ៉ាងនេះជួយសម្រួលទៅដល់ផលប្រយោជន៍យុត្តិធម៌។ ចំណុចនេះវាបានឆ្លើយតបទៅនឹងសំណួរនេះរួចមកហើយ ប្រសិនបើប្រធានយល់ឃើញថា ចាំបាច់ថាចៅក្រមបម្រុងមកពីផ្នែកផ្សេងៗទទួល -- ត្រូវតែមានការឯកភាពសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនោះ គឺថាគួរតែដាក់សំណើនេះទៅខាងការិយាល័យរដ្ឋបាលឲ្យសម្របសម្រួលសំណើនេះ។

ហើយខ្ញុំគិតថា ដំណើរការនេះមិនចំណាយពេលយូរនោះទេ គឺថាដំណើរការវាអាចចាប់ផ្តើមទៅបាននៅពេលដែលមានសេចក្តីបង្គាប់ពីសាលាដំបូង។

អ្វីដែលយើងត្រូវការ និងចាំបាច់នៅទីនេះ គឺថាវាត្រូវ -- យើងត្រូវការតែដីកាសម្រេច ឬសេចក្តី

សម្រេចពីអង្គជំនុំជម្រះសាលាដំបូងតែប៉ុណ្ណោះបន្ទាប់មកអាចដាក់ទៅតាមរដ្ឋបាល បន្ទាប់ទៅរដ្ឋបាលនឹងអាចសម្របសម្រួលទៅកាន់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមបាន។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៏៖**

ខ្ញុំគិតថា លោកទទួលស្គាល់រួចមកហើយ វាមិនមែនជាបញ្ហាសាមញ្ញសម្រាប់ប្រធាននោះទេក្នុងការចេញសេចក្តីសម្រេចមួយបែបនេះ។ លោកបានទទួលស្គាល់រួចមកហើយទៅលើចំណុចនេះ។ ហើយយើងក៏មិនអាចប្រកាសសេចក្តីសម្រេចនេះនៅក្នុងថ្ងៃនេះផងដែរ។ តើលោកទទួលស្គាល់ដែរឬទេថាការចេញសេចក្តីសម្រេច ដីកាសម្រេចនេះអាចចំណាយពេលមួយរយៈផងដែរ?

**លោក នីកូឡាស គូមជែន៖**

នៅក្នុងការយល់ឃើញរបស់ខ្ញុំ បញ្ហានេះវាអាចសម្រេចបានលឿនក៏អាចថាបាន។ អង្គជំនុំជម្រះឬលោកប្រធាន អាចធ្វើការសម្រេចថាចាត់តាំង អាចចាត់តាំងអ្នកណាមួយឲ្យធ្វើជាសមាជិកតែម្តងទៅឬក៏បើសិនជាមានចំណុចណាមួយសង្ស័យ លោកប្រធានថាមិនអាចធ្វើទៅបាន អាចដាក់សំណើនេះទៅកាន់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែម្តងទៅ។

[១១:១០:៤៦]

យើងធ្វើយ៉ាងណាជៀសវាងកុំឲ្យមានសេចក្តីសម្រេចណាស្មុគស្មាញ ហើយយើងធ្វើយ៉ាងណាចេញសេចក្តីសម្រេចមួយ ដែលអាចធ្វើការងារទៅបាន កុំឲ្យចេញសេចក្តីសម្រេចមួយវាជាប់គាំង។ ដូច្នេះ តាមការយល់ឃើញរបស់ខ្ញុំ នៅពេលដែលមានផែនការសម្រេចរួចមកហើយ ក្នុងការចាប់ផ្តើមក្រុមប្រឹក្សាណាមួយ សាលាដំបូងគឺថាអាចធ្វើទៅតាមដំណើរបាន។ ហើយខ្ញុំៗទទួលស្គាល់ថា អង្គជំនុំជម្រះសាលាដំបូងមិនអាចចាប់ផ្តើមនៅថ្ងៃស្អែកតែម្តងនោះទេ ចំពោះដំណាក់កាលក្រោយ។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ អាចត្រូវតែមានសេចក្តីសម្រេចណាមួយឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ហើយឬក៏អាចថាបង្កើតយកចៅក្រមថ្មីមកឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ឲ្យគេយល់អំពីដំណើរការរឿងរបស់យើង។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៏៖**

ខ្ញុំមានសំណួរមួយចំនួនទៀត លោក គូមជែន។ លោកចង់ឲ្យដំណើរការ ឬសេចក្តីសម្រេចនេះធ្វើឲ្យលឿនពីប្រធាន។ បានន័យថា បន្ទាប់ពីសេចក្តីសម្រេចនេះ អាចមានដំណើរការរយៈពេលពីរបីខែក្រោយហ្នឹង អាចដំណើរការទៅបានតែម្តង។ ចំណុចនេះ គឺគ្រប់គ្រាន់ បើសិនជាមានសេចក្តីសម្រេច

ចេញលឿនអ៊ីចឹង។ មែនដែរឬទេ?

**លោក នីកូឡាស គូមជែន៖**

បាទជាការពិតដូច្នោះមែន។ ក៏ប៉ុន្តែមានសេចក្ដីសម្រេចជាការសំខាន់មួយហើយ ក៏ប៉ុន្តែលទ្ធផលដែលអាចអនុវត្តទៅបាននោះ ជាចំណុចសំខាន់មួយទៀត។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

អ្វីដែលលោកបានលើកឡើង លោកបានស្នើឡើងអំពីក្រុមប្រឹក្សាជំនុំជម្រះទី២ ហើយនៅក្នុងសេចក្ដីសន្និដ្ឋានរបស់លោក លោកបានលើកឡើងថា ប្រសិនបើអង្គជំនុំជម្រះទី២បង្កើតនោះ គួរតែដំណើរការឲ្យបានលឿន។ ហើយប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះទី២ បង្កើតហើយមិនដំណើរការទៅលឿននោះទេ គឺគួរតែឲ្យអង្គជំនុំជម្រះបច្ចុប្បន្ននេះដំណើការទៅតែម្ដង តែធ្វើយ៉ាងណាក៏ដោយឲ្យដំណើរការនេះឲ្យលឿនតាមដែលអាចធ្វើទៅបាន។ នៅក្នុងបរិបទនេះ លោកបានលើកឡើងថា វិធីមួយក្នុងការសម្រេចបានចំពោះការដែលយើងចង់បាននោះ គឺធ្វើយ៉ាងណាឲ្យមានបុគ្គលិកបន្ថែមឲ្យបានគ្រប់គ្រាន់។ ហើយគឺថាវាអាចមានបុគ្គលិកច្បាប់ប្រាំ ឬក៏ប្រាំពីរនាក់បន្ថែមសម្រាប់យើង។ ហើយខាងការិយាល័យរដ្ឋបាលបានបញ្ជាក់ហើយថា អាចជ្រើសរើសបានទៅលឿនតែប៉ុណ្ណោះចំពោះត្រូវការបុគ្គលិកបន្ថែម។ ហើយតើលោកអាចបញ្ជាក់ទេ ចៅក្រមថ្មីដែលមកសិក្សាសំណុំរឿងនេះ ចំណាយពេលប្រហែលចំនួនប៉ុន្មានដែរដើម្បីឲ្យគាត់យល់? ហើយធ្វើយ៉ាងណា គឺថាចៅក្រមទាំងអស់នោះគាត់អាចចំណាយពេលប៉ុន្មានដើម្បីឲ្យគាត់យល់រឿងហ្នឹង រួមជាមួយនឹងសាលក្រមគ្រោងដែលនឹងចេញផងដែរ។

[១១:១៣:៤១]

ជាពិសេស ថាតើចំណាយពេលប៉ុន្មានដែរ ដើម្បីឲ្យបុគ្គលិកច្បាប់ជាតិនោះ គាត់ដឹង យល់អំពីរឿងក្ដី ហើយការងារចំណាយរយៈពេលប៉ុន្មានដើម្បីចាត់ចែងការងារទៅកាន់បុគ្គលិកថ្មីទាំងអស់នេះ។ តើលោកមានបានពិចារណាទៅលើទិដ្ឋភាពទាំងអស់នេះដែរឬទេ តាមការយល់ឃើញរបស់លោក? ហើយឬក៏លោកយល់ឃើញថា វាជាការងារមួយដែលអាចចៅក្រមអាចធ្វើទៅបានយ៉ាងងាយតែប៉ុណ្ណោះ នៅពេលត្រឹមពេលចេញសាលក្រម? ចំពោះបុគ្គលិកអន្តរជាតិប្រាំរូបដែលយើងលើកឡើងថា ទៅកាន់ការិយាល័យសហព្រះរាជអាជ្ញានេះគឺនៅក្នុងអនុស្សរណៈ ដែលក្នុងនោះលើកឡើងអំពីរបៀបវារៈពាក់ព័ន្ធទៅនឹងបុគ្គលិកបន្ថែមប្រាំរូបពីខាងអន្តរជាតិ។ យើងមិនដែលលើកឡើងថា វាជាបញ្ហាមួយងាយស្រួលនោះទេ ហើយវាក៏ត្រូវការពេលវេលា ហើយដំណើការនោះក៏វាស្មុគស្មាញផងដែរ។ ក៏ប៉ុន្តែមានការ

ចង្អុលបង្ហាញឧទាហរណ៍មួយចំនួន ឬក៏បទពិសោធន៍មួយចំនួន ដែលចៅក្រមចូលរួមនៅក្នុងវគ្គទី២ នៅក្នុងពេលដែលសរសេរសាលក្រមដូចជានៅតុលាការ អេស.អិល.អេហ្វ ឬតុលាការផ្សេងទៀតនោះ គឺមានបទពិសោធន៍បែបហ្នឹង។ យើងក៏បានចង្អុលបញ្ជាក់ពីរយៈពេលដែលនៃការចាប់ផ្ដើមសវនាការ វាពាក់ព័ន្ធទៅនឹងបញ្ហាថវិកា ហិរញ្ញវត្ថុ។ ហើយប្រសិនបើតុលាការមិនបើកសវនាការឲ្យបានលឿនទេ គឺថាការចំណាយនេះវានៅតែចំណាយដដែល។ ដូច្នេះ តុលាការ គឺគេតម្រូវឲ្យធ្វើការឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ដោយសារហេតុផលមួយចំនួនដូចដែលបានចង្អុលបញ្ជាក់ជាច្រើនលើកច្រើនសាហើយ បញ្ហាទី១ វាពាក់ព័ន្ធទៅនឹងអាយុរបស់ជនជាប់ចោទ។ ឧក្រិដ្ឋកម្មដែលបានកើតឡើង៣០-៤០ឆ្នាំរួចមកហើយនោះ គឺថាជនជាប់ចោទគាត់មានវ័យចំណាស់ ហើយហេតុដូច្នេះហើយគឺថា យើងគួរតែរៀបចំសវនាការការជំនុំជម្រះឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ដោយគិតពិចារណាអំពីវ័យជរារបស់ជនជាប់។ ដូច្នេះ យើងគួរតែធ្វើការងារ០២នេះ ឲ្យបានលឿនតាមដែលអាចធ្វើទៅបាន ហេតុដូច្នេះហើយបានជាគេចង់ឲ្យមានការបង្កើតអង្គជំនុំជម្រះទី២។

[១១:១៦:១២]

ខ្ញុំយល់ថាវាចំណាយពេលមួយរយៈ ដើម្បីបង្កើតក្រុមប្រឹក្សានេះ។ ហើយចំពោះខ្ញុំយល់គឺវាយ៉ាងណាក៏ដោយ យើងត្រូវតែសម្របសម្រួលការងារហ្នឹងជាមួយនឹងសាលក្រមផងដែរ ដែលវាតម្រូវការឲ្យមានការបកប្រែផងដែរ។ ដូច្នេះ ការងារទាំងអស់នេះវាទាមទារឲ្យយើងប្រឹងប្រែង និងតម្រូវការខ្លាំងណាស់ ហើយយើងដឹងហើយថា ចៅក្រមទាំងអស់នៅទីនេះ គឺជាចៅក្រមមានសមត្ថភាពអាចធ្វើតុល្យ-ភាពថ្លឹងថ្លែងអំពីការលំបាកទាំងអស់នេះបាន ដើម្បីឲ្យរឿងក្ដីនេះដំណើរការទៅមុខ។ ហើយអ្វីដែលយើងគិតនោះមិនមែនថាគ្រប់លទ្ធភាពទាំងអស់មិនអាចធ្វើទៅបាននោះទេ។ ហើយយើងខ្ញុំយល់ឃើញថា បញ្ហាសំខាន់វាជាកត្តាកិច្ចរបស់យើងទាំងអស់គ្នា។ សំណុំរឿង០០២/០២ គឺនៅមានសល់បទចោទដែលនៅសល់ ហើយនិងទីតាំងបទល្មើស ការកាប់សម្លាប់ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងការរំលោភសេពសន្ថវៈជាដើម។ តុលាការនឹងធ្វើការស្ដាប់ បើកសវនាការទៅលើបទចោទទាំងអស់នេះ។ ហើយផែនការនោះគឺថា គួរតែធ្វើឡើងឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន តើយើងដោះស្រាយយ៉ាងម៉េច ដើម្បីយើងអាចដំណើរការទៅមុខបាន។

ប្រសិនបើយើងគ្រាន់តែពន្យារពេលផែនការរបស់យើង ឬពន្យារពេលចេញសេចក្ដីសម្រេច គឺថាពេលនោះ ពេលវេលានឹងពន្យារពេល ចំណាយក៏កាន់តែច្រើន ហើយការធ្វើសវនាការក៏កាន់តែយូរ

ហើយការស្វែងរកយុត្តិធម៌ក៏គេរង់ចាំយូរទៀត។ ខ្ញុំយល់អំពីការទាមទារ ការងារជាក់ស្តែងនៅទីនេះដែលទាមទារបុគ្គលិកបន្ថែមជាដើម ជាឧទាហរណ៍។ ហើយលោកចៅក្រមក៏ចូលរួមក្នុងការសម្ភាសបុគ្គលិកផងដែរ ហើយក៏ប៉ុន្តែការងារទាំងអស់នេះ គឺយើងអាចគ្រប់គ្រងចាត់ចែងទៅបាននោះទេ។

[១១:១៨:០៨]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

នៅក្នុងសេចក្តីសន្និដ្ឋានរបស់លោក លោកបានផ្សាយជាសាធារណៈ ហើយសាធារណជនក៏បានយល់ផងដែរថា ការជំនុំជម្រះវគ្គទី២នេះនឹងអាចចាប់ផ្តើមនៅចុងកុម្ភៈបាន លោកបានលើកឡើងដូច្នេះ។ នៅថ្ងៃនេះលោកស្នើសុំឲ្យមានក្រុមប្រឹក្សា ឬក៏មានក្រុមអ្នកមន្ត្រីជំនួយទី២ តែងតាំង ឬក៏ក្រុមប្រឹក្សាទី២។ ហើយចំពោះខ្ញុំៗយល់ថា បុគ្គលិកថ្មីនោះក៏មិនអាច -- មិនទាន់ត្រៀមខ្លួនរួចរាល់ជាស្រេចដែរ បើសិនជាគិតត្រឹមខែកុម្ភៈនោះក៏គាត់មិនទាន់អាចត្រៀមខ្លួនការងាររបស់គាត់រួចទៅហើយ។ តើការសន្មតរបស់ខ្ញុំនេះត្រឹមត្រូវដែរឬទេ?

**លោក នីកូឡាស គូមជែន៖**

ខ្ញុំជឿថា យើងអាចយកបុគ្គលិកនៅទីនេះតែម្តង យកមកប្រើប្រាស់នៅចុងខែកុម្ភៈ។ ចុងខែកុម្ភៈនេះគឺជាសំណើសុំពេលវេលារបស់ខ្ញុំតែប៉ុណ្ណោះ។ ហើយភាគីផ្សេងទៀតនោះ ក៏មិនទាន់លើកឡើងសំណើពេលវេលារបស់ពួកគេផងដែរ ហើយចៅក្រមក៏អាចលើកសំណើពេលវេលានេះផងដែរ។

ចំពោះបុគ្គលិកថ្មីដែលគ្រោងនឹងចូលមកធ្វើការងារនេះ អាចទទួលការណែនាំពីបុគ្គលិកនៅទីនេះបាន ហើយពួកគេប្រាកដជាអាចយល់បានទៅលើការងារហ្នឹង។ ខ្ញុំសូមបញ្ជាក់តាមបទពិសោធន៍របស់ខ្ញុំដោយសារតែខ្ញុំធ្លាប់ធ្វើការងារនៅសាលាក្តីឧក្រិដ្ឋកម្មដទៃទៀត។ នៅពេលដែលមានការកាត់បន្ថយបុគ្គលិកនៅតុលាការសេរ៉ាឡេអូន នៅអាយ.ស៊ី.ធី.វ៉ាយ, អាយ.ស៊ី.ធី.អ័រ បានបិទដំណើរការរួចទៅហើយ ដូច្នេះបទពិសោធន៍ហ្នឹងគឺថាមានបុគ្គលិកច្បាប់មួយចំនួននោះ គឺក្រោយពីមានការកាត់បន្ថយបុគ្គលិកនៅទីនោះក៏គេកំពុងតែរកការងារថ្មីមកធ្វើការ ដូច្នេះគឺថាគេក៏អាចទទួលយកការងារនៅទីនេះផងដែរ ហើយចំពោះខាងភាគីកម្ពុជាអាចជាបញ្ហាស្មុគស្មាញដោយសាររឿងនេះវាស្មុគស្មាញ។

[១១:២០:១២]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

ដោយសារតែបុគ្គលិកថ្មីពេលខ្លះទៅមិនអាចចូលរួមជួយការងារយើងច្រើនទេ ដោយសារពួក

គាត់ថ្មីខ្ញុំជឿអ៊ីចឹង។ ហើយចំពោះបុគ្គលិកច្បាប់ដែលមានលទ្ធភាពមកធ្វើការងារនៅទីនេះក៏ធ្វើយ៉ាងណាឲ្យគាត់យល់អំពីការងារទាំងអស់នេះផងដែរ។ បានន័យថា គាត់ត្រូវការពេលវេលាច្រើនឲ្យយល់ អានឲ្យអានយល់ទៅលើរឿងទាំងអស់នេះដូចដែលលោកផងដែរ។ បុគ្គលិកបច្ចុប្បន្នរបស់យើងនៅទីនេះគឺថា គាត់អាចធ្វើការងារហ្នឹងក្នុងពេលដំណើរគ្នាដោយប្រសិទ្ធភាពផងដែរ។ ដូច្នេះតើលោកទទួលស្គាល់ដែរឬទេ មិនត្រឹមតែបុគ្គលិកច្បាប់ប៉ុណ្ណោះនោះទេ ហើយគឺថាចៅក្រមហ្នឹង គឺនឹងមកបើកសវនាការចូលរួមនៅទីនេះគឺវានឹងមានប្រយោជន៍ ហើយចំពោះការយល់ឃើញរបស់លោកគឺយ៉ាងម៉េចដែរ? ហើយគឺមានក្រុមចៅក្រមមួយក្រុមតូចតែប៉ុណ្ណោះដែលទទួលខុសត្រូវលើដំណាក់កាលទី២នេះ។ ប្រសិនបើយើងបង្កើតក្រុមប្រឹក្សាទី២ ហើយយើងដំណើរការទៅក្នុងពេលដំណាលគ្នាហ្នឹង តើយ៉ាងម៉េចដែរ? ហើយតើវាអាចមានការពន្យារពេលដល់ការចេញសាលក្រមទី១ ដែរឬទេ?

[១១:២១:២៩]

**លោក ទីកូឡាស គូមជែន៖**

ខ្ញុំហាក់បីដូចជាមិនយល់សំណួរលោកស្រីចៅក្រម គឺពាក់ព័ន្ធទៅនឹងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ ឬយ៉ាងម៉េច?

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ខ្ញុំសួរអំពីបញ្ហាបុគ្គលិកដែលគ្រោងថាយកមកបម្រើការងារថ្មីនោះ។

**លោក ទីកូឡាស គូមជែន៖**

ខ្ញុំយល់ឃើញថា ការសរសេរសាលក្រមជាការងារអាទិភាព ហើយយើងស្នើសុំថា ដោយសារអង្គជំនុំជម្រះចូលរួមនៅក្នុងការសរសេរសាលក្រមនោះគឺថា ពីដំបូងគឺផែនការសវនាការគួរតែរៀបចំជាបណ្ដើរៗទៅបានន័យថា បីថ្ងៃក្នុងមួយសប្ដាហ៍។ ដូច្នេះវាមិនមានអ្វីពន្យារពេលនោះទេ។ យើងខ្ញុំមិនមែនស្នើសុំឲ្យពន្យារពេលទៅលើការសរសេរចេញសាលក្រមនោះទេ។ ការស្នើសុំរបស់យើងខ្ញុំឲ្យចាប់ផ្ដើមសវនាការវគ្គទី២ នៅចុងខែកុម្ភៈនេះ បានន័យថាវា បួនខែរួចមកហើយក្រោយពីបិទបញ្ចប់ការពិភាក្សាដេញដោល។ ដូច្នេះអ្វីដែលវាត្រូវការពេលវេលាខ្លាំងនោះគឺនៅពេលដែលយើងបកប្រែសាលក្រម និងការសម្រួលទៅលើពាក្យពេចន៍នៅក្នុងសាលក្រមទាំងអស់នោះ។ អានេះតាមដែលខ្ញុំយល់។

ចំណុចមួយដែលយើងត្រូវពិនិត្យមើលជម្រើសផ្សេង តើយើងត្រូវមើលអ្វី? តុលាការកំពូលបានលើកឡើងយ៉ាងច្បាស់ថា ការរង់ចាំ ប្រាំខែមុនពេលចាប់ផ្ដើមសំណុំរឿង០០២/០២ នោះបើសិនរង់ចាំ

ប្រាំបីខែ ដូច្នេះគឺមិនអាចទទួលយកបាននោះទេ ដោយសារតែជនជាប់ចោទ វាអាចប្រឈមនឹងសុខភាពរបស់គាត់ មិនអាចដំណើរការទៅមុខបានទៀត។ ហើយដូច្នេះហើយ សាលាដំបូងគួរតែដំណើរការសវនាការឲ្យបានលឿនតាមដែលអាចធ្វើទៅបាន។ ចំណុចនេះហើយប្រសិនបើយើងមិនដំណើរការឲ្យបានលឿនទេ គឺវាអាចសមស្របដែលយើងអាចដោះលែងជនជាប់ចោទឲ្យមានសេរីភាពបណ្ដោះអាសន្នសិន។ នៅពេលដែលបាល់កំពុងតែយើងបណ្ដើរលេងទាំងអស់គ្នា ពេលខ្លះទៅវាមិនអាចមានភាពងាយស្រួលក្នុងការដំណើរការសវនាការ ការជំនុំជម្រះរបស់យើងនោះទេ ក៏ប៉ុន្តែយើងគួរតែកែសម្រួល កែកាលវិភាគរបស់យើង ហើយយើងគួរតែមានផែនការជាក់លាក់ឲ្យបានច្បាស់លាស់ឲ្យខាងរដ្ឋបាលនេះធ្វើយ៉ាងណារកថវិកា រកបុគ្គលិក ហើយឲ្យក្រុមមេធាវីការពារក្ដីអាចរក្សាបុគ្គលិករបស់ខ្លួនមានប្រសិទ្ធភាពតាមដែលអាចធ្វើទៅបាន។

[១១:២៣:៤៦]

ហើយចំពោះពេលវេលាដែលអង្គជំនុំជម្រះលើកឡើង យើងដឹងហើយថាភាគីនោះវាត្រូវការពេលវេលាដែរនៅពេលដែលគាត់ត្រូវការប្ដឹងទៅសាទុក្ខមួយចំនួនផងដែរ។ យើងដឹងអំពីពេលវេលាកំណត់ដែលយើងត្រូវធ្វើនៅពេលណានៅពេលបណ្ដឹងសាទុក្ខ ហើយយើងមិនមែនស្នើសុំឲ្យធ្វើការបើកសវនាការវគ្គពីរនេះក្រោយពេលបណ្ដឹងសាទុក្ខនោះទេ។ យើងមិនស្នើសុំដូច្នោះឡើយ។ ការរៀបចំផែនការនេះគឺជាបញ្ហាចម្បងដែលយើងត្រូវតែសម្រេចនិងដោះស្រាយ។ ខ្ញុំដឹងថាចៅក្រមនៅទីនេះ ទាំងអស់មានសមត្ថភាពដោយសារតែគាត់យល់ដឹងរឿងក្ដី ហើយគាត់អាចយល់អំពីដំណាក់កាល០២បាន។ ក៏ប៉ុន្តែយើងមិនទាន់ដឹងថាលទ្ធភាពយើងដើរតាមផ្លូវណា។ ហើយមិនដឹងថាតើចៅក្រមទាំងអស់នៅទីនេះ អាចពីរឆ្នាំក្រោយគាត់មានលទ្ធភាព ឬមានពេលទំនេរអាចចូលរួមជំនុំជម្រះ ឬមួយក៏យ៉ាងណានោះទេ។ ដូច្នេះបើសិនជាយើងមិនដឹងលទ្ធភាពហ្នឹងទាំងអស់គ្នា យើងគួរតែរៀបចំ ផែនការពីពេលហ្នឹងទៅសម្រាប់រយៈពេលពីរឆ្នាំបន្ទាប់នេះ។ ហើយដោយយើងគិតអំពីការសរសេរសាលក្រម និងការរៀបចំការងារផ្សេងៗផងដែរ។

ក្នុងពេលដែលយើងទទួលស្គាល់ថាផែនការរបស់យើងមានឧបសគ្គជាច្រើនដែលយើងត្រូវដោះ-ស្រាយ យើងគួរតែព្យាយាមធ្វើយ៉ាងណាធ្វើឲ្យឲ្យបានលឿន ហើយមានផែនការឲ្យបានច្បាស់លាស់។ ប្រសិនបើយើងមិនមានផែនការ មិនមានសេចក្ដីសម្រេចឲ្យបានជាក់លាក់នៅក្នុងភាសារបស់យើងៗ--បានន័យថា កំពុងតែទាត់កំប៉ុងបណ្ដើរចេះតែបណ្ដើរតាមផ្លូវ ឲ្យពេលវេលាចេះតែអូសបន្លាយទៅ។

បានន័យថា នៅពេលដែលយើងនិយាយអ៊ីចឹងបានន័យថា កំប៉ុងនៅពេលដែលយើងទាត់ឲ្យវាទៅមុខពីរម៉ែត្រទៅ ក្រោយមកទៀតយើងដើរទៅដល់ យើងទាត់ចេះតែពន្យារអ៊ីចឹង។ យើងជៀសវាងការងារបែបហ្នឹង យើងត្រូវតែសម្រេចឲ្យមានផែនការមួយអាចធ្វើទៅបាន ឲ្យបានលឿន ដើម្បីឲ្យការជំនុំជម្រះធ្វើទៅបាន។ ប្រសិនបើយើងពន្យារពេលទៅទៀតនោះ បញ្ហាកាន់តែច្រើនទៀតនឹងអាចលេចចេញដដែល ប្រាំមួយខែក្រោយមក ប្រាំបីខែក្រោយនៅតែមានបញ្ហាលេចឡើងទៀតហើយ។

[១១:២៦:០៧]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

មានបញ្ហាតូចពីរ លោក គូមជែន ខ្ញុំស្នើ ខ្ញុំយល់ថាការជំនុំជម្រះលើ០២នេះវាអាចចំណាយពេលពីរ ឬក៏បីឆ្នាំតាមដែលលោកលើកឡើង។ ហើយសំណើរបស់លោកហ្នឹងគឺថា១៨ -- ១២ខែទៅ១៨ខែចំពោះសវនាការវគ្គទី២នេះ។

**លោក នីកូឡាស គូមជែន៖**

នៅនៅពេលដែលខ្ញុំនិយាយថាសវនាការនេះអាច វគ្គនេះអាចចំណាយពេលពីរទៅបីឆ្នាំនេះដោយសារតែវាមិនមែនថា យើងសម្រេចហើយយើងអាចចាប់ផ្ដើមសវនាការនៅថ្ងៃស្អែកនោះទេ ដោយសារយើងត្រូវការពេលវេលាសរសេរសាលក្រម ហើយនិងផែនការថែដន្យសង្គ្រោះបន្ទាប់អ្វីផ្សេងទៀត។ អ៊ីចឹងវាអាចមានការពន្យារពេលខ្លះដដែល។ ដូច្នេះ ចំពោះខ្ញុំ ខ្ញុំយល់ឃើញថាការជំនុំជម្រះវគ្គទី២នេះអាចចំណាយពេល១២ទៅ១៨ខែ។ ហើយខ្ញុំយល់ឃើញថាការជំនុំជម្រះ១២ទៅ១៨ខែនេះ វាអាចសម្រេចបានតែម្ដងប្រសិនបើមិនមានឧបសគ្គ ឬការពន្យារពេល ឬមិនមានឧបសគ្គពីខាងជនជាប់ចោទ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

ដើម្បីសរុបមកវិញ សហព្រះរាជអាជ្ញាស្នើឡើងថា អង្គជំនុំជម្រះសាលាដំបូងជ្រើសរើសជួលបុគ្គលិកក្រុមទី២បន្ថែមមកធ្វើការ។ ហើយយើងគួរតែចាប់ផ្ដើមសវនាការវគ្គបន្ទាប់នេះឲ្យបានលឿនតាមដែលអាចធ្វើទៅបាន។ ហើយក្នុងពេលដដែលនេះ គឺរក្សាផែនការរបស់អង្គជំនុំជម្រះតាមអ្វីដែលបានកំណត់។ ហើយគឺលោកបានបញ្ជាក់ថា យើងគួរតែឲ្យអង្គជំនុំជម្រះសាលាដំបូង គឺរក្សាការងាររបស់ខ្លួនដដែល ហើយធ្វើយ៉ាងណាគិតអំពីផែនការការជំនុំជម្រះទី២ឲ្យបានលឿនតាមដែលអាចធ្វើទៅបាន។ ហើយលោកៗលើកឡើងអ៊ីចឹង បានន័យថាយើងពេលនេះធ្វើការអត់លឿន ឬក៏យ៉ាងម៉េច?

[១១:២៨:២២]

**លោក នីកូឡាស គូមជែន៖**

យើងរីករាយណាស់ដែលយើងរៀបចំការប្រជុំនៅថ្ងៃនេះ ដើម្បីឲ្យយើងយល់ថាតើយើងគួរធ្វើអ្វីទៅមុខទៀត។ ដូច្នេះនៅពេលនេះគឺខ្ញុំលើកឡើងថា សុំឲ្យអង្គជំនុំជម្រះសាលាដំបូងចេញសេចក្ដីសម្រេចមួយឲ្យបានលឿន ថាតើធ្វើយ៉ាងម៉េចទៅលើសំណុំរឿងវគ្គ០២/០២នេះ ដើម្បីគិតប្រយោជន៍ដើម្បីបណ្ដឹងរដ្ឋប្បវេណី ជនជាប់ចោទ និងភាគីអន្តរជាតិ និងជាតិទាំងអស់គ្នា។

យើងគួរតែមានផែនការមួយច្បាស់លាស់ដើម្បីឲ្យយើងអាចបញ្ចប់ការងាររបស់យើងបាន។ ប្រសិនបើយើងនៅតែដំណើរការអត់មានធ្វើអ្វីនោះ គឺយើងនឹងចំណាយថវិកាកាន់តែច្រើនចំពោះតុលាការនេះ ហើយយើងនឹងចាយលុយអ្នកដែលគេបង់តាក់ឲ្យប្រទេសនីមួយៗនោះ គេយកលុយមកជួយយើងនោះ គឺទាំងកម្ពុជា ទាំងអន្តរជាតិ។ ហើយយើងសង្ឃឹមថា រឿងក្ដីនេះយើងមិនចាំបាច់រង់ចាំរហូតទៅដល់មានបណ្ដឹងសាទុក្ខនោះទេ ហើយក៏វាមិនចំណាយពេលសកម្មភាពយើងរហូតទៅដល់រាប់សិបឆ្នាំផងដែរ។ នេះជាកាតព្វកិច្ចរបស់យើង ដែលយើងត្រូវពិចារណានៅពេលនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណបាទ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១១:២៩:៤០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទសូមអរគុណលោកប្រធាន។ បាទ សំណួរខ្ញុំសួរទៅកាន់លោកសហព្រះរាជអាជ្ញាទាំងពីររូប។ បាទយើង -- ក្នុងកិច្ចប្រជុំយើងនេះយើងនិយាយអំពីបញ្ហាទាក់ទងទៅនឹងការចាប់ផ្ដើមកាត់សេចក្ដីបន្តទៀត។ ឧទាហរណ៍ដូចជាពីរយៈពេលដែលយើងត្រូវកំណត់ក្នុងការធ្វើសវនាការ។ ក៏ប៉ុន្តែ ខ្ញុំមានសំណួរមួយដែលត្រូវលើកឡើង ពីព្រោះថាយើងនិយាយអំពីក្រុមជំនុំជម្រះទី២។ ហើយខ្ញុំយល់ បើសិនខ្ញុំច្រឡំជួយកែខ្ញុំផង។ គឺថាឧបសម្ព័ន្ធដែលលោកភ្ជាប់ទៅនឹងសារណាចុងក្រោយរបស់លោកហ្នឹង លោកបានផ្ដល់ការចង្អុលបង្ហាញអំពីរយៈពេលនៅក្នុងការជម្រះសេចក្ដី។ ហើយការចង្អុលបង្ហាញនេះមានមូលដ្ឋានលើការដែលលោកសន្មតថានៅក្នុងក្រុមជំនុំជម្រះទី២នេះ គឺមានចៅក្រមដដែល ហើយនិងជាការបន្តសវនាការពីមុនៗមកទេ។ ហើយមានក្រុមអ្នកពិនិត្យខាងភស្តុតាងជាដើម។

សំណួរខ្ញុំដូចតទៅនេះ តើជាលក្ខណៈទូទៅ តើលោកមានការយល់ឃើញយ៉ាងណាដែរអំពីផលប៉ះពាល់នៅក្នុងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២ ទៅលើការចង្អុលបង្ហាញរយៈពេលវេលាដែល

លោកបានផ្តល់ជូននេះ។ ខ្ញុំសន្មតថាយើងប្រហែលមិនដឹងថារយៈពេលមួយឆ្នាំប្រាំបីខែ ឬក៏ពីរឆ្នាំនោះទេ ខ្ញុំគិតថាយូរជាងហ្នឹង។ ហើយជាការពិតណាស់ដែលអស់លោកទាំងអស់គ្នាព្រួយបារម្ភអំពីការផ្តល់ជំនួយរបស់អ្នកផ្តល់ជំនួយទាំងអស់ហ្នឹង។ ក៏ប៉ុន្តែយើងអាចសួរសំណួរផងដែរថា តើផលប្រយោជន៍ក្នុងការចាប់ផ្តើមឲ្យលឿនបំផុតក្នុងការជម្រះសេចក្តីលើកទី២ ជាមួយនឹងក្រុមប្រឹក្សាទី២ តើតាមការពិតទៅយើងអាចចំណេញពេលពីរបីខែតែប៉ុណ្ណោះនោះ តើវាអាចធ្វើឲ្យការកាត់ក្តីហ្នឹងចំណាយពេលយូរលើសហ្នឹងទៅទៀត បើធៀបនឹងពេលវេលាដែលលោកគិតថាអាចចំណេញនៅក្នុងការបង្កើតក្រុមជំនុំជម្រះទី២។

[១១:៣២:២១]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណ ហើយខ្ញុំសូមថ្លែងអំណរគុណដែលខ្ញុំមានឱកាសដើម្បីបញ្ជាក់។ ដើម្បីបញ្ជាក់ឲ្យច្បាស់គឺថាអ្វីដែលស្នើ គឺថាវាជាការល្អ ជាការមានប្រយោជន៍ដែលយើងធ្វើការជំនុំជម្រះសំណុំរឿង ០០២/០២ គឺថាភស្តុតាងពីសំណុំរឿង០០២/០១ ដូចគ្នានៅក្នុងដីកាដំណោះស្រាយ ឬក៏ដីកាបញ្ជូនរឿងទៅជំនុំជម្រះ គឺថាភស្តុតាងទាំងអស់ដែលបានសួរដេញដោលដោយគ្រប់ភាគីទាំងអស់ហ្នឹងគឺបានន័យថា ឯកសារដែលយើងបានដាក់នៅក្នុងកំណត់ត្រានៅក្នុងសំណុំរឿង០១០១ ត្រូវបញ្ជូនទៅសំណុំរឿង០០២/០២។ ដូច្នេះយើងសន្មតថាភស្តុតាងទាំងអស់នេះគឺវាមានទំនាក់ទំនងក៏ដូចជាតួនាទីរបស់ជនជាប់ចោទព្រមទាំងអំណាចរបស់ជនជាប់ចោទដែលយើងគិតថា យើងមិនចាំបាច់ត្រូវធ្វើការកោះហៅយកមកសួរដេញដោលបន្ថែមទៀតទេ។ ហេតុដូច្នេះហើយទើបយើងគាំទ្រដល់ក្រុមប្រឹក្សាជំនុំជម្រះបច្ចុប្បន្ន ហើយអាចបន្តទៅសំណុំរឿង០០២/០២។

ប៉ុន្តែជាជម្រើសមួយទៀត ប្រសិនបើថាវាមិនអាចធ្វើទៅបាននោះទេ គឺបានន័យថាក្រុមប្រឹក្សាជំនុំជម្រះបច្ចុប្បន្នមិនអាចបន្តទៅមុខទៀតទេ គឺយើងត្រូវការត្រូវការក្រុមប្រឹក្សាជំនុំជម្រះទី២ ដែលមានចៅក្រមថ្មី។ ប៉ុន្តែខ្ញុំគិតថាវានឹងមានការពន្យារពេល ប៉ុន្តែការពន្យារពេលហ្នឹងតាមការយល់ឃើញរបស់ខ្ញុំ គឺពួកគេត្រូវពឹងផ្អែកទៅលើភស្តុតាងនៅក្នុងសំណុំរឿង០០២/០១។ ប៉ុន្តែខ្ញុំមិនអាចផ្តល់តួលេខឲ្យបានច្បាស់លាស់ទាក់ទងទៅនឹងបញ្ហានោះទេ។ ប៉ុន្តែយើងគិតថាវាមានអាចមាន២៤០០០ទំព័រជាងនៃឯកសារទាំងអស់ដែលត្រូវការអាន។ ដូច្នេះ អានេះគឺប្រហែលជា២៤០.០០០ទំព័រជាងដែលយើងត្រូវអាន។

[១១:៣៤:១៣]

ដូច្នេះខ្ញុំគិតថាវាមានប្រសិទ្ធភាពល្អជាងប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះរក្សានូវសមាជិកនៃក្រុមប្រឹក្សាបច្ចុប្បន្ន ឬក៏រក្សាឲ្យបានច្រើនបំផុតនូវសមាជិកក្រុមប្រឹក្សាបច្ចុប្បន្នហ្នឹង ដើម្បីបន្តឲ្យបានឆាប់រហ័ស។ ហើយធ្វើការជំនុំជម្រះទៅលើបទចោទដែលមាននៅក្នុងដីកាដំណោះស្រាយ ហើយរក្សានូវទាំងមេធាវីការពារក្តី ទាំងក្រុមប្រឹក្សាជំនុំជម្រះទាំងអស់ហ្នឹងគឺវាជាការល្អ។

ខ្ញុំសង្ឃឹមថា ខ្ញុំបានឆ្លើយទៅនឹងចម្លើយរបស់លោកចៅក្រម។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសហព្រះរាជអាជ្ញាអន្តរជាតិ។ ខ្ញុំមានសំណួរមួយពីរចំពោះលោកដែរ។ ខ្ញុំបានស្តាប់នូវចម្លើយរបស់លោក លោកបានឆ្លើយបំភ្លឺថា បញ្ហាដែលមិនអាចតែងតាំងជាសមាសភាពជាក្រុមប្រឹក្សាជំនុំជម្រះទី២ បានចេញពីការិយាល័យសហចៅក្រម -- សហព្រះរាជអាជ្ញា នៅសហព្រះរាជអាជ្ញាបម្រុងអន្តរជាតិគ្មាន ហើយសហព្រះរាជអាជ្ញាបម្រុងជាតិហ្នឹងមានបញ្ហាសុខភាព បញ្ហាជំងឺមិនអាច -- ទំនងមិនអាចជាបន្តក្នុងការបំពេញការងារក្នុងរយៈពេលឆាប់ៗនេះបានទេ។ ហើយបញ្ហាទី២ គឺលោកបានបញ្ជាក់ថា គឺមិនអាចបាននោះ ជាទិដ្ឋភាពផ្លូវច្បាប់ មានទំនាស់ផលប្រយោជន៍ដោយសារបេសកកម្មនេះ អង្គជំនុំជម្រះសាលាកំពូលបានចង្អុលបង្ហាញមកខ្លួនខ្ញុំផ្ទាល់ ដែលជាប្រធានអង្គជំនុំជម្រះសាលាដំបូង ក្នុងការកោះអញ្ជើញចៅក្រមបម្រុងនៅ អ.វ.ត.ក ទាំងជាតិ និងអន្តរជាតិដើម្បីបង្កើតឡើងនៅក្រុមប្រឹក្សាជំនុំជម្រះទី២ សម្រាប់អង្គជំនុំជម្រះសាលាដំបូង។

[១១:៣៦:០៧]

សំណួរ ខ្ញុំសួរថា ប្រសិនបើខ្ញុំធ្វើការកោះអញ្ជើញបណ្តាចៅក្រមបម្រុងជាតិ និងអន្តរជាតិពីការិយាល័យសហចៅក្រមស៊ើបអង្កេត ពីអង្គបុរេជំនុំជម្រះ ឬក៏ពីតុលាការកំពូល ដែលបណ្តាចៅក្រមទាំងអស់នោះ បានចូលរួមនៅក្នុងនីតិវិធីស៊ើបអង្កេត ឬក៏នីតិវិធីនៃការពិនិត្យលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចផ្សេងៗរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ឬក៏បានពិនិត្យ ចូលរួមពិនិត្យលើសេចក្តីសម្រេចផ្សេងៗរបស់អង្គជំនុំជម្រះសាលាដំបូង ដូចជាចៅក្រមបម្រុងនៅតុលាការកំពូលជាដើម។ សំណួរសួរថា បើយើងខ្ញុំអញ្ជើញគាត់ឲ្យចូលរួមនៅក្នុងអង្គជំនុំជម្រះសាលាដំបូងទី២ ដែលគ្រោងនឹងបង្កើតឡើងតាមសេចក្តីអនុសាសន៍របស់តុលាការកំពូលនេះ សំណួរសួរថា តើអាចប្រព្រឹត្តទៅបានទេ? តើវាមានទំនាស់ផលប្រយោជន៍ដូចគ្នានឹងតួនាទីរបស់សហព្រះរាជអាជ្ញាបម្រុងដែរឬទេ?

[១១:៣៧:៤២]

**លោកស្រី ជា លាង៖**

ចាស ខ្ញុំតាមពិតទាក់ទងនឹងព្រះរាជអាជ្ញាអន្តរជាតិ ហើយទាក់ទងនឹងអំពីទំនាស់ ហើយប៉ុន្តែខ្ញុំដូចជាមិនទាន់ច្បាស់ខ្លួនឯងថា អំពីទំនាស់ផលប្រយោជន៍នេះចំពោះតុលាការអន្តរជាតិទេ។ ប៉ុន្តែចំពោះជាតិដែលជាសហព្រះរាជអាជ្ញា ទោះបីគាត់ជាមានតួនាទីជាសហព្រះរាជអាជ្ញានៅក្នុងពេលបច្ចុប្បន្ន បើសិនជាអង្គជំនុំជម្រះកោះហៅគាត់ឲ្យមកជាចៅក្រមក្នុងជំនុំជម្រះអង្គទី២នេះមិនមានបញ្ហាទេ ដោយសារនៅក្នុងច្បាប់កម្ពុជាមិនមានការហាមឃាត់ក្នុងករណីគាត់ដែលជាព្រះរាជអាជ្ញា និងអាចទៅជាចៅក្រម ចៅក្រមទៅព្រះរាជអាជ្ញាបាន។ អានេះៗដោយសារច្បាប់យើងមានចែងច្បាស់លាស់តែម្តង។ ដូច្នេះវាមិនមានបញ្ហាអីទេ។ ប៉ុន្តែការលើកឡើងដំបូងរបស់ខ្ញុំពាក់ព័ន្ធអំពីបញ្ហាសុខភាពនេះ ប្រសិនបើជាករណីដែលអង្គជំនុំជម្រះសាលាដំបូងសម្រេចថា នឹងមានការបង្កើតនូវអង្គជំនុំជម្រះទី២នេះ ការងារផ្នែករដ្ឋបាលនឹងអាចទំនាក់ទំនងស្នើចៅក្រមៗ ឬក៏ព្រះរាជអាជ្ញាណាមួយដែលតែងតាំងជាចៅក្រមសម្រាប់អង្គជំនុំជម្រះទី២នេះបាន។

[១១:៣៩:០១]

ខ្ញុំខ្លួនឯង តែមិនទាន់ច្បាស់អំពីបញ្ហាចៅក្រម អំ! ព្រះរាជអាជ្ញាអន្តរជាតិ ដោយសារនៅអន្តរជាតិនោះ គាត់អាចផ្លាស់ប្តូរទៅតាមចៅក្រម ឬក៏ព្រះរាជអាជ្ញាអំពីទំនាស់ផលប្រយោជន៍ ហើយការអត់មាននេះ តើវាមានបញ្ហាក្នុងការតែងតាំងក្នុងអង្គជំនុំជម្រះថ្មីដែរឬទេ។ បញ្ហានេះដោយសារបើសិនជាមានការបង្កើតនូវអង្គជំនុំជម្រះថ្មីមួយដែលហៅថា អង្គជំនុំជម្រះទី២ នេះគឺផ្នែកអង្គការសហប្រជាជាតិគាត់មិនបាច់ដាក់ជាព្រះរាជអាជ្ញាបម្រុងក៏បានដែរ គាត់អាចបញ្ជូនឈ្មោះដែលជាចៅក្រមតែម្តងមកក៏បានក្នុងនាមជាចៅក្រមចំតែម្តងក្នុងអង្គជំនុំជម្រះទី២នេះ អាហ្នឹង ប៉ុន្តែវាជាបុគ្គលមួយប៉ះពាល់នឹងផលប្រយោជន៍ ហើយខ្ញុំយល់ឃើញខ្លួនឯងថា ក្នុងការដែលតែងតាំងនៅចៅក្រមថ្មីមួយ ដែលជាថ្មីសន្លាងតែម្តង វាមានការលំបាកច្រើនក្នុងការជំរុញដំណើរការឲ្យនីតិវិធីក្នុងសំណុំរឿង០០២/០២ នេះទៅមុខឲ្យបានលឿនដែល ដូចដែលតុលាការកំពូលចង្អុលបង្ហាញ ក៏ដូចជាសំណើរបស់ព្រះរាជអាជ្ញាចង់ឲ្យសវនាការក្នុងសំណុំរឿង០០២/០២នេះឲ្យបានលឿន ហើយនិងចាប់ផ្តើមឲ្យឆាប់រហ័ស ដូចផលវិបាកនៅខាងសហការីរបស់ខ្ញុំលើកឡើងអ៊ីចឹង ថាមូលហេតុផ្សេងៗដែលយើងបានពិចារណាគ្នាថា នឹងអាចជួបនូវផលវិបាកអំពី យើងនឹងអាច -- មិនអាចមើលឃើញ។ ដូច្នេះ ខ្ញុំគិតថាចំណុចទី១ ទាល់តែសាលាដំបូងនេះ -- ខ្ញុំនិយាយថានេះហួសហាក់ដូចជានឹងហួសនឹងអំពីការនិយាយបន្តិចហើយ ប៉ុន្តែខ្ញុំចង់

សំណូមពរទៅវិញ ថាគួរតែអង្គជំនុំជម្រះចេញសេចក្តីសម្រេចដំណាក់កាលទី១ ដែលហៅថាដំណាក់កាលហ្នឹង បង្កើតឲ្យមានអង្គជំនុំទី២ហ្នឹងដែរអត់? ប្រសិនបើជាមានការបង្កើតនោះ រដ្ឋបាលត្រូវតែចាប់ផ្តើមធ្វើការងារអំពីការតែងតាំងចៅក្រម តើចៅក្រមបច្ចុប្បន្នអាចជាចៅក្រមហ្នឹងបាននៅក្នុងអង្គជំនុំជម្រះទី២ហ្នឹងបានដែរអត់? យើងអាចពិចារណាគ្នា និងពិភាក្សាគ្នាបាន។

[១១:៤១:០៤]

ហើយចំណុចមួយទៀត ក៏ផ្នែក ពិនិត្យទៅលើផ្នែករបៀបរៀបហ្នឹង ក៏យើងអាចពិចារណាបានដែរ ប៉ុន្តែត្រូវគិតអំពីថាតើផលវិបាកនៅការិយាល័យផ្សេងៗ ដែលជាចៅក្រមបម្រុងដែលគេកំពុងតែបំពេញការងាររបស់គេនៅក្នុងការិយាល័យរបស់គេ យើងដករបស់គេមកថែមទៀត យកមកឲ្យធ្វើការនៅអង្គជំនុំជម្រះទី២នេះ ក៏វាប៉ះពាល់ទៅលើផ្នែកបុគ្គលិក។ ចៅក្រមគាត់ក៏ជាបុគ្គលិកមួយនៅក្នុងការិយាល័យរបស់គេដែរ។ ឧទាហរណ៍ថាបម្រុងនៅតុលាការកំពូល កាលណាមានការពិភាក្សាចេញសេចក្តីសម្រេចអីមួយ ធម្មតាវាមានការប្រជុំ និងពិគ្រោះយោបល់អីទាំងអស់គ្នា។ អ៊ីចឹងការបាត់បង់នូវរបស់មនុស្សគេមួយនៅក្នុងការិយាល័យហ្នឹង។ អានេះវាជាបញ្ហាមួយ។ តើពិចារណាដល់ចំណុចហ្នឹង តើប៉ះពាល់ទេអំពីការិយាល័យផ្សេងៗទៀត? ចំពោះការិយាល័យសហព្រះរាជអាជ្ញា ទោះបីបម្រុងគាត់មិនបានចូលជាអចិន្ត្រៃយ៍ដូចនៅខាងអង្គជំនុំជម្រះមែន ប៉ុន្តែខាងអង្គជំនុំជម្រះ ខ្ញុំជឿថាអាចនឹងមានការប៉ះពាល់ខ្លះៗអំពីបញ្ហាហ្នឹង។ ដូចជាតាមអ្វីដែលខ្ញុំដឹង ដូចជានៅអង្គបុរេជំនុំជម្រះ កាលហ្នឹង បម្រុងគាត់ចូលរួមក្នុងការជួយធ្វើការងារហ្នឹងដែរសព្វថ្ងៃនេះ។ ដូច្នេះ យើងពិចារណាអំពីបញ្ហានេះ។

អ៊ីចឹងហើយបានខ្ញុំថាការបង្កើត យើងសម្រេចថាឲ្យវាមានអត់ឥឡូវហ្នឹង? ថាបើសិនជាមានយើងត្រូវតែចាប់ដំណើរការ ថាត្រូវការតែងតាំងដោយចៅក្រមអី។ អ្វីដែលសារណារបស់យើងដែលបានដាក់នៅក្នុងនេះ តាំងពីម្សិលមិញក៏ដូចជាប៉ុន្មានថ្ងៃមុននេះកន្លងមកហ្នឹង គឺពីថ្ងៃ១០ហ្នឹងដែរ ហើយនិងពីមុនហ្នឹងទៀត គឺយើងបានសំណូមពរទៅអង្គជំនុំជម្រះទេ អំពីផែនការថាអង្គជំនុំជម្រះសំណុំរឿងសវនាការហ្នឹងវាអាចត្រូវការរយៈពេល ការប៉ាន់ស្មានរបស់ភាគីតែខ្ញុំ ខាងម្នាក់ទេ គឺ៩០ថ្ងៃ។ អានេះជាអ្វីដែលយើងបានស្នើ អ្វីដែលយើងមានការឲ្យអង្គជំនុំជម្រះបានដឹង។ ដូច្នេះអានេះជាសំណូមពររបស់ខ្ញុំភាគីម្នាក់ ដូច្នេះអាចភាគីផ្សេងៗទៀត គេអាចមានសំណូមពរដែរ។ ដូច្នេះ អង្គជំនុំជម្រះអាចពិចារណានិងសម្រេចក្រោយ។ អ៊ីចឹងខ្ញុំនៅតែជំហានទី១ គឺថាអង្គជំនុំជម្រះសម្រេចសិន ថាមានសវនាការហ្នឹងដែរអត់។ អានេះជាចំណុចទី១។ តែអ្វីដែលខ្ញុំបានដឹងពីព្រឹកមកទល់ពេលនេះ ខ្ញុំគិតថាការបង្កើតតាម

អ្វីដែលរដ្ឋបាលបានឆ្លើយ ហាក់ដូចជាអត់មានបញ្ហាអីទេ។ រដ្ឋបាលក៏គាត់គាំទ្រ ផ្នែកហិរញ្ញវត្ថុ ក៏គាំទ្រ អំ! បុគ្គលិក ប៉ុន្តែបុគ្គលិកជាតិ ខ្ញុំនៅតែមិនទាន់ច្បាស់ចំពោះខ្លួនឯង។ ដោយសារថាថវិកាសង្គ្រោះ អំមិញ ដែលខ្ញុំបានស្តាប់នេះ! គឺគាត់ ការលើកឡើង ភាគីខាងសហការីខ្ញុំណ៎ះ គាត់លើកឡើងហ្នឹង ប្រាំជាតិ និងប្រាំអន្តរជាតិ ឆ្លើយទៅប្រាំអន្តរជាតិហ្នឹង ចំពោះថវិកាសង្គ្រោះ ប៉ុន្តែជាតិ ខ្ញុំនៅតែអត់ទាន់ច្បាស់ខ្លួនឯងអ៊ីចឹង នៅពេលដែលធ្វើសំណើទៅ នឹងពិចារណា។ ដូច្នេះ ថាតើពិចារណាហ្នឹងម៉េច? ទាល់តែស៊ីជម្រៅការងារបច្ចេកទេសបុគ្គលិកហ្នឹងយកមកធ្វើអី។ អានេះទាល់តែពិភាក្សាស៊ីជម្រៅឱ្យច្បាស់លាស់។ បើសិនជាធ្វើសំណើទៅ អ្ហែ! ពិចារណាមិនសមហេតុផល មិនឱ្យ។ អានេះជាបញ្ហាមួយដែលយើងមិនអាចដំណើរការបាន។ អានេះខ្ញុំសរុបមកវិញ។ ហើយបញ្ហាទំនាស់ផ្សេងៗទៀត អំពីទាក់ទងទៅនឹងសហព្រះរាជអាជ្ញាអន្តរជាតិ បើសិនជាសហការីរបស់ខ្ញុំ គាត់អាចនឹងជួយឆ្លើយបាន។ សូមឱ្យគាត់ជួយឆ្លើយអំពីបញ្ហានេះចាស។

[១១:៤៤:០៧]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ហើយមុននឹងជូនវេទិកាទៅសហព្រះរាជអាជ្ញាអន្តរជាតិ ខ្ញុំសូមបញ្ជាក់នូវសំណួររបស់ខ្ញុំឡើងវិញ។ ខ្ញុំមិនបានសួរអំពីថាសហព្រះរាជអាជ្ញាហ្នឹង អាចចូលរួមនៅក្នុងក្រុមប្រឹក្សាទី២ទេ ព្រោះសហព្រះរាជអាជ្ញាបានឆ្លើយរួចហើយ អំពីបញ្ហាគ្មានសហព្រះរាជអាជ្ញាបម្រុងអន្តរជាតិ ហើយនិងសហព្រះរាជអាជ្ញាបម្រុងជាតិគាត់មានបញ្ហាសុខភាព ប៉ុន្តែគាត់បានប្រើពាក្យមួយថា “ទំនាស់ផលប្រយោជន៍”។ នៅក្នុងច្បាប់ជាតិកម្ពុជា បានចែងច្បាស់អំពីវិសមត្ថភាព រវាងតួនាទីរបស់ព្រះរាជអាជ្ញាក្នុងការចាត់ការសំណុំរឿងមិនអាចមកជំនុំជម្រះរឿងក្តីដដែលនោះបានទេ។ ក្រុមស៊ើបអង្កេត កាលណាគាត់ចូលរួមជាចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿងនោះហើយ មិនអាចមកចូលរួមជំនុំជម្រះរឿងក្តីដែលគាត់បានចូលរួមស៊ើបអង្កេតទេ។ រឿងក្តីដូចគ្នា សភាស៊ើបសួរដូចគ្នា បើគាត់នៅសភាស៊ើបសួរ ហើយគាត់បានចូលសម្រេច ពិនិត្យសម្រេចលើសំណុំរឿងក្តីនោះហើយ គាត់មិនអាចចូលរួមជាចៅក្រមជំនុំជម្រះនៅក្នុងរឿងក្តីនោះទេ។ ឥឡូវនេះ ថែមទាំងតុលាការកំពូលទៀត វារៀងចម្លែកបន្តិច ពីព្រោះខាងកម្ពុជាមានតែបញ្ជូនពីក្រោមឡើងទៅលើចៅក្រម អត់មានមកពីលើមកក្រោមទេ។ ប៉ុន្តែឧទាហរណ៍ថា ចៅក្រមបម្រុងដែលបាននៅធ្វើការនៅតុលាការកំពូលនោះគាត់បានចូលពិនិត្យសម្រេច ពិភាក្សាលើសេចក្តីសម្រេចនានាដែលប្រឆាំងនឹងកិច្ចដំណើរការរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានសម្រេច

កន្លងមកនេះរួចហើយ។ សំណួរសួរថា ស្ថានភាពវិសមត្ថភាពនេះ វាទំនាស់ផលប្រយោជន៍បែបហ្នឹង ជាបែបបម្រុង មិនមែនជាបែបជាពេញសិទ្ធិទេ។ លក្ខណៈបែបនេះ សួរថាតើអាចឲ្យខ្ញុំនេះពិនិត្យពិចារណាតែងតាំងគាត់ធ្វើជាចៅក្រមពេញសិទ្ធិ ដើម្បីដំណើរការនូវជាចៅក្រមប្រឹក្សានៅក្នុងក្រុមប្រឹក្សាជំនុំជម្រះទី២ នៃសាលាដំបូងដែរឬទេ? នេះជាបញ្ហាសំណួរគឺសួរបញ្ហាប៉ុណ្ណឹងទេ បញ្ហាដទៃទៀតអត់ចង់បានទេដោយសារមូលហេតុអី?

ឥឡូវនេះ យើងដាក់បញ្ហាជាបញ្ហាចម្បង ជាបញ្ហាបន្ទាន់ ដំបូងបំផុត ដើម្បីពិភាក្សានេះ ពិនិត្យលទ្ធភាពថា តើខ្ញុំក្នុងនាមប្រធានអង្គជំនុំជម្រះសាលាដំបូងហ្នឹង ដោយសារមតិយោបល់ទាំងអស់ហ្នឹងផ្នែកខាងផ្លូវច្បាប់ ផ្នែកខាងរដ្ឋបាល ផ្នែកខាងហិរញ្ញវត្ថុ ផ្នែកខាងបច្ចេកទេសនៅក្នុងកិច្ចដំណើរការហ្នឹងសួរថាតើខ្ញុំនេះ! បើគេមានលទ្ធភាពអាចបង្កើត ឬក៏ខ្ញុំគ្មានលទ្ធភាពអាចបង្កើតនូវក្រុមប្រឹក្សាទី២ទេ។ នេះជាបញ្ហាដែលខ្ញុំមិនអាចឆ្លើយថា បានទេ ថាឥឡូវនេះបង្កើតទេ ពីព្រោះកំពុងតែពិនិត្យលទ្ធភាពស្តាប់មតិយោបល់ភាគីឲ្យផ្តល់យោបល់ ឲ្យរដ្ឋបាលផ្តល់យោបល់ ថាតើស្ថានភាពនេះ ខ្ញុំអាចបង្កើត លទ្ធភាពបង្កើតបានឬអត់? អ៊ីចឹងខ្ញុំស្តាប់មតិយោបល់នេះ ដើម្បីនឹងផ្ទៀងផ្ទាត់មើលថា តើខ្ញុំអាចពិចារណាបញ្ហានេះ ដើម្បីលើកសំណើទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដើម្បីតែងតាំងសមាសភាពទាំងអស់នេះមកធ្វើជាចៅក្រមនៃចៅក្រមពេញសិទ្ធិនៅក្នុងដំណើរជំនុំជម្រះទី២ នៃអង្គជំនុំជម្រះសាលាដំបូងដែរឬទេ? រួមទាំងតែងតាំងបុគ្គលិកណាមួយជាប្រធានអង្គជំនុំជម្រះសាលាដំបូងទី២នេះ ក្រុមប្រឹក្សាជំនុំជម្រះសាលាដំបូងទី២នេះទៀតផង។ នេះគឺពិនិត្យលទ្ធភាពទេ មិនទាន់ប៉ានសម្រេចយ៉ាងម៉េចទេ ទុកលទ្ធភាពនេះដើម្បីពិនិត្យពិចារណាទៀត បន្ទាប់ពីស្តាប់មតិយោបល់របស់ភាគី។ សូមលោកសហព្រះរាជអាជ្ញាអន្តរជាតិជ្រាប គឺសុំតែបញ្ហាវិសមត្ថភាពទេ ថាតើរបៀបនេះតើយើងអាចតែងតាំងបានឬក៏អត់?

[១១:៤៧:៤៩]

**លោកស្រី ជា លាង៖**

លោកប្រធាន ដើម្បីមុនឲ្យទៅគាត់ ខ្ញុំចង់បញ្ជាក់បន្តិចទេអំពីបញ្ហាទំនាស់ផលប្រយោជន៍ គាត់នឹងបកស្រាយអំពីព្រះរាជអាជ្ញានេះចុះ។ ប៉ុន្តែយោបល់របស់ខ្ញុំ អ្វីដែលខ្ញុំយល់ដឹងអំពីតុលាការនេះចំពោះបម្រុងនេះ អ្វីកន្លងមក គឺតាមដែលខ្ញុំដឹងគឺគាត់គ្រាន់តែឲ្យយោបល់ទេ គាត់អត់មានសិទ្ធិក្នុងការសម្រេចទេ។ ដូច្នេះ ទោះបីចេញជាសាលក្រម ចេញអីហ្នឹងក៏ដោយ គាត់ឲ្យយោបល់នៅក្នុងប្រជុំ នៅក្នុងការណ៍អីផ្សេងៗ គាត់ឲ្យយោបល់។ ដូច្នេះថាគាត់ទំនាស់ផលប្រយោជន៍ដូចជាមិនមាន ប៉ុន្តែមាន

ចំណុចមួយដែលខ្ញុំមានការកត់សម្គាល់ទៅលើចៅក្រមស៊ើបអង្កេតបម្រុង។ ប៉ុន្តែសួរថា បម្រុងសព្វថ្ងៃគាត់ចូលធ្វើការទេ? វាអត់ទៅទៀត ថាទំនាស់ផលប្រយោជន៍ ថាគាត់អង្កេតអាហ្នឹងហើយ យករឿងហ្នឹងមក ថាគាត់បានដឹងរឿងហ្នឹង។ តែចំពោះចៅក្រមផ្សេងៗទៀត ដូចជាតុលាការកំពូល ដូចជាសាលាអង្គបុរេ ដូចជាសាលានេះ គាត់ដូចជាគ្រាន់ឱ្យយោបល់។ ដូច្នេះខ្ញុំថាទំនាស់ផលប្រយោជន៍អំពី -- អាហ្នឹងអាស្រ័យទៅលើចៅក្រមទេ អំពីថារើសរើហ្សេរពីសាលាដំបូង ភី.ធី.ស៊ី, អូ.ស៊ី.អាយ.ជេ, អូ.ស៊ី អីហ្នឹងគឺជាថាតើអ្វីដែលគាត់បានធ្វើ អ្វីដែលគាត់មិនបានធ្វើ អ្វីដែលគាត់មានសិទ្ធិសម្រេច អ្វីដែលគាត់មិនមានសិទ្ធិសម្រេច។ ដោយឡែកទំនាស់នេះ ខ្ញុំសូមឱ្យអន្តរជាតិគាត់ឆ្លើយចាស។

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមបញ្ជាក់បន្ថែមបន្តិចមុននឹងឆ្លើយ។ លោកសហព្រះរាជអាជ្ញាអន្តរជាតិ សេចក្តីសម្រេចរបស់តុលាការកំពូលបានសម្រេចផ្តល់សមត្ថកិច្ច សិទ្ធិអំណាចឱ្យខ្ញុំបង្កើតអង្គជំនុំជម្រះសាលាដំបូងទី២ ដោយផ្អែកលើមូលដ្ឋានធនធានដែលមានស្រាប់បច្ចុប្បន្ន! ឱ្យច្បាស់។

[១១:៤៩:៣៩]

**លោក ឃ្លុត វ៉ូសាន់ហោក៖**

លោកប្រធាន ខ្ញុំព្យាយាមឆ្លើយតបទៅនឹងសំណួររបស់លោកប្រធាន ថាតើចៅក្រមមកពីអង្គជំនុំជម្រះដទៃទៀតហ្នឹងមានសមត្ថកិច្ចអាចចូលរួមនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះទី២ បានដែរឬអត់នោះ។ ខ្ញុំគិតថា ពាក្យដែលខ្ញុំប្រើប្រាស់គឺថា ខ្ញុំប្រើប្រាស់ពាក្យថា "ទំនាស់ផលប្រយោជន៍" ប៉ុន្តែប្រសិនបើតាមច្បាប់អន្តរជាតិ គឺថាតើបុគ្គលនោះមានការលម្អៀងដែរឬអត់ ដែលធ្វើឱ្យគាត់មិនអាចមានលទ្ធភាព ឬក៏មិនមានសមត្ថភាពចូលរួមនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះ។ ផ្អែកទៅលើអ្វីដែលលោកប្រធានបាននិយាយ ខ្ញុំគិតថា វាមានភាពខុសគ្នារវាងសហចៅក្រមស៊ើបអង្កេត ហើយនិងអង្គជំនុំជម្រះដទៃទៀត។ ការពិតទៅដែលថាចៅក្រមមានសិទ្ធិសម្រេចនៅក្នុងសំណុំរឿងនោះគឺថាជាតួនាទីរបស់ចៅក្រម ប៉ុន្តែមិនមែនបានន័យថាចៅក្រមនោះមានភាពលម្អៀងនោះឡើយបើតាមទស្សនៈរបស់ខ្ញុំ។ ឧទាហរណ៍ដូចជាតុលាការកំពូលបានធ្វើការសម្រេចទៅលើបណ្តឹងសាទុក្ខបន្ទាន់បង្ហំ មិនមែនបានន័យថាចៅក្រមដែលចូលរួមនៅក្នុងការសម្រេចនោះមានភាពលម្អៀង ឬក៏មិនមានសមត្ថភាព ឬក៏មិនមានលទ្ធភាពចូលរួមនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះនោះទេ។ ដូច្នេះបានន័យថា ចៅក្រមមួយរូបគាត់សម្រេចទៅលើសេចក្តី ទៅលើសំណុំរឿងមួយមិនមែនមានន័យថាគាត់មិនអាចចូលរួមនៅក្នុងសំណុំមួយបន្តទៀតបាននោះទេ។ ឧទាហរណ៍

ដូចជាករណីមួយទៀត ថាតើវាមានការជំនុំជម្រះត្រឹមត្រូវឬក៏អត់នោះ គឺគេថាចៅក្រមមិនមែនមានន័យថាចៅក្រមគាត់ចូលរួមជំនុំជម្រះហើយគាត់មិនមានសមត្ថភាពក្នុងការចូលរួមបន្តនោះទេ។ ដូច្នេះចំពោះអង្គជំនុំជម្រះសាលាដំបូង និងតុលាការកំពូលដែលជាបញ្ហាជំនុំជម្រះចុងក្រោយ គឺបានន័យថាយើងត្រូវបង្ហាញឲ្យហួសពីវិមតិសង្ស័យទៅលើជនជាប់ចោទ។ ខ្ញុំគិតថាវាមានភាពខុសគ្នាមួយរវាងចៅក្រមដែលបានចូលរួមនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងការចេញដីកាដំណោះស្រាយ។ នៅក្នុងដីកាដំណោះស្រាយ គឺជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ជាដីកាផ្តន្ទាទោស។ ដូច្នេះហើយខ្ញុំឃើញថាវាមានបញ្ហាដែលយើងគួរសង្កេតឃើញអំពីបញ្ហានេះ ដែលថាអាចមានភាពលម្អៀងរវាងចៅក្រមនៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលអាចមានទំនាស់ផលប្រយោជន៍។ ប៉ុន្តែ ចំពោះចៅក្រមនៅអង្គជំនុំជម្រះនៅអង្គជំនុំជម្រះដទៃទៀតដូចជាមិនមានបញ្ហាអ្វីជាធ្ងន់ធ្ងរនោះទេ។

[១១:៥២:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់នូវមតិយោបល់របស់សហព្រះរាជអាជ្ញាលើបញ្ហានេះ។ បញ្ហាដែលមានការបារម្ភនោះគឺថាអ៊ីចេះទេ ប្រសិនបើយើងខ្ញុំជាអង្គជំនុំជម្រះពិនិត្យលទ្ធភាពនេះមិនអាចទៅរួច ហើយត្រូវស្នើសុំទៅតាមរយៈរដ្ឋបាលទៅក្រុមប្រឹក្សាអង្គចៅក្រម ឬឲ្យទៅពិភាក្សាលើការបង្កើននូវចំនួនសមាសភាពចៅក្រមថ្មីបន្ថែមទៀត ខ្ញុំមើលទៅវាប្រឈមជាមួយនឹងបទប្បញ្ញត្តិដែលចែងនៅក្នុងមាត្រា៣ នៃកិច្ចព្រមព្រៀងដែលមាត្រា៣នេះ ខ្ញុំបាននិយាយពីព្រឹកហើយ គឺបានកំណត់យ៉ាងច្បាស់លាស់នូវការស្នើសុំការតែងតាំងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិចំពោះចៅក្រមអន្តរជាតិគឺ ប្រាំពីររូប ដោយប្រាំរូបជាចៅក្រមពេញសិទ្ធិ ហើយពីររូបជាចៅក្រមបម្រុងសម្រាប់អង្គជំនុំជម្រះសាលាដំបូងហើយនិងបីរូបសម្រាប់អង្គជំនុំជម្រះសាលាដំបូង ហើយនិងបួនរូបសម្រាប់អង្គជំនុំជម្រះតុលាការកំពូល។ បានន័យថាលេខនេះគឺគេបានកំណត់ច្បាស់លាស់ នូវចំនួនជាក់លាក់នៅក្នុងហ្នឹង ហើយត្រូវបានឧត្តមក្រុមប្រឹក្សាអង្គចៅក្រមប្រជុំពិភាក្សាសម្រេច ហើយបានចេញព្រះរាជក្រឹត្យ ដែលខ្ញុំបានជម្រាបនៅព្រឹកមិញ។ ហើយប្រសិនបើយើងត្រូវការសមាសភាពផ្សេងពីសមាសភាពដែលមានស្រាប់នៅក្នុងព្រះរាជក្រឹត្យនេះ វាអាចពាក់ព័ន្ធដែរឬទេ លើបញ្ហាថា ត្រូវធ្វើវិសោធនកម្មកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិអំពីសមាសភាពចៅក្រម ដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការសវនាការជាពិសេស និងដោយឡែក គឺអង្គជំនុំជម្រះសាលាដំបូងនេះ។ រួមទាំងបទប្បញ្ញត្តិពាក់ព័ន្ធនេះនៅក្នុង

ច្បាប់ស្តីពីការបង្កើតអ.វ.ត.ក ផង។ នេះខ្ញុំគ្រាន់តែជម្រាបទេ ដោយសារបញ្ហាសំណួរទី១អំមិញ គឺមិនមានចំណុចបញ្ជាក់ច្បាស់នៅឡើយ បញ្ហានេះគឺយើងនឹងពិនិត្យពិចារណាគួបផ្សំនឹងធាតុផ្សំផ្សេងទៀតដែលយើងរកឃើញនៅក្នុងអំឡុងពេលនៃការជជែកពិភាក្សានេះ។

បាទ ជាបន្តទៅនេះអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីមានឱកាសក្នុងការសាកសួរទៅចំពោះឯកឧត្តមប្រធាន និងលោកអនុប្រធានការិយាល័យរដ្ឋបាលចំពោះបញ្ហាដែលអង្គជំនុំជម្រះបានលើកឡើងកាលពីព្រឹកមិញនេះ តើមានបញ្ហាអីដែលចង់សួរបញ្ជាក់រំលេចបន្ថែមដែរឬទេ?

បើមានសូមអញ្ជើញបាទ!

[១១:៥៥:០៩]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគីអង្គសវនាការដែលមានវត្តមាននាពេលនាពេលនេះ។ សូមគោរពលោកប្រធាន យើងខ្ញុំមានសំណួរបន្តិចបន្តួចតែប៉ុណ្ណោះសម្រាប់សួរបញ្ជាក់អំពីអ្វីដែលបានលើកឡើងពីព្រឹកមិញ។ សំណួរយើងខ្ញុំគឺថា មានការបញ្ជាក់ហើយ ក៏ប៉ុន្តែនៅតែមិនទាន់មានភាពច្បាស់លាស់ យើងខ្ញុំមិនទាន់មានការយល់ច្បាស់លាស់អំពីរយៈពេលសម្រាប់ការតែងតាំងឲ្យមានចៅក្រមថ្មី ក្រៅពីបញ្ជីដែលមានស្រាប់នៅ អ.វ.ត.ក នេះ។ ថាតើសម្រាប់ចៅក្រមជាតិរយៈពេលនៃការតែងតាំងប្រើរយៈពេលប៉ុន្មាន? ហើយសម្រាប់ចៅក្រមអន្តរជាតិរយៈពេលតែងតាំងនេះត្រូវការប្រើរយៈពេលប៉ុន្មាន? ថាតើការតែងតាំងនេះអាចចៅក្រមទាំងអស់នោះចូលមកកាន់តំណែងនៅទីនេះក្នុងអំឡុងខែណា? ខាងខែ៣, ខែ៤ ឬក៏ ខែ៥, ខែ៦ តើអាចបញ្ជាក់អំពីបញ្ហានេះបានដែរឬទេ?

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ អ៊ីចឹងខ្ញុំសូមសាកល្បងឆ្លើយលើសំណួរនេះ។ ដូចខ្ញុំបានលើកឡើងពីព្រឹកមិញហើយថាជាទម្លាប់យើងត្រូវតែសំណើទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ហើយយើងធ្លាប់បានធ្វើជាបន្តបន្ទាប់ហើយ គឺជាទម្លាប់ ជាមធ្យម គឺវានៅក្រោមមួយខែ។ អ៊ីចឹងខ្ញុំមិនអាចនិយាយប៉ាវសម្រាប់ស្ថាប័នឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមទេ។ អ៊ីចឹងជាទម្លាប់ដែលធ្លាប់ធ្វើ មិនមែនជាលើកទី១ទេ គឺវាមិនលើសពីមួយខែទេ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញបន្តសំណួរទៀតបាទ។

**លោក ពេជ អង្គ៖**

បាទ សំណួររបស់ខ្ញុំគឺសម្រាប់ខាងអន្តរជាតិផងដែរបាទ។

**ប្រធានអង្គជំនុំ៖**

លោកអនុប្រធានការិយាល័យរដ្ឋបាលមានអ្វីឆ្លើយតបបន្ថែមទៅលើសំណួរ ដែលសួរដោយក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអម្បាញ់មិញនេះដែរទេ? បើមានសូមអញ្ជើញបាទ!

[១១:៥៧:៤៥]

**លោក ឃុត វ៉ូសាន់ហោក៖**

បញ្ហានេះ គឺទាក់ទងទៅនឹងឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គឺជាសិទ្ធិអំណាចរបស់ខាងភាគីជាតិ។ ដូច្នេះខ្ញុំសូមប្រគល់ទៅខាងភាគីជាតិ។

**លោក ពេជ អង្គ៖**

បាទ ប្រហែលជាសំណួររបស់ខ្ញុំមិនបានច្បាស់លាស់សម្រាប់ភាគីអន្តរជាតិ។ សម្រាប់នីតិវិធីនៅក្នុងការតែងតាំងចៅក្រមអន្តរជាតិ ដើម្បីឱ្យគាត់ចូលមកកាន់តួនាទីនៅក្នុងអង្គជំនុំជម្រះនេះ។ ថាតើត្រូវការរយៈពេលប៉ុន្មាន? ដូចលោកបានបញ្ជាក់ហើយមានត្រូវការឆ្លងកាត់ដំណាក់ ដែលមានពាក់ព័ន្ធទៅនឹងអគ្គលេខាធិការរបស់អង្គការសហប្រជាជាតិទៀត។ ដូច្នេះថាតើលោកអាចបញ្ជាក់បានទេ រយៈពេលប៉ុន្មានដែលចាប់ពីពេលដែលលោកធ្វើសំណើទៅថ្នាក់លើបន្តទៀត ហើយរហូតដល់ចៅក្រមមកកាន់តំណែងនៅក្នុងអង្គជំនុំជម្រះនេះ ថាតើត្រូវការរយៈពេលប៉ុន្មាន?

[១១:៥៨:៥២]

**លោក ឃុត វ៉ូសាន់ហោក៖**

សូមអរគុណ។ ទាក់ទងទៅនឹងបញ្ហាបច្ចេកទេស គឺធ្វើឡើងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដូចជាខាងចៅក្រមជាតិដែរ។ ប៉ុន្តែចំពោះខាងអង្គការសហប្រជាជាតិ គឺអគ្គលេខាធិការជាអ្នកតែងតាំងចៅក្រម។ ដូចដែលខ្ញុំបានបញ្ជាក់ពីដើម គឺយើងមានបញ្ជីចៅក្រម ឬក៏យើងហៅថាបេក្ខជនចៅក្រម ដែលមាន -- ដែលទទួលបានការតែងតាំង ហើយគឺថាមានកាតព្វកិច្ចក្នុងការធ្វើដូច្នេះ។ ប្រសិនបើមានតម្រូវការ គឺគេនឹងបានបញ្ជាក់ ហើយនិងបានបញ្ជូនបញ្ជីឈ្មោះហ្នឹងមកខាងឧត្តមក្រុមប្រឹក្សានៃ

អង្គចៅក្រម។ នេះគឺជានីតិវិធី។

ទាក់ទងទៅនឹងពេលវេលា ខ្ញុំគិតថាខ្ញុំនឹងផ្តល់អត្ថិភាពបំផុតទៅលើបញ្ហានេះ ហើយខាងការិយាល័យកិច្ចការច្បាប់ក៏នឹងបានដោះស្រាយទៅលើបញ្ហានេះ។ ហើយយើងនឹងបាន -- យើងនឹងជួយជំរុញដល់បញ្ហាល្បឿននេះ ហើយយើងនឹងផ្តល់អត្ថិភាពខ្ពស់បំផុតចំពោះបញ្ហានេះ។ ប៉ុន្តែខ្ញុំមិនអាចបញ្ជាក់អំពីចំនួនថ្ងៃឱ្យបានច្បាស់លាស់ ពិតប្រាកដនោះទេ។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណចំពោះការឆ្លើយបំភ្លឺដ៏ក្បោះក្បាយនេះ។ លោកប្រធានខ្ញុំខាងភាគីដើមបណ្តឹងរដ្ឋប្បវេណីអស់សំណួរពាក់ព័ន្ធទៅនឹងចំណុចនេះហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ បាទឥឡូវនេះដល់ពេលសម្រាកហើយ អ៊ីចឹងគឺកិច្ចប្រជុំរបស់គឺផ្អាកត្រឹមនេះសិនហើយកិច្ចប្រជុំពិភាក្សារបស់យើងនឹងលើបន្តទៅទៀតនៅរសៀលនេះ ចាប់ផ្តើមពីម៉ោងមួយនិងសាមសិបនាទី។ ហេតុដូច្នេះសូមភាគី និងសាធារណជនជ្រាប ហើយនិងសូមអញ្ជើញចូលរួមឱ្យបានទាន់ និងតាមពេលវេលាកំណត់នេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០០ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:០៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ!

ខ្ញុំប្រកាសបន្តកិច្ចប្រជុំពិភាក្សារបស់យើងតទៅទៀត។ ហើយប្រធានបទដែលបានដាក់ជជែកពិភាក្សាកាលពីព្រឹកមិញនេះ ឃើញថានៅមិនទាន់ចប់នៅឡើយទេ ដោយសារនៅមានក្រុមមេធាវីការពារក្តីទាំងពីរក្រុម ដែលមិនទាន់បានសួរសំណួរពាក់ព័ន្ធជាមួយនឹងបញ្ហានេះ។ ប៉ុន្តែដោយ -- ដើម្បីចង់ឱ្យបានច្បាស់លាស់លើបញ្ហានេះ ខ្ញុំគ្រាន់តែសុំបញ្ជាក់បន្ថែមលើការកត់សម្គាល់មួយចំនួនដោយធនធាន

ដែលសម្រាប់ តើខ្ញុំជាប្រធានអង្គជំនុំជម្រះសាលាដំបូងហ្នឹងអាចអញ្ជើញចៅក្រមដែលមានស្រាប់ទាំងជាតិ និងអន្តរជាតិនៅអ.វ.ត.ក នេះតែងតាំងជាក្រុមប្រឹក្សាជំនុំជម្រះទី២ បានដែរឬអត់?

យើងបានជជែកគ្នារួចជាច្រើនហើយ ប៉ុន្តែខ្ញុំកត់សម្គាល់លើមាត្រា៥៥៦ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ត្រង់ចំណុចចុងក្រោយបង្អស់គឺប្ដឹងជំទាស់ គឺអាចទទួលបានពាក់ព័ន្ធតែចៅក្រមអាសនៈតែប៉ុណ្ណោះ។ ចៅក្រមទាំងឡាយអាចត្រូវប្ដឹងជំទាស់ដោយមូលហេតុដូចខាងក្រោមនេះ។ ខ្ញុំលើកយកមូលហេតុចុងក្រោយ៖ "កាលណាចៅក្រម ឬធ្លាប់ជាអ្នកតំណាង ឬជាអ្នកជំនួយឲ្យភាគីចំពោះរឿងក្ដី ឬកាលណាចៅក្រមចូលរួមក្នុងការសម្រេចសេចក្ដីក្នុងនាមជាមជ្ឈត្តករចំពោះរឿងក្ដី ឬបានចូលរួមក្នុងការសម្រេចសេចក្ដីនៅសាលាដំបូងដែលបានប្ដឹងប្រាស្រ័យ ឧបាស្រ័យ ឬការជំនុំជម្រះបណ្ដឹងឧទ្ធរណ៍ដែលមានឧបាស្រ័យ ឬបង្ហាញមតិយោបល់ណែនាំផ្នែកច្បាប់ចំពោះរឿងក្ដី"។ បាទ សូមឲ្យមានការចាប់អារម្មណ៍ ពីព្រោះយើងនឹងដាក់បញ្ហានេះ។ នេះតាមលទ្ធភាពក្នុងការពិនិត្យលើធនធានដែលមានស្រាប់។ តើបញ្ហាទាំងអស់នេះវាអាចរារាំងមិនឲ្យខ្ញុំធ្វើសំណើសុំក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ ដែរឬទេ?

[១៣:៣៤:៣៨]

បញ្ហាមួយទៀត ខ្ញុំបានបញ្ជាក់រួចហើយកាលពីព្រឹកមិញ។ ប៉ុន្តែដោយសារព្រឹកមិញនេះ យើងមិនទាន់មានភាពប្រាកដប្រជាជាងអ្វីដែលខ្ញុំបានបញ្ជាក់អម្បាញ់មិញនេះ គឺពាក់ព័ន្ធជាមួយនឹងកិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជាជាមួយនឹងអង្គការសហប្រជាជាតិ ត្រង់មាត្រា៣ អំពីចៅក្រម។ នៅក្នុងមាត្រានេះ គឺចែងច្បាស់ហើយ សមាសភាពចៅក្រមជំនុំជម្រះមានដូចខាងក្រោមនេះ៖

"ក) ចៅក្រមជំនុំជម្រះសាលាដំបូង ចៅក្រមខ្មែរបីរូប ចៅក្រមអន្តរជាតិពីររូប។ ខ) ចៅក្រមជំនុំជម្រះតុលាការកំពូល ដែលជាកន្លែងទទួលបណ្ដឹងឧទ្ធរណ៍ផង និងជាកន្លែងចេញសេចក្ដីសម្រេចបិទផ្លូវប្ដឹងតវ៉ាផង ចៅក្រមខ្មែរបួនរូប និងចៅក្រមអន្តរជាតិបីរូប"។

ចំណុចទី៥ -- កថាខណ្ឌទី៥៖ "លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ នឹងបញ្ជូនបញ្ជីឈ្មោះបេក្ខជនសម្រាប់តំណែងជាចៅក្រមអន្តរជាតិយ៉ាងតិចប្រាំពីររូប ហើយពីក្នុងបញ្ជីនេះឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម នឹងតែងតាំងចំនួនប្រាំរូប ដើម្បីបម្រើការងារជាចៅក្រមនៅក្នុងអង្គជំនុំជម្រះក្ដីទាំងពីរថ្នាក់។ ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រម តែងតាំងចៅក្រមអន្តរជាតិដោយយកពីក្នុងបញ្ជីឈ្មោះដែលអគ្គលេខាធិការអង្គការសហប្រជាជាតិបានប្រគល់ជូនតែប៉ុណ្ណោះ"។

[១៣:៣៦:០៥]

បាទ ហើយនេះគឺថា ចំពោះចៅក្រមបម្រុង គឺនៅសាលាក្តីនីមួយៗ គឺមានមួយរូបជាតិ មួយរូបអន្តរជាតិ។ នេះយើងបានដឹងគ្រប់គ្នាហើយ។ ខ្ញុំចង់បានធ្វើការ -- ត្រូវការមតិយោបល់ពីអស់លោក លោកស្រីដែលពាក់ព័ន្ធនឹងបញ្ហានេះ ដោយសារបទប្បញ្ញត្តិនេះបានចែងច្បាស់លាស់លើចំនួន លើទាំងការបញ្ជូននូវបញ្ជីឈ្មោះ ទាំងការតែងតាំង ហើយព្រះរាជក្រឹត្យដែលខ្ញុំបានលើកឡើងព្រឹកមិញ គឺស្របទៅនឹងបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងនេះរួចហើយ ប៉ុន្តែលទ្ធភាព ប្រសិនបើលទ្ធភាពទី១ អម្បាញ់មិញដែលខ្ញុំបានលើកឡើងថា វាបញ្ហាទំនាស់ផលប្រយោជន៍ ឬក៏វិសមត្ថភាពរវាងតួនាទីនៅក្នុងកិច្ចដំណើរការនីតិវិធីកន្លងមកនេះ។ សួរថាលទ្ធភាពទី២ តើការដែលសុំជ្រើសរើសថ្មី មនុស្សថ្មី ចៅក្រមថ្មី មកចូលរួមដើម្បីបង្កើតក្រុមប្រឹក្សាទី២នេះ តើវាមានបញ្ហាទំនាស់ផ្លូវច្បាប់ដែរឬទេចំពោះបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងដែលខ្ញុំបានអានជម្រាបជូនអស់លោក លោកស្រីរួចហើយអម្បាញ់មិញនេះ។

បាទ ជាបន្តទៅនេះ សូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា។

សូមអញ្ជើញបាទ! បើសិនជាមានសំណួរអ្វីសួរបញ្ជាក់ទៅលើឯកឧត្តមប្រធាន និងលោកអនុប្រធានការអំពីបញ្ហាដែលយើងបានជជែកពិភាក្សាគ្នាកាលពីព្រឹកមិញនេះ។

[១៣:៣៧:៣៥]

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន ហើយសូមជម្រាបសួរអស់លោក លោកស្រីទាំងអស់នៅក្នុងទីនេះ។ លោកប្រធានយើងមានសំណួរពីរ ដែលខ្ញុំចង់ដាក់សួរទៅឯកឧត្តមប្រធានស្តីទី និងលោកអនុប្រធាន។ សំណួរទាំងពីរនេះ គឺពាក់ព័ន្ធទៅនឹងការបារម្ភដែលខាងមេធាវីការពារក្តីយើងមាន។ ទី១ គឺថាយើងបានបញ្ជាក់ដែលប្រាប់មកខាងយើងថា គឺខាងប្រធានអង្គភាពគាំពារការពារក្តីបានប្រាប់យើងថា ក្នុងករណីដែលមានការជំនុំជម្រះទី២ ដែលធ្វើឡើងក្រោយការចេញសាលក្រម។ ដូច្នេះនៅក្នុងពេលប្រាំ-ប្រាំមួយខែឆ្នាំក្រោយយើងអត់មានសវនាការនោះទេ។ នៅក្នុងករណីនេះគឺយើងនឹងមានផលប៉ះពាល់ជាអវិជ្ជមានចំពោះថវិកាខាងការពារក្តី។ គេប្រាប់យើងថា មិនទាន់មានការសម្រេចនៅឡើយទេ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយយើងចង់ស្នើសុំការបកស្រាយ គឺចង់សួរទៅឯកឧត្តមប្រធាន និងលោកអនុប្រធាន គឺថាក្នុងករណីដែលសាលាដំបូងសម្រេចថា និងមានសវនាការសំណុំរឿង០០២/០២ នៅក្រោយចេញសាលក្រម ថាតើវាមានផលវិបាក ឬក៏មានផលប៉ះពាល់អវិជ្ជមានបែបណាចំពោះខាងថវិកាការពារក្តី? ហើយចំពោះសំណួរទី២ គឺពាក់ព័ន្ធទៅនឹងរយៈពេលប្រហែលជាខែ៦ ខែ៧ ឬក៏ចុងឆ្នាំ២០១៤នុ៎ង គឺ

នៅពេលដែលយើងស្តាប់ -- យើងមានសវនាការលើភស្តុតាងនៅក្នុងសំណុំរឿង០០២/០២ ហើយយើងក៏ប្រហែលជានឹងមានការប្តឹងសាទុក្ខសម្រាប់សំណុំរឿង០០២/០១។ ដូច្នេះនៅពេលនោះគឺថាខាងមេធាវីការពារក្តីនឹងមិនអាចបំពេញការងារឲ្យបានជោគជ័យ នៅពេលដែលយើងគិតទៅដល់ធនធានដែលយើងមានក្នុងពេលបច្ចុប្បន្ននោះឡើយ។

ទាក់ទងទៅនឹងផែនការសង្គ្រោះបន្ទាន់ ឬក៏ថវិកាសង្គ្រោះបន្ទាន់របស់ខាងអន្តរជាតិនោះ តាមខ្ញុំយល់គឺថាមេធាវីការពារក្តីទាំងខាងជាតិ និងខាងអន្តរជាតិ គឺថាទាំងមេធាវីជាតិ និងមេធាវីការពារក្តី គឺយើងទទួលការទូទាត់ពីថវិកាអន្តរជាតិ។ ដូច្នេះ តើយើងអាចដាក់ពាក្យស្នើសុំថវិកាបន្ថែមនៅក្នុងរយៈពេលដែលយើងត្រូវត្រៀមប្តឹងសាទុក្ខផង យើងត្រៀមសវនាការសម្រាប់លើភស្តុតាងផងដែរឬទេ? ដូច្នេះ គឺជាបញ្ហាពីរដែលខ្ញុំចង់ធ្វើការសាកសួរ ទៅឯកឧត្តម និងលោកអនុប្រធាន។

**លោក ឃ្នុត រ៉ូសាន់ហោក៖**

សូមអរគុណ។ ដោយសារតែបញ្ហានេះ គឺជាការបង្ហាញអំពីខាងមេធាវីការពារក្តី ហើយខាងការពារក្តី គឺស្ថិតក្រោមខាងអន្តរជាតិ។ ដូច្នេះ គឺយើងមិនមានភាពខុសគ្នារវាងបុគ្គលិកជាតិ និងបុគ្គលិកអន្តរជាតិនោះឡើយ។ ចំពោះសំណួរទី១ ដែលយើងត្រូវបំបែកឲ្យខុសគ្នារវាងថវិកា និងអ្វីដែលជាផែនការកំពុងអភិវឌ្ឍន៍នោះ។ ដូច្នេះ គឺមានការសន្មតថា យើងសន្មតថាមិនមានការជំនុំជម្រះក្នុងពេលដែលយើងរៀបចំសវនាការក្នុងពេលជាមួយនោះឡើយ។ នេះគឺជាបទដ្ឋាននិតិវិធីធម្មតាសម្រាប់ក្រុមខាងការពារក្តី។ ប៉ុន្តែក្នុងថវិការបស់យើងគឺមិនមានការផ្លាស់ប្តូរនោះឡើយ។ គឺថាយើងផ្តល់ថវិកាចំពោះក្រុមមេធាវីការពាក្តីទាំងពីរដោយពេញលេញតែម្តង។ ប៉ុន្តែក្នុងការអនុវត្តជាក់ស្តែង យើងត្រូវតែមានការកែសម្រួល។ ចំពោះសំណួរទី២ នៅពេលដែលអនុវត្តការងារទាំងពីរក្នុងពេលជាមួយគ្នា នៅពេលនោះគឺយើងមានផែនការសង្គ្រោះបន្ទាន់សម្រាប់មេធាវីការពារក្តី។ ហើយដូចគ្នាហ្នឹង ចំពោះខាងព្រះរាជអាជ្ញាក៏យើងប្រើប្រាស់ដូចគ្នាដែរ គឺប្រសិនបើមានសំណើពីខាងសហព្រះរាជអាជ្ញា គឺយើងឆ្លើយតបដូចគ្នាដែរ។

[១៣:៤២:២៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

បាទ ជាបន្តទៅនេះ សូមផ្តល់ឱកាសជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

សូមអញ្ជើញ! សូមអញ្ជើញលោកមេធាវី សុន អរុណ បាទ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ សូមគោរពអង្គសវនាការ សូមគោរព។ ខ្ញុំមានសំណួរពីរ ដូចសហភាតារបស់ខ្ញុំអ៊ីចឹងដែរ។ សំណួរទី១ សួរថា – សួរទៅខាងរដ្ឋបាល – ដោយយោងការយល់ឃើញមិនសូវច្បាស់ ខ្ញុំសូមឲ្យរដ្ឋបាលឆ្លើយឲ្យបានជាក់លាក់ និងទូលំទូលាយ ដើម្បីការយល់ច្បាស់លាស់របស់ខ្ញុំ និងខ្ញុំជឿថាអ្នក --មានផ្នែកខ្លះក៏យល់មិនសូវច្បាស់ដូចខ្ញុំដែរ។

តាមរយៈប្រធានការិយាល័យ ឌី.អេស.អេស បានឲ្យដឹងថា នៅដំណាច់ឆ្នាំ២០១៣នេះ នឹងអាចកាត់មន្ត្រីខ្លះចេញពីផ្នែករបស់ខ្លួន ដូចជាទីប្រឹក្សាច្បាប់។ល។ ចុះបើករណី០០២ កើតនៅពេលឆាប់ៗនេះ តើនយោបាយកាត់មន្ត្រីទាំងនេះ នៅតែបន្តដដែល ឬក៏រក្សាទុកបុគ្គលិកដែលមានស្រាប់នោះ? ពីព្រោះបើបង្កើតករណី០០២/០២ នៅពេលឆាប់ៗនេះ នោះការងាររបស់មេធាវីការពារនឹងមានការងារកាន់តែច្រើន គឺត្រូវរៀបចំធ្វើ ឧទាហរណ៍ទៅតុលាការកំពូលផង និងត្រូវរៀបចំសវនាការករណី០០២/០២ផង។ អានេះសំណួរទី១។

សំណួរទី២ សួរថា តាមចម្លើយរបស់លោកប្រធានរដ្ឋបាល និងអនុប្រធានរដ្ឋបាលព្រឹកមិញ បានឆ្លើយចំពោះចៅក្រម និងព្រះរាជអាជ្ញាថានឹងមានប្រាក់ថវិកាទន់ភ្លន់ បត់បែនទៅតាមកាលៈទេសៈ។ ឧទាហរណ៍ពិតប្រាកដ ដែលកើតឡើងមកនៅពេលដែលប្រាក់ខែ មន្ត្រីធំមន្ត្រីតូចខាងខ្មែរអត់មានបើកឲ្យបីឬបួនខែ ហើយដំណើរការតុលាការនោះបានផ្អាក អាការផ្អាកនេះហើយដែលធ្វើឲ្យតុលាការពន្លឿនទៅមុខអត់រួច។ ដើម្បីឲ្យបានពន្លឿន ខ្ញុំសូមបញ្ជាក់ម្តងទៀតថាប្រាក់សម្រាប់បង្វិលទន់ភ្លន់ ដែលលោកទាំងពីរបានជម្រាបតុលាការនោះតើវាពិតប្រាកដយ៉ាងម៉េចខ្លះ? ពាក្យថាទន់ភ្លន់នោះ? តាមមានប្រសាសន៍ពីព្រឹកមិញថា ខាងបរទេសនឹងមានប្រាក់ ប៉ុន្តែខាងខ្មែរតើមានបម្រុងទុកដូចខាងបរទេសទេ? នេះជាសំណួរទី២ សូមអរគុណ។

[១៣:៤៦:១៦]

**ឯកឧត្តម ក្រាញ់ តូនី៖**

សូមអរគុណលោកមេធាវី។ អ៊ីចឹងខ្ញុំ ដោយហេតុថាសំណួរទី១ គឺជាការងារដោយឡែករបស់លោក ឃ្មុត ខាងសមាសភាពអង្គការសហប្រជាជាតិពាក់ព័ន្ធលើផ្នែកគាំពារជនជាប់ចោទនេះ ខ្ញុំសូមឆ្លើយលើសំណួរទី២ តែម្តង។ សំណួរទី២ អ្វីដែលខ្ញុំនិយាយហ្នឹង ម្តងវិញទៀតគឺថវិកាគឺមានថវិកាជា

តួលេខ ដែលយើងត្រូវអនុម័តឆាប់ៗនេះ ដោយប្រទេសផ្ដល់ជំនួយធំៗ នូវអ្វីដែលគេហៅថា ប្រទេស ផ្ដល់ជំនួយធំៗ *ប្រាំងស៊ីប៉ាល់ដូន័រគ្រុប ឬ ក៏ស្មៀលើងកូតេ (តាមសូរស័ព្ទ)* នៅញូវយ៉កសភាអស់លោក នោះកំពុងតែពិចារណាទៅលើគម្រោងថវិកាដែលយើងខ្ញុំបានទៅឧទ្ទេសនាមនិងដាក់ជូនសម្រាប់ពិនិត្យពី មួយខែមុននេះ ឥឡូវគេមិនទាន់អនុម័តទេ។ អ្វីដែលខ្ញុំនិយាយថា មានភាពទន់ភ្លន់នោះ គឺក្នុងគម្រោង ថវិកានីមួយៗ យើង គឺឯកសារថវិកាជាការប្រមើលមើលនូវសកម្មភាពដែលអាចនឹងមានក្នុងឆ្នាំនេះ ក្នុងឆ្នាំ២០១៤-២០១៥ នេះបាទ។ អ្វីដែលខ្ញុំនិយាយថាមានលក្ខណៈទន់ភ្លន់នោះ គឺជាសិល្បៈ និងជា បច្ចេកទេសនៃការតាក់តែងថវិកា គឺយើងបានគ្របដណ្ដប់ទៅលើសកម្មភាពគ្រប់ផ្នែក នៅគ្រប់ អ.វ.ត.ក ហើយនៅមានកញ្ចប់មួយដែលគេហៅថា កញ្ចប់សម្រាប់ដូចជាកុងសុលតង់ ដូចជាចៃដន្យអ្វីដែលយើង បានប្រមើលមើលមិនឃើញនៅក្នុងការតាក់តែងថវិកាតាមផែនការសកម្មភាពហ្នឹង។ អាហ្នឹងហើយ ដែលលក្ខណៈទន់ភ្លន់និងអាចបត់បែនបាន។

[១៣:៤៨:០៣]

រីឯមួយផ្នែកទៀតដែលខ្ញុំបានជម្រាបជូនពីខាងលើនេះហើយ គឺយើងមានបញ្ហាកង្វះសាច់ប្រាក់។ ពេលណាថវិកាកំណត់ហើយគឺវាអត់មានបញ្ហាទេ ថវិកាកំណត់ហើយ គឺយើងធ្វើការងារទៅតាមការ កំណត់នោះហើយតាមផែនការសកម្មភាពនោះ។ ហើយបញ្ហាកង្វះសាច់ប្រាក់ ដោយហេតុថាតុលាការ យើងចំណុះទៅនឹងថវិកាស្ម័គ្រចិត្តរបស់ប្រទេសផ្ដល់ជំនួយធំៗ។ អ៊ីចឹងវាតែងតែមានការយឺតយ៉ាវក្នុង ការបើកប្រាក់ខែ ជាពិសេសខាងភាគីជាតិយើងមានបញ្ហានេះតាំងពីឆ្នាំ២០០៨, ២០០៩មកម្ល៉េះ។ ហើយ បើយើងយល់ឃើញថា យើងឈប់ធ្វើការងារទាំងអស់ដោយសារមានបញ្ហាយឺតយ៉ាវខ្លះៗតុលាការនេះ ប្រហែលជាគ្មានវត្តមានមកដល់ថ្ងៃនេះទេ ព្រោះអីយើងមានបញ្ហាចាប់ពីឆ្នាំ ២០០៨, ២០០៩ ហើយ។ ប៉ុន្តែជាសរុបមកវិញគឺពេលណាដែលថវិកាត្រូវបានអនុម័តហើយ គឺសាច់ប្រាក់មក គ្រាន់តែយឺត ហើយ យើងទទួលបានប្រាក់ខែគ្រប់ៗគ្នាទាំងមន្ត្រីគ្រប់ផ្នែកទាំងអស់។ នេះជាបញ្ហា ហើយតថភាពនៃអ.វ.ត.ក របស់យើង។ នេះជាចម្លើយរបស់ខ្ញុំលើសំណួរទីពីរសូមអរគុណ។

**លោក ឃ្លុត វ៉ូសាន់ហោក៖**

សូមអរគុណ។ ចំពោះសំណួរទី១គឺថាខាងការពារក្ដីត្រូវបានឧបត្ថម្ភទាំងស្រុងដោយខាងអង្គការ សហប្រជាជាតិហើយមិនមានការពន្យារ ហើយក៏មិនមានការយឺតយ៉ាវក្នុងការទូទាត់ថវិកាដោយសារ អង្គការសហប្រជាជាតិឡើយ។ ដូច្នេះគឺថាខាងអង្គភាពគាំពារការការពារក្ដីមិនដែលមានបញ្ហាដូចខាង

ជាតិនោះឡើយ។ ចំពោះសំណួរលោកសួរនោះគឺដូចប្រហាក់ប្រហែលនឹងសំណួរពីមុនដែរ។ គឺថាអ្វីៗទាំងអស់នៅក្នុងខាងការពារក្តី គឺត្រូវធ្វើការ -- គឺថាត្រូវដើរដោយសារផែនការ។ ប្រសិនបើមិនមានការងារទេគឺអត់មានដំណើរការ មិនមានការធ្វើផែនការនោះឡើយ។ ប៉ុន្តែចំពោះលោក លោកបាននិយាយថាសវនាការ០០២/០២ នឹងចាប់ផ្តើមឆាប់ៗនេះ ប៉ុន្តែវាគ្រាន់តែជាលទ្ធភាពមួយប៉ុណ្ណោះ ហើយវាជាបញ្ហាមួយដែលយើងត្រូវដោះស្រាយនៅពេលក្រោយ។ ហើយវាមានការលក្ខខណ្ឌតម្រូវផ្សេងៗដែលយើងត្រូវដោះស្រាយនៅពេលក្រោយទៀត។ សូមអរគុណ។

[១៣:៥០:២៦]

**ប្រធានអង្គជំនុំ៖**

អរគុណ។ សូមអញ្ជើញក្រុមមេធាវីការពារក្តីលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរអង្គជំនុំជម្រះ ហើយនិងភាគីទាំងអស់នៅទីនេះ។ ដោយសារតែយើងកំពុងតែនិយាយអំពីលុយ ទោះបីជាការអន្តរាគមន៍បន្តិចទៀតនេះយើងនិយាយពីច្បាប់ក៏ដោយ ព្រោះថាយើងនៅក្នុងតុលាការ។ ហើយអ៊ីចឹងបញ្ហាច្បាប់មានចោទ ទាក់ទងទៅនឹងអង្គជំនុំជម្រះទី២។ ដោយសារយើងកំពុងតែនិយាយអំពីខាងការពារក្តី ហើយនិងការកាត់បន្ថយការងារ ហើយវិធានការកាត់បន្ថយ តើវាកើតទេ? ពីព្រោះថាមានការអនុម័តថវិកាហើយៗ។ ខ្ញុំគិតថា ភាសាខាងរដ្ឋបាលនេះមិនសូវច្បាស់ទេចំពោះខ្ញុំ។ បើសិនជាខ្ញុំយល់មិនច្បាស់ទេ មានការអនុម័តថវិកាហើយ ហើយយើងត្រូវធ្វើការងារ បំពេញការងាររបស់យើង។

**លោក ឃ្នុត វ៉ូសាន់ហោក៖**

ខ្ញុំគិតថា ខ្ញុំអាចឆ្លើយបាន។ តាមជាគោលការណ៍គឺបាទ ប៉ុន្តែមិនមានការផ្លាស់ប្តូរក្នុងការអនុវត្តជាក់ស្តែងនោះឡើយ។ គឺថាតាំងពីចាប់ផ្តើមរហូតមកដល់ពេលឥឡូវនេះ គឺនៅដដែល គឺថាយើងផ្តល់ទៅដល់ខាងមេធាវី -- ខាងប្រធានអង្គភាពគាំពារការការការពារក្តី។ ដូច្នេះមិនមានអ្វីផ្លាស់ប្តូរនោះទេ។

[១៣:៥២:០៣]

**កញ្ញា អង់តា ហ្គីសសេ៖**

ការអនុវត្តមិនប្រែប្រួលទេ ក៏ប៉ុន្តែនៅតាមរបៀបដែលគេប្រាប់យើងនោះ គេមិនបានសួរយើងថាតើនៅក្នុងស្ថានភាពរាល់ថ្ងៃនេះ យើងត្រូវធ្វើការងារយ៉ាងម៉េច។ ហើយគេបានប្រាប់ថាត្រូវកាត់បន្ថយ

បុគ្គលិកមុននឹងយើងធ្វើការងារនោះផង។ អ៊ីចឹងជាដំបូងនេះ ខ្ញុំសូមគាំទ្រមតិយោបល់របស់អ្នកស្រីចៅក្រម ខាយរ៉ាយថ៍ គឺថាការងារនៅក្នុងសវនាការនេះ គឺជាការងារដែលគេមើលឃើញ។ ក៏ប៉ុន្តែការងារដែលគេមើលមិនឃើញនោះការងារធំណាស់ នៅក្នុងក្របខ័ណ្ឌនៃការប្តឹងឧទ្ធរណ៍ទៅលើសេចក្តីសម្រេចខាងមុខនេះ ឬក៏ការងារត្រៀមលក្ខណៈ -- ការងាររបស់យើងត្រៀមលក្ខណៈក្នុងការជម្រះសេចក្តីលើកទី២។ ពីព្រោះថាយើងមិនមែនធ្វើការតែនៅក្នុងសវនាការនេះទេ យើងត្រៀមលក្ខណៈពីមុនមកទៀតផង។ អ៊ីចឹងយើងត្រូវចាប់ផ្តើមតាំងពីពេលនេះតទ្បូវផង។ ឥឡូវខ្ញុំសូមបញ្ជាក់ត្រង់ចំណុចនេះឲ្យសាធារណជនបានដឹង ព្រោះថានៅពេលដែលយើងពិភាក្សានៅពេលខាងមុខនេះយើងអាចដឹងថាការងារខាងការពារក្តីនេះ ក្រុមការងារក្តីទាំងអស់ដូចទៅភាគីទាំងអស់ផងដែរ មិនមែនត្រឹមតែវត្តមាននៅក្នុងសវនាការនេះទេ វាលើសពីហ្នឹងឆ្ងាយណាស់។

[១៣:៥៣:២៧]

ចំណុចទី២ ខ្ញុំនឹងនិយាយអំពីច្បាប់ ខ្ញុំបានជម្រាបជូនរួចហើយ។ គឺថានៅក្នុងអនុស្សរណៈដែលលោកបាន-- ឥឡូវខ្ញុំនិយាយទៅកាន់ប្រធានរដ្ឋបាលរង។ អនុស្សរណៈដែលលោកបានផ្ញើទៅតុលាការកំពូលបញ្ជាក់អំពីបរិស្ថានច្បាប់នៅកន្លែងយើងនេះ ក្នុងការបង្កើតអង្គជំនុំជម្រះទី២ ហើយមិនទទួលបានចម្លើយអ្វីទេ។ អ៊ីចឹងសំណួរខ្ញុំចង់ដឹងថាតើនៅពេលដែលអត់មានចម្លើយពីតុលាការកំពូលនេះ តើយើង-- ដូចពីព្រឹកមិញយើងនិយាយហើយ ថាយើងអាចនិយាយអំពីការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ដែរឬទេ? ពេលដែលខ្ញុំអានឯកសារនោះ ខ្ញុំមិនដឹងថាមូលដ្ឋានណាដែលអាចឲ្យយើងតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២ហ្នឹងទេ។ គឺថាមានចៅក្រមបម្រុងមែន ប៉ុន្តែពួកគាត់នោះមិនអាច -- គាត់អាចជំនួសចៅក្រមតែកាលៈទេសៈណាមួយទេ តូចតាចទេ រយៈពេលខ្លីទេតាមមាត្រាទី៣កិច្ចព្រមព្រៀងនេះ។ អ៊ីចឹងវាតាមករណីតែប៉ុណ្ណោះ។

[១៣:៥៤:៤៣]

យើងនិយាយអំពីចៅក្រមជំនួសនោះ អ៊ីចឹងគឺថាគាត់ទៅជំនួសគេជាបណ្តោះអាសន្នទេ ដើម្បីជំនួសចៅក្រមដែលជំនុំជម្រះ។ អ៊ីចឹងនៅក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ ដែលយើងពិភាក្សាតាំងពីព្រឹកនេះមកហើយ យើងមិនមែននិយាយអំពីការជំនួសចៅក្រមម្តងម្កាលទេ នេះគឺថាជំនួសបង្កើតក្រុមជំនុំជម្រះថ្មីតែម្តង។ អ៊ីចឹងខ្ញុំសួរថាតើតាមផ្លូវច្បាប់ យើងមានមូលដ្ឋានច្បាស់លាស់ណាមួយទេ បើសិនជាលោកទៅសួរ ទៅតុលាការកំពូលនោះ ប្រហែលជាគេមិនដឹងចម្លើយផងនោះ។ អ៊ីចឹងហើយយើងត្រូវ

ចាំចម្លើយគតិយុត្តពីតុលាការនោះផង។ តើអង្គការសហប្រជាជាតិហ្នឹងត្រូវធ្វើសេចក្ដីសម្រេច ឬក៏តុលាការកំពូលយើងនៅទីនេះសម្រេច? ពីព្រោះថាលោកប្រធានហ្នឹងផ្ទាល់តើត្រូវយ៉ាងម៉េច គាត់ត្រូវប្រឌិត ឬក៏ធ្វើវិសោធនកម្មទៅលើកិច្ចព្រមព្រៀងឬយ៉ាងម៉េចក្នុងការបង្កើតអង្គជំនុំជម្រះទី២នេះ? អ៊ីចឹងខ្ញុំសូមចោទសំណួរនេះទៅលោកដោយផ្ទាល់។ តើលោកចាំសេចក្ដីសម្រេចពីតុលាការកំពូល ឬការបំភ្លឺពីតុលាការកំពូល ឬក៏លោកចាំទទួលការបំភ្លឺពីញូវយ៉ក?

នេះមិនមែនជាគោលជំហររបស់ខ្ញុំទេ។ លោកប្រធានក៏គាត់យល់ឃើញអ៊ីចឹងដែរ ព្រោះថាតាមអត្ថបទហ្នឹងដូចអត់មានគ្រោងអំពីលទ្ធភាពនេះទេ។ អ៊ីចឹងខ្ញុំសូមសង្កត់ធ្ងន់លើផ្នែកច្បាប់នេះ។

សូមលោកអញ្ជើញឆ្លើយ។

**លោក ឃ្លុត វ៉ូសាន់ហោក៖**

សូមអរគុណ។ ចំពោះសំណួរទី១៖ ថាតើយើងចាប់ផ្ដើមការងារនៅពេលណា? អាហ្នឹងគឺជាសិទ្ធិរបស់ប្រធានអង្គភាពគាំពារការការពារក្ដី មិនមែនជាសិទ្ធិរបស់ខ្ញុំទេ។ នេះគឺជាការងាររបស់ខាងការពារក្ដី គឺថាតាំងពីដំបូងមកម្ល៉េះ។ ដូច្នេះ គឺវាអាស្រ័យទៅលើក្រុមការពារក្ដីថាតើពួកគេត្រូវការធនធានប៉ុន្មាន គេត្រូវការនៅពេលណា? ហើយត្រូវមានការអនុម័តពីខាងអង្គភាពគាំពារការការពារក្ដី។ ចំពោះថវិកានៅពេលដែលយើងពិចារណាទៅលើក្រុមទាំងមូលតែម្ដងរហូតទៅដល់ចុងឆ្នាំក្រោយ។ ប្រសិនបើគេត្រូវការថវិកាប៉ុនណា អាហ្នឹងគឺអាស្រ័យទៅលើអង្គភាពគាំពារការការពារក្ដី។

[១៣:៥៧:១១]

ចំពោះសំណួរទី២ គឺថាតាមទស្សនៈខាងការិយាល័យខ្ញុំ គឺថានៅពេលដែលមានការស្នើសុំឱ្យមានការបញ្ជាក់បំភ្លឺ គឺថាអង្គជំនុំជម្រះតុលាការកំពូលថាតើគាត់មានចេតនាចង់ធ្វើវិសោធនកម្មទៅលើកិច្ចព្រមព្រៀង ឬក៏អត់ ប្រសិនបើខាងតុលាការកំពូលគាត់ចង់ ខ្ញុំនឹងជម្រាបទៅដល់ភាគីនានា។ ប៉ុន្តែចំពោះអនុស្សរណៈទី២ គឺខ្ញុំបានសង្កត់ធ្ងន់ថា យើងបានពិនិត្យទៅលើភាពស្មុគស្មាញផ្នែករដ្ឋបាល និងផ្នែកច្បាប់ក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ ហើយយើងបានសន្និដ្ឋានថា ចំពោះយើងៗអាចគាំទ្រទៅដល់ការសម្រេចបែបនេះ ឬក៏អាចគាំទ្រទៅដល់ក្រុមប្រឹក្សាជំនុំជម្រះបច្ចុប្បន្ន។ ហើយខ្ញុំ គឺថាយើងមានទស្សនៈមួយថាយើងអាចគាំទ្រ ប្រសិនបើវាវិវត្តន៍ទៅមុខ។ ហើយយើងក៏មានការទទួលខុសត្រូវទៅដល់បញ្ហារបស់តុលាការនេះផងដែរ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

[១៣:៥៨:៣០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទសូមអរគុណលោកប្រធាន។ ហើយជាសំណួរដែលខ្ញុំសួរទៅលោកស្រីមេធាវី អង់តា ហ្គីសសេ។ ខ្ញុំយល់ថា គឺយើងដឹងថាមានបញ្ហាច្បាប់នៅកន្លែងយើងនេះហើយ ទាក់ទងនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២ តើយើងត្រូវគិតថាអាចត្រូវធ្វើទៅបាន គឺថាក្នុងការលោកស្រីជំទាស់លើភាពស្របច្បាប់នៃការតែងតាំងនេះ តែងតាំងចៅក្រមដែលនឹងបង្កើតចេញជាក្រុមជំនុំជម្រះទី២ ពីព្រោះថាវាអាចមានការប៉ះពាល់ទៅលើការចាប់ផ្ដើមធ្វើដំណើរការសវនាការខាងមុខព្រោះថានឹងមានសំណើសុំឱ្យពិចារណាលើចៅក្រមដែលគេតែងតាំងដោយខុសច្បាប់។ អ៊ីចឹង វាអាចប៉ះពាល់ទៅដល់ដំណើរការនីតិវិធី។ តើលោកស្រីចង់និយាយយ៉ាងដូច្នេះ ឬក៏យ៉ាងម៉េច?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកចៅក្រម! តាំងពីព្រឹកមិញមកនោះ គឺថាយើងទាំងអស់គ្នា ដូចឆ្លើយដាក់គ្នាទៅវិញទៅមកអត់សូវច្បាស់លាស់អីទេ។ គឺថាយើងត្រូវតែទៅមុខ។ សហព្រះរាជអាជ្ញាគាត់និយាយថាដែរ បង្ហាញគោលជំហររបស់ខ្លួន យើងអាចចាប់ផ្ដើមនៅខែ២ យើងត្រៀមលក្ខណៈរួចហើយ អត់មានបញ្ហាអ្វីទេ។

អង្គជំនុំជម្រះនោះក៏ផ្ដល់វេទិកាទៅភាគីដែរ ហើយយើងទាំងអស់គ្នាត្រូវពន្យល់ថា យើងចង់ទៅមុខឱ្យលឿន។ ខ្ញុំចង់ទៅលឿនដែរ ក៏ប៉ុន្តែដូចដែលខ្ញុំបានលើកឡើងអ៊ីចឹង។ អង្កាល់ប្រជុំពីរបីខែមុននេះទៅលឿននោះមិនមែនបានន័យថាចេះតែឱ្យតែទៅទេ ហើយដូចព្រះរាជអាជ្ញាបានលើកឡើងកាលព្រឹកមិញអ៊ីចឹងដែរ ថាយើងត្រូវរត់ទៅមុខ ក៏ប៉ុន្តែយើងត្រូវដឹងថាយើងរត់ទៅណា? ខ្ញុំចង់រត់ដែរ តែខ្ញុំចង់ដឹងថាខ្ញុំចង់ទៅណា? ឥឡូវខ្ញុំចង់ដឹងថាខ្ញុំទៅណា? អ៊ីចឹងនៅពេលដែលគេសួរខ្ញុំពីការបង្កើតអង្គជំនុំជម្រះថ្មីនេះ ខ្ញុំមិនមែនចង់ជំទាស់ទៅលើការតែងតាំងចៅក្រមណាទេ។ ខ្ញុំជាមេធាវី ខ្ញុំសិក្សាច្បាប់ អ៊ីចឹងខ្ញុំមើលតាមអត្ថបទច្បាប់។ ខ្ញុំមុននឹងជំទាស់ហ្នឹង ខ្ញុំចង់សួរថាតើធ្វើការសម្រេចតែងតាំងចៅក្រមថ្មីនេះមើលមូលដ្ឋានអ្វី? បើសិនជាគេប្រាប់ថា មានការធ្វើវិសោធនកម្មអាចធ្វើទៅបានអីនោះ ខ្ញុំមិនជំទាស់អ្វីទេ។ អ៊ីចឹងខ្ញុំគ្រាន់តែចង់ស៊ីជម្រៅលើផ្នែកច្បាប់។ ឥឡូវនេះ យើងចង់បង្កើតក្រុមប្រឹក្សាជំនុំជម្រះថ្មីថាចៅក្រមណាចូលមក? គេនិយាយថា មិនអាចយកចៅក្រមបម្រុង ឬក៏ចៅក្រមដែលនៅសហ

ចៅក្រមស៊ើបអង្កេត ហើយនិងចៅក្រមខាងសហព្រះរាជអាជ្ញា។ យើងខ្ញុំខាងការពារក្តី ខ្ញុំនៅទីនេះដើម្បីការពារសិទ្ធិរបស់កូនក្តីខ្ញុំ។ បើខ្ញុំឃើញថា មានចៅក្រមមកពីចៅក្រមស៊ើបអង្កេត ឬក៏សហព្រះរាជអាជ្ញានោះមកកាត់ក្តីកូនក្តីខ្ញុំនេះ ខ្ញុំគឺតួនាទីខ្ញុំត្រូវតែជំទាស់ហើយ។ យើងត្រូវតែប្រុងប្រយ័ត្នក្នុងការបង្កើត តែងតាំងចៅក្រមថ្មីនេះ។

[១៤:០១:៥៥]

ខ្ញុំគ្រាន់តែចង់ដឹងថា មូលដ្ឋានច្បាប់ហ្នឹងយ៉ាម៉េច? យើងខ្ញុំមិនមែនចង់បានចៅក្រមដដែលហ្នឹងទេសម្រាប់ការកាត់ក្តីវគ្គទី២នេះ។ ខ្ញុំ -- យើងបានរៀបរាប់ហើយថា យើងថាប្រសិនជាការមានប្តឹងឧទ្ធរណ៍អីទៀតនោះ យើងឃើញទាំងអស់គ្នាហើយថា មានច្បាប់។ យើងមើលទៅ ថាតើកិច្ចព្រមព្រៀងនោះយ៉ាងម៉េច? ហើយច្បាប់ណាខ្លះដែលគ្របដណ្តប់លើការបង្កើតចៅក្រមថ្មីនេះ? អ៊ីចឹងដូចនៅក្នុងតុលាការអន្តរជាតិផ្សេងទៀតនោះក៏ដោយ ការជំនួសចៅក្រមដែលគាត់មានទុក្ខធុរៈនោះមានហើយ មានច្បាប់អ៊ីចឹងយើងនេះនៅមានមាត្រាទី៣នៃកិច្ចព្រមព្រៀង។ អ៊ីចឹងខ្ញុំមិនយល់ថា ហេតុអីក៏ត្រូវបង្កើតក្រុមប្រឹក្សាជំនុំជម្រះថ្មីទេ។ ក្នុងពេលដែលគេមិនពន្យល់ពីមូលដ្ឋានច្បាប់ឲ្យខ្ញុំ ខ្ញុំមិនដឹងថាតើ -- ខ្ញុំយល់ហើយថាខាងព្រះរាជអាជ្ញាហ្នឹងចង់ដាក់ភស្តុតាងនៅក្នុងសំណុំរឿងយើងនេះទៅវគ្គជំនុំជម្រះទី២ ហើយយើងជំទាស់ហើយក្នុងការសម្រេចខាងមុខនេះ។ យើងនឹងប្តឹងឧទ្ធរណ៍ហើយនៅខាងមុខនេះ។ តើបើសិនជាចៅក្រមថ្មីនោះមក -- គាត់ឯករាជ្យ ហើយបើគេយកគាត់មកនៅទីនេះ អនុលោមតាមមាត្រាទី៣នៃវិធាន -- នៃកិច្ចព្រមព្រៀងនោះ តើចៅក្រមនៅទីនេះធ្វើអ្វី? ហើយបុគ្គលិកគាំទ្រនោះធ្វើអ្វី? ខ្ញុំអត់យល់។ ក្នុងឋានៈខ្ញុំជាមេធាវីការពារក្តីនេះ ខ្ញុំត្រូវសួរលើចំណុចនេះ។ តើមានរឿងអ្វីកើតឡើង បើសិនជាសេចក្តីសម្រេចសាលក្រមលើកក្រោយនេះ មានប្តឹងឧទ្ធរណ៍នោះ ហើយតើចៅក្រមថ្មីនោះនឹងធ្វើអ្វី? បើសិនជាសុទ្ធតែជាចៅក្រមថ្មីនោះ គេហៅថាក្រុមជំនុំជម្រះថ្មីហើយ មិនមែនទេ... ទោះបីជាយើងយកចៅក្រមបម្រុងមកដាក់អីក៏ដោយ។ អ៊ីចឹងយើងមិនមែននេះទេ យើងត្រូវធ្វើយ៉ាងណាធានាឲ្យមានយុត្តិធម៌ទៅដល់កូនក្តីរបស់ខ្ញុំ។

[១៤:០៤:៣០]

គេថា ខ្ញុំនិយាយលឿន ឥឡូវខ្ញុំសូមបន្ថយល្បឿន។

អ៊ីចឹងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះថ្មីនេះ ខ្ញុំមិនឃើញថាមានមូលដ្ឋានច្បាប់អ្វីទេ។ ខ្ញុំនៅតែមិនយល់ថា វាអត់មានអត្ថបទច្បាប់អីបញ្ជាក់ពីភាពសមហេតុសមផលនេះទេ ត្រឹមត្រូវទេ ហើយអ៊ីចឹង

យើងៗមានខាងរដ្ឋបាលនៅទីនេះ នៅចំពោះមុខយើងនោះ តើ -- ខ្ញុំសួរថាតើខាងរដ្ឋបាលនេះមានសិទ្ធិអំណាចអីបង្ហាញពីមូលដ្ឋានច្បាប់ដែរឬទេ? អានេះខ្ញុំគ្រាន់តែផ្ដល់ចម្លល់របស់ខ្ញុំទេ ថាប្រហែលជាមានភាគីផ្សេងៗទៀតនឹងលើកពីហេតុផលរបស់គេដែរ។ ឥឡូវនេះ ខ្ញុំគ្រាន់តែនិយាយអំពីតើមានមូលដ្ឋានច្បាប់អត្ថបទគតិយុត្តណាដែលគាំទ្រការបង្កើតក្រុមប្រឹក្សាជំនុំជម្រះថ្មីដែរឬទេ? តើនៅពេលដែលគេតែងតាំងគាត់ហើយនោះ តើគាត់មានសិទ្ធិអំណាចអ្វីខ្លះ? ហើយសេចក្ដីសម្រេចរបស់តុលាការយើងរាល់ថ្ងៃនេះមានកម្រិតណា? ព្រោះថាយើងអាចមានធ្វើការជំទាស់ យើងជំទាស់ទៅលើសាក្សីមួយចំនួន។ អ៊ីចឹងមានការប៉ះពាល់ច្រើនណាស់។ អ៊ីចឹងមុននឹងការចាប់ផ្ដើមដំណើរការថ្មីនេះ អ៊ីចឹងខ្ញុំចង់ឲ្យមានភាពច្បាស់លាស់ទាំងអស់គ្នាតាមផ្លូវច្បាប់។ នេះចំណុចទី២។

[១៤:០៥:៥១]

ហើយចំណុចទី៣ នៅពេលដែលយើងនឹងចាប់ផ្ដើមការជម្រះសេចក្ដីវគ្គទី២នេះ សហព្រះរាជអាជ្ញាពន្យល់ថា យើងចាប់ផ្ដើមចុងខែកុម្ភៈបាន។ អ៊ីចឹង ខ្ញុំសួរថាអ្នកណាអ្នកកំណត់ថាវិសាលភាពវគ្គ២នេះប៉ុនណា? សហព្រះរាជអាជ្ញា -- អ៊ីចឹងអ្នកណាសម្រេចលើបញ្ហាវិសាលភាពនេះ? តើអ្នកណាសម្រេច? តើសហព្រះរាជអាជ្ញា ឬក៏ចៅក្រមសព្វថ្ងៃនេះ ឬក៏ចៅក្រមនៃអង្គជំនុំជម្រះទី២? អ៊ីចឹងយើងមិនមែនចង់ធ្វើឲ្យរឿងរ៉ាវស្មុគស្មាញទេ។ កុំនិយាយថាយើងអ្នកធ្វើឲ្យដំណើរការយឺតយ៉ាវ។ ខ្ញុំឡើងនិយាយនេះ ដើម្បីកុំឲ្យមានបញ្ហានៅពេលក្រោយ។ បើសិនយើងមានមូលដ្ឋានថ្មី ដោយសារថាយើងចង់បង្ហាញថា មុខមាត់យើងស្អាតជាងមុន ហើយឲ្យគេផ្ដល់ជំនួយមកច្រើន។ អានេះមិនមានប្រយោជន៍អីទេ។ ខ្ញុំមិនចង់និយាយឲ្យអ្នកណាពេញចិត្តអ្វីទេ។ ខ្ញុំគ្រាន់តែចង់និយាយអំពីភាពស្របច្បាប់ ផ្លូវច្បាប់តែប៉ុណ្ណោះ។ អ៊ីចឹងមូលដ្ឋានច្បាប់ជាធំ ក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះថ្មីនេះ។ ព្រោះថានៅពេលចុងក្រោយ ក្រោយនោះ គឺកូនក្ដីយើងទេ ដែលគេកាត់ទោសនោះ កាត់សេចក្ដីនេះ។ ចំណុចទី៣ ដែលខ្ញុំចង់និយាយដែរ យើងបានចាប់ផ្ដើមនិយាយអំពីខាងការងារខាងការពារក្ដី ហើយខ្ញុំសប្បាយចិត្តនឹងឮថា ខាងយើងនេះជាអ្នកសម្រេច។

ខ្ញុំសូមរំឭកថា ដើម្បីត្រៀមចូលកិច្ចប្រជុំរៀបចំសវនាការនេះ ហើយនិងវិសាលភាពការកាត់ក្ដីនេះ គឺថាយើងធ្វើការច្រើនណាស់។ ខ្ញុំនិយាយតាំងនាមឲ្យក្រុមផ្សេងទៀត ភាគីផ្សេងទៀត ដើមបណ្ដឹងរដ្ឋប្បវេណីក៏ដោយ សហព្រះរាជអាជ្ញាក៏ដោយ។ ព្រោះថាយើងដឹងស្រាប់ហើយ ថាបុគ្គលិកតាមផ្នែកមួយៗនោះវាមានចំនួនខុសគ្នាៗ។ គេ -- គឺថាអ្នកខ្លះៗ ខំព្យាយាមរកបុគ្គលិកថែម ឬក៏ថារកការងារ

ផ្សេងៗផង ព្រោះថានៅទីនេះមិនច្បាស់លាស់ទេ។

[១៤:០៨:២១]

អ៊ីចឹង យើងត្រៀមយ៉ាងម៉េច បើយើងនៅក្នុងភាពស្រពេចស្រពិល។ ហើយបើសិនជាថាមានបញ្ហាថវិកា ហើយកាត់បន្ថយបុគ្គលិកអ៊ីចឹង ហើយកាត់ -- ដេញបុគ្គលិកទាំងអស់នោះចោល ហើយប្រាប់ -- ហើយខ្ញុំទៅប្រាប់បុគ្គលិកខ្ញុំថា ខំប្រឹងធ្វើការយ៉ាងម៉េចដើម្បីឲ្យយើងចុងខែ២នេះ ឲ្យយើងត្រៀមលក្ខណៈគ្រប់គ្រាន់ មិនអាចធ្វើដូចខាងព្រះរាជអាជ្ញាអីទេ។ អ៊ីចឹង ខ្ញុំសូមរំឭកថា នៅក្នុងក្រុមខ្ញុំនេះ គឺថាយើងជាមួយ គង់ សំអុន, ជាមួយ អាកទូរ វែកគែន, ជាសហការីរបស់ខ្ញុំហ្នឹងក៏ដោយ យើងបានចាប់ផ្តើមសិក្សាឯកសារសំណុំរឿងនេះតែចុងឆ្នាំ២០១១ទេ កាលនោះយើងមិនដឹង មិនបានក្តាប់សំណុំរឿងឲ្យបានមូលទេ ព្រោះថាយើងមានបុគ្គលិកតិចពេក។

ហើយសហព្រះរាជអាជ្ញាជាតិអម្បាញ់មិញនេះ គាត់និយាយពីថ្ងៃបុណ្យថ្ងៃអីនេះច្រើនណាស់។ អ៊ីចឹងខ្ញុំសូមជ្រាបថា ខាងខ្ញុំនេះមិនមែនដែលបានឈប់សម្រាកថ្ងៃបុណ្យទានផង។ អ៊ីចឹងបើយើងនិយាយអំពីការត្រៀមលក្ខណៈការកាត់សេចក្តីនេះ គឺថាមិនមែនយើងត្រូវការពេលមួយខែមុនទេ ចាប់ពេលមុនយូរ តាំងពីឥឡូវហ្នឹងទៅ យើង -- អ៊ីចឹងត្រង់ចំណុចនេះ គឺថានៅពីក្រោយឆាកនោះមានការងារច្រើនណាស់ មិនមែនតែត្រឹមតែនៅសវនាការសាធារណៈទេ។ ហើយដូចថាយើងធ្វើការនេះ គ្រាន់តែឲ្យគេអ្នកផ្តល់ជំនួយមកសប្បាយចិត្តនោះ មិនបាច់មកចូលរួមសវនាការនេះទេ។ អ៊ីចឹងសូមបញ្ចប់ត្រឹមហ្នឹង។

[១៤:១០:០៨]

**ប្រធានអង្គជំនុំ៖**

អរគុណបាទ សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

សូមអរគុណច្រើនលោកប្រធាន។ ខ្ញុំគ្រាន់តែសួរបន្ថែមទៅហ្គីសសេ ពាក់ព័ន្ធទៅនឹងយោបល់ដែលលោកស្រីបានលើកឡើង។ សង្ខេបមកវិញខ្ញុំគិតថាភាគីគ្រប់គ្នានៅក្នុងបន្ទប់សវនាការនេះយល់ថាការងារពាក់ព័ន្ធទៅនឹងការជំនុំជម្រះកំពុងតែបន្តទោះបីជាសវនាការមិនបើកជំនុំជម្រះក៏ដោយ មេធាវីការពារក្តីសហព្រះរាជអាជ្ញាដើមបណ្តឹងរដ្ឋប្បវេណី និងអង្គជំនុំជម្រះកំពុងតែបន្តធ្វើការដូចគ្នា។ ហើយគំនិតនេះមិនមានអ្វីខុសគ្នានោះទេ។ សាធារណជនរួមទាំងអ្នកផ្តល់យោបល់ទាំងអស់ផ្សេងទៀតគឺគាត់មិនយល់ចំណុចហ្នឹងដូចដែលខ្ញុំនិយាយពីខាងដើម។ ការចូលរួមសវនាការជំនុំជម្រះវាស្ថិតនៅក្នុងបញ្ជី

របៀបវារៈរបស់យើង។ ក៏ប៉ុន្តែខ្ញុំយល់មិនច្បាស់សោះចំពោះមេធាវីការពារក្តី ខៀវ សំផន ដែលបានលើកឡើងអំពីបញ្ហាអង្គច្បាប់ពាក់ព័ន្ធទៅនឹងការតែងតាំង ឬក៏លើកឡើងអំពីក្រុមប្រឹក្សាជំនុំជម្រះទី២នោះ។ លោកស្រីបានលើកឡើងចំណុចច្រើនណាស់ ក៏ប៉ុន្តែគោលបំណងនៃការរៀបចំកិច្ចប្រជុំនេះគឺដើម្បីឱ្យយើងអាចដំណើរការចូលរួមក្នុងការជំនុំជម្រះទី២ ហើយនិងការរៀបចំសាលក្រមផងដែរ។ ហើយធ្វើយ៉ាងណាឲ្យយើងអាចចូលទៅដល់វគ្គទី២។ យើងត្រូវតែធ្វើការងារហ្នឹងទាំងអស់គ្នា។ តុលាការកំពូលបានបញ្ជាក់ច្បាស់ហើយសម្រាប់យើងទាំងអស់គ្នា។ យើងធ្វើយ៉ាងណាឲ្យយើងទាំងអស់គ្នានេះដឹងព័ត៌មានច្បាស់អំពីក្រុមប្រឹក្សាជំនុំជម្រះទី២ នៅពេលនោះលោកប្រធាននឹងធ្វើការចេញជាសេចក្តីសម្រេចមួយដែលមានសំអាងហេតុពេញលេញ។ ដូច្នេះ វាជាគុណប្រយោជន៍មួយបើសិនលោកស្រីអាចលើកឡើងអង្គច្បាប់នៅក្នុងសេចក្តីសន្និដ្ឋានអំពីបញ្ហាផ្លូវច្បាប់ថា ចំណុចបញ្ហាផ្លូវច្បាប់ណាមួយដែលបើកឱ្យលោកប្រធាននោះធ្វើការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២បាន។ ក្រុមមេធាវីការពារក្តី នួន ជា អាចលើកឡើងចំណុចនោះបន្ថែមបាន។ ការលើកឡើងយោបល់នេះគឺដើម្បីឱ្យលោកប្រធានអាចចេញសេចក្តីសម្រេចដោយមានសំអាងហេតុពេញលេញសម្រាប់យើង។

[១៤:១២:៤៤]

**កញ្ញា អង់តា ហ្គីសសេះ**

ចាស លោកស្រីចៅក្រម លោកស្រីដូចជាឃោរឃៅជាមួយខ្ញុំពេកហើយ។ ខ្ញុំគិតថាប្រហែលជាតុលាការកំពូលនៅក្នុងសេចក្តីសម្រេចរបស់ខ្លួននោះនឹង -- បន្ទាប់ពីភាគីបានប្តឹងនោះគាត់បានផ្តល់មូល-ហេតុច្បាប់ហើយនៅក្នុងសំអាងហេតុ ខ្ញុំគិតថាចម្លើយរបស់តុលាការកំពូលនឹងផ្តល់សំអាងហេតុខ្លះៗ។ បើសិនជាសំអាងហេតុជាមូលដ្ឋានផ្លូវច្បាប់ក្នុងការបង្កើតអង្គជំនុំជម្រះទី២នេះ។ ប៉ុន្តែបើចំពោះខ្ញុំ មានមាត្រាទី៣នៃកិច្ចព្រមព្រៀងនេះដែលលើកឡើងអំពីលទ្ធភាពនៃការបង្កើត ឬក៏តែងតាំងចៅក្រមបម្រុងលើចៅក្រមដែលមានរាល់ថ្ងៃនេះ។ ចំពោះខ្ញុំនោះ ត្រង់ចំណុចនេះនៅក្នុងមាត្រានេះគ្រាន់តែករណីលើកលែងទេ មិនមែនក្នុងការបង្កើតក្រុមប្រឹក្សាទី២ទេ។ ក៏ប៉ុន្តែបើតុលាការកំពូល ឬក៏ខាងអង្គការសហប្រជាជាតិនៅញូវយ៉កនោះគាត់នឹងនិយាយថា មានលទ្ធភាពអាចបង្កើតបាននោះ ខ្ញុំនឹងពិនិត្យមើលវិភាគអត្ថបទច្បាប់នេះ។ បើសិនគ្រាន់តែមាត្រាទី៣នេះទេ មានតែមាត្រាទី៣ នៃកិច្ចព្រមព្រៀងនេះទេចំពោះខ្ញុំមិនអាចធ្វើបានទេ ព្រោះថា -- ខ្ញុំមើលឃើញប៉ុណ្ណឹងខ្ញុំមិនមានចេះអីជាងគេទេ។ ទោះបីយើងខំប្រឹងបកស្រាយឱ្យបានវែងឆ្ងាយយ៉ាងណាក៏បញ្ហានៃការបង្កើតក្រុមប្រឹក្សាទី២នេះ វាអាចប៉ះពាល់ទៅលើការ

ការពារក្តី សិទ្ធិការពារក្តី ថាតើមូលដ្ឋានអ្វីដែលឈរលើមូលដ្ឋានអ្វីដែលចៅក្រមថ្មីនេះមកធ្វើការជំនុំជម្រះ? ព្រោះថាជារឿងក្តីតែមួយទេ សំណុំរឿង០០២ តែមួយទេ។ អ៊ីចឹងយើងត្រូវការពេលវេលាដើម្បីធ្វើការកត់សម្គាល់ជាលាយលក្ខណ៍អក្សរត្រង់ចំណុចនេះ។ ព្រោះថាបើតាមតុលាការអន្តរជាតិផ្សេងៗនោះមិនដែលមានករណីនេះទេ ហើយតុលាការជាតិក៏មិនដែលមានរឿងនេះដែរ។ អ៊ីចឹងជាចំណុចមួយដែលយើងត្រូវតែពិចារណា ពីព្រោះថាតុលាការកំពូលមិនបានពន្យល់ឲ្យបានច្បាស់លាស់ទេ ហើយដោយសារខ្វះការពន្យល់ច្បាស់លាស់នេះ យើងនឹងធ្វើសំណើជាលាយលក្ខណ៍អក្សរដើម្បីផ្តល់មតិយោបល់របស់ខ្ញុំ ហើយមកសួរខ្ញុំពេលឥឡូវនេះភ្លាមៗនេះ ខ្ញុំរកដំណោះស្រាយមិនឃើញទេលោកស្រីចៅក្រម។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី។

សូមអញ្ជើញចៅក្រម!

[១៤:១៥:៤៤]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

សូមអរគុណលោកស្រី ហ្គិសសេ។ ខ្ញុំនិយាយនេះក្នុងនាមខ្លួនខ្ញុំផ្ទាល់តែប៉ុណ្ណោះ។ យើងមិនចង់ចំណាយពេលច្រើនលើកឡើង -- ឲ្យលើកឡើងអំពីបញ្ហាផ្លូវច្បាប់ពាក់ព័ន្ធទៅនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២នោះទេ។ យើងខ្ញុំមិនចង់បានសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ឬក៏ការប្រជុំបែបនេះលើកក្រោយទៀតនោះឡើយ។ ហើយយើងគ្រាន់តែលើកឡើងចំណុចដែលបានលើកឡើងដោយភាគីនៅក្នុងបន្ទប់សវនាការនេះតែប៉ុណ្ណោះ។ លោកស្រីបានបញ្ជាក់អំពីអង្គច្បាប់លើមាត្រា៣(៨) ហើយមានចំណុចណាទៀតដែលចង់លើកឡើងអំពីអង្គច្បាប់ដែរឬទេ? បើសិនមិនមានទេ ខ្ញុំនឹងសង្ខេបនូវចំណុចដែលលោកស្រីបានលើកឡើងពីខាងដើម។

អង្គជំនុំជម្រះមិនឲ្យលោកស្រីសន្យាថាលោកស្រីនឹងមិនប្តឹងសាទុក្ខ ឬក៏ធ្វើដាក់បណ្តឹងជំទាស់ចិត្តលើចៅក្រមណាមួយនោះទេ។ គ្រាន់តែឲ្យលោកស្រីនៅពេលនេះគឺបញ្ជាក់ទេ ហើយលោកស្រីបានលើកឡើងហើយថា លោកស្រីមិនដឹងថាត្រូវចាត់វិធានការតាមណានោះទេ។ ហើយដើម្បីផលប្រយោជន៍កូនក្តីរបស់លោកស្រី លោកស្រីថាពេលខ្លះអាចប្តឹងជំទាស់ចិត្ត។ ក៏ប៉ុន្តែចំណុចហ្នឹងវាអាចមានការពន្យារពេលបើសិនជាមានបណ្តឹងបែបហ្នឹង។ នេះជា -- មិនមែនជាការទទួលខុសត្រូវរបស់លោកស្រីនោះទេ វាជាពាក់ព័ន្ធទៅបញ្ហានីតិវិធី។

[១៤:១៧:១០]

ខ្ញុំសូមសួរលោកស្រី តើមានបញ្ហាអង្គច្បាប់ណាផ្សេងទៀត ដែលលើកឡើងពាក់ព័ន្ធទៅនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២នោះទេ ដែរឬទេ? សូមលើកឡើងប្រសិនបើមាន។

**កញ្ញា អង់តា ហ្គីសសេះ**

លោកស្រីចៅក្រម ភាគីផ្សេងទៀតគេនឹងផ្តល់យោបល់លើចំណុចនេះ។ ប៉ុន្តែចំពោះខ្ញុំទាក់ទងទៅនឹងចំណុចច្បាប់មួយ ដែលយើងកំពុងពិភាក្សានេះ យកជាមូលហេតុនៃការបង្កើតក្រុមជំនុំជម្រះទី២នេះគឺថាមានតែមាត្រា៣(៨)ហ្នឹងទេ ហើយពេលក្រោយ ពេលវេលាសមស្របខ្ញុំនឹងធ្វើការកត់សម្គាល់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ លោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ក្រុមមេធាវីការពារក្តី នួន ជា តើលោកមានចំណុចអង្គច្បាប់ណាមួយចង់លើកឡើងពាក់ព័ន្ធទៅនឹងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២ដែរឬទេ?

[១៤:១៨:០៦]

**លោក វិចទ័រ កូប៉េះ**

សូមអរគុណលោកស្រីចៅក្រម ខាតវ៉ាយថ៍ ខ្ញុំលើកឡើងខ្លីទេ។ ខ្ញុំយើងខ្ញុំយល់ឃើញថាយោបល់បឋមរបស់ខ្ញុំ គឺខ្ញុំយល់ឃើញថាគ្មានឧបសគ្គផ្លូវច្បាប់ក្នុងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២នោះទេ។ បញ្ហាមួយ គឺពាក់ព័ន្ធទៅនឹងនៅពេលដែលតែងតាំងចៅក្រមថ្មីនោះវាអាចមានបញ្ហាលម្អៀងកើតឡើង។ ដូច្នេះ ចំណុចហ្នឹង គឺវាមានពាក់ព័ន្ធនឹងការជំនុំជម្រះដោយផ្ទាល់តែប៉ុណ្ណោះ។ ត្រឡប់ទៅខាងដើមវិញ យើងខ្ញុំមិនឃើញមានការប្រឈម ឬក៏ការឧបសគ្គណាមួយក្នុងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២នោះទេ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សំណួរបន្ត ខ្ញុំគិតថាចៅក្រម ឡាវ៉ែន៍ ក៏មានសំណួរផងដែរ។ លោកបានលើកឡើងថា អាចមានលេចឡើងអំពីបញ្ហាលម្អៀង។ បញ្ហានេះជាបញ្ហាលើកឡើងតាំងពីដើមមក ហើយភាគីក៏បានលើកឡើងដែរ តុលាការកំពូលក៏បានលើកឡើងផងដែរ។ ក៏ប៉ុន្តែនៅក្នុងសេចក្តីសម្រេចលើកទី២ តុលាការកំពូលមិនបានលើកឡើងចំណុចនេះសាជាថ្មីនោះទេ។ ហើយតើលោកមានបានឃើញថា ការដែលមិនបាន

លើកឡើងនៅក្នុងសេចក្ដីសម្រេចទី២នេះជាចំណុចខកខានមួយធ្ងន់ធ្ងរដែរឬទេចំពោះលោក?

**លោក វ៉ិចទ័រ កូប៉េ៖**

ដូចជាមិនធ្ងន់ធ្ងរអ្វីនោះទេ។ ចំពោះយើងខ្ញុំជាមេធាវីការពារក្ដី យើងគ្រាន់តែចង់ដឹងថាតើចៅក្រមថ្មីទាំងប្រាំនោះគឺនរណាគេ? ប្រសិនបើយើងយល់ឃើញថា ចៅក្រមមួយ ឬក៏ពីរចេញមកពីហ្នឹងវាអាចលេចឡើងអំពីបញ្ហាលម្អៀង បញ្ហាអនាគតិ។ ក៏ប៉ុន្តែនៅពេលនេះប្រសិនបើយើងមិនទាន់ស្គាល់ឈ្មោះផងនោះ ដូច្នេះតើធ្វើម្ដេចយើងដឹងទៅ? ហើយយើងក៏មិនមានបញ្ហាណាមួយត្រូវលើកឡើងនោះផងដែរ។ ហើយចំពោះការខកខានមិនលើកឡើងក្នុងសេចក្ដីសម្រេចទី២ របស់តុលាការកំពូលមិនមែនជាបញ្ហាអ្វីធ្ងន់ធ្ងរនោះទេសម្រាប់យើងខ្ញុំ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍!

[១៤:២០:១៩]

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

បាទសូមអរគុណលោកប្រធាន។

បើតាមខ្ញុំយល់អំពីអ្វីដែលលោកស្រី ហ្គីសសេ បាននិយាយ គឺថាគាត់មិនទាន់ច្បាស់លាស់នៅឡើយទេនៅក្នុងដំណាក់កាលនេះទាក់ទងនឹងក្របខ័ណ្ឌច្បាប់ដែលយើងតែងតាំងក្រុមប្រឹក្សាជំនុំជម្រះថ្មី។ ខ្ញុំយល់ថាមានការអាល់អែកនៅពេលនេះ ព្រោះថាយើងអាច-- សួរថាតើលោកប្រធាននេះអាចតែងតាំងចៅក្រមបម្រុង ឬក៏ចៅក្រមពេញសិទ្ធិដែរឬទេ? គឺថាមាននៅក្នុងមាត្រា៣(៨) នេះចែងសម្រាប់តែចៅក្រមបម្រុងទេ។ ហើយនៅក្នុងកិច្ចព្រមព្រៀងនេះ គឺថាមានតែអង្គជំនុំជម្រះមួយទេដែលមានសមាសភាពចៅក្រមពេញសិទ្ធិប្រាំ មិនមែនចៅក្រម១០រូបទេ។ អ៊ីចឹងតើនេះឬការកំណត់សម្គាល់របស់លោកស្រី? បាទខ្ញុំសូមសួរសំណួរហ្នឹងទៅក្រុម នួន ជា ផងដែរ។ តើលោកយល់ឃើញថាចៅក្រមត្រូវតែតែងតាំងចៅក្រមបម្រុង ឬក៏ចៅក្រមពេញសិទ្ធិនោះ ពីព្រោះថាលោកឆ្លើយអម្បាញ់មិញថាអត់មានបញ្ហាអ្វីទេ។ អ៊ីចឹងលោកសូមបញ្ជាក់មើល៍ ថាតើឱ្យតែងតាំងចៅក្រមពេញសិទ្ធិ ឬក៏ចៅក្រមបម្រុង? ហើយខ្ញុំនឹងផ្ដល់វេទិកាទៅភាគីផ្សេងទៀតផងដែរ ដើម្បីឱ្យគាត់បញ្ចេញមតិត្រង់ចំណុចនេះ។

[១៤:២១:៥២]

**លោក វ៉ិចទ័រ កូប៉េះ**

ចៅក្រម លោកចៅក្រម ឡាវែន៍ ចំពោះយើងខ្ញុំគឺវាដូចគ្នា ខ្ញុំយល់អ្វីដែលបានលើកឡើងពាក់ព័ន្ធទៅនឹងការតែងតាំងចៅក្រម ហ្វេនស៍ នោះក៏អាចក្លាយទៅជាសមាជិកមួយរូបនៅក្នុងក្រុមប្រឹក្សាជំនុំជម្រះទី២ថ្មីនោះផងដែរ ដោយសារលោកស្រីដឹងរឿងច្រើន។ ហើយវាអាចដែលថាមិនចាំបាច់តែងតាំងចៅក្រមបម្រុងទាំងអស់ទេ អាចចៅក្រមពីអង្គជំនុំជម្រះផ្សេងក៏អាចតែងតាំងមកបានដែរ។ នៅចុងក្រោយនោះ គឺយើងគ្រាន់តែឲ្យចៅក្រមហ្នឹងគឺថាមានជាសមាសភាពហ្នឹងអាចដោះស្រាយរឿងក្ដីបានទៅលើរឿងក្ដីលើកូនក្ដីរបស់ខ្ញុំ។ ហើយថាតើលទ្ធភាព ឱកាសតែងតាំងហ្នឹងដោយរបៀបណា គឺយើងខ្ញុំនោះមិនជាខ្វល់ខ្វាយខ្លាំងទេ។ យើងមិនគិតឃើញថាមានឧបសគ្គផ្លូវច្បាប់ក្នុងការតែងតាំងជាចៅក្រមបម្រុង ឬក៏ចៅក្រមពេញសិទ្ធិយកមកនោះទេ។ ក្របខ័ណ្ឌយោងរបស់យើង គឺនៅពេលដែលតែងតាំងមកនោះវាអាចលេចឡើងអំពីបញ្ហាលម្អៀង ហើយនេះជាអ្វីដែលយើងមើលឃើញថាវាអាចកើតអ៊ីចឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

អ៊ីចឹងគឺថាត្រង់ចំណុចនេះ គឺថាលោកយោងទៅលើមាត្រា៣(៨)។ លោកយល់អ៊ីចឹង ឬយ៉ាងក៏ម៉េច តាមរយៈការយោងទៅលើមាត្រាហ្នឹង ឬក៏យ៉ាងម៉េច?

[១៤:២៣:៣១]

**លោក វ៉ិចទ័រ កូប៉េះ**

និយាយឲ្យត្រង់ទៅនៅក្នុងការពិភាក្សានេះ ថាតើចៅក្រមណាមួយដែលនឹងដោះស្រាយរឿងក្ដីកូនក្ដីរបស់ខ្ញុំ។ ហើយជាទូទៅ ខ្ញុំចាំមើលសិនថាតើនរណាគេជាចៅក្រម។ ហើយខ្ញុំមិនដឹងថាតើចៅក្រមមួយរូប ឬក៏ច្រើនជាងមួយរូបអាចមានភាពលម្អៀង។ ខ្ញុំក៏មិនទាន់ដឹងដែរ និយាយឲ្យត្រង់ទៅគឺខ្ញុំមិនមានអ្វីច្រើនត្រូវលើកឡើងអំពីឱកាស ឬលទ្ធភាពដែលប្រធានអង្គជំនុំជម្រះថ្មីហ្នឹងនឹងដើរតាមផ្លូវណានោះទេ។ ហើយចំពោះខ្ញុំ បញ្ហាហ្នឹងដូចជាខ្ញុំមិនមានអ្វីព្រួយបារម្ភនោះទេ។ ហើយយើងខ្ញុំរង់ចាំមើលសិន តើនៅពេលដែលសាងសង់ស្ថានហើយនោះ ថាតើខ្ញុំនឹងគិតឃើញថាត្រូវដើរតាមផ្លូវណា។ ប្រសិនបើនៅពេលក្រោយតែងតាំងហើយមានភាពលម្អៀងនោះ គឺថាយើងខ្ញុំនឹងលើកបញ្ហាហ្នឹងឡើង។ ហើយចំពោះយើងខ្ញុំគឺចង់ឲ្យបានចៅក្រមណាមួយកុំឲ្យមានការជ្រៀតជ្រែក ឬក៏ពាក់ព័ន្ធនឹងសេចក្ដីសម្រេចនាពេលមុនៗ ជាពិសេសកុំឲ្យមានចៅក្រមណាដែលអាចលេចឡើងអំពីបញ្ហាលម្អៀងណាមួយ។

[១៤:២៤:៤៧]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអម្បាញ់មិញនេះ ខ្ញុំភ្លេចចំណុចមួយនៅក្នុងអ៊ីម៉ែលដែលខ្ញុំបានផ្ញើទៅអង្គជំនុំជម្រះហ្នឹង គឺបញ្ហាហៅថា ការបង្កើតក្រុមប្រឹក្សាថ្មីឬក៏អត់? យើងមិនយល់ថា -- គោលជំហរយើងតាំងពីដើមមក គឺថាយើងៗមិនដឹងថា បង្កើតការជម្រះវគ្គទី២យ៉ាងម៉េចទេ បើមិនទាន់មានសេចក្ដីសម្រេចសាលក្រមទី១នេះផង។ ខ្ញុំសូមពន្យល់មូលហេតុនេះ។ ក្រុមខ្ញុំពេលមួយនោះ -- យើងកាលពេលមួយនោះ ខ្ញុំនៅចាំនៅឡើយទេ។ អង្គាល់ប្រជុំរៀបចំសវនាការលើកមុននោះ ខាងសហព្រះរាជអាជ្ញាក៏មានគោលជំហរដូចយើងដែរ គឺថាអង្គាល់ដែលយើងនិយាយអំពីសំណុំរឿង០០២/០២នេះ គឺថាយើងទាំងអស់គ្នាត្រូវចាំសាលក្រមចេញសិន ព្រោះថាធ្វើអ៊ីចឹងយើងអាចចេញធ្វើដំណើរការទៅមុខលឿន គឺថាមានបញ្ហា គឺថា ឧទាហរណ៍ដូចជា ទម្រង់ទំនួលខុសត្រូវ ដែលសំខាន់ណាស់ ហើយដែលនឹងអាចប៉ះពាល់ទៅលើរបៀបជម្រះសេចក្ដីលើកទី២ ហើយទាក់ទងទៅនឹងវិសាលភាពផង។

អ៊ីចឹងនេះជាគោលជំហរផ្លូវច្បាប់របស់ខ្ញុំ ហើយខ្ញុំមិនដឹងថាយើងនៅទីនេះនិយាយពីច្បាប់ ឬក៏ពីនយោបាយ ឬក៏ផ្នែកហិរញ្ញវត្ថុពីសំណាក់អ្នកផ្ដល់ជំនួយមកយើងនេះទេ។ បើយើងនិយាយពីច្បាប់ យើងគិតពីច្បាប់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

[១៤:២៦:៤០]

**លោកស្រី បេនី យេះ**

សូមអរគុណ។ ខ្ញុំ បេនី យេ ខ្ញុំនិយាយក្នុងនាមសហមេធាវីនាំមុខអន្តរជាតិដែលមិនមានវត្តមាននៅក្នុងថ្ងៃនេះ។ នៅពេលនេះ ខ្ញុំសូមបង្ហាញជំហររបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធទៅនឹងបញ្ហាចោទ ដែលថាតើគួរតែតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២ ដែរឬទេ? នៅក្នុងការយល់ឃើញរបស់ខ្ញុំក្រុមជំនុំជម្រះទី២ មិនចាំបាច់នោះទេ។ យើងមិនគាំទ្រក្នុងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២ នេះឡើយ។

ជាបឋមពាក់ព័ន្ធទៅនឹងអំណាចរបស់លោកប្រធានក្នុងការចាត់តាំង តែងតាំងចៅក្រមពីបេក្ខជនបម្រុង ឬក៏ចៅក្រមថ្មីនោះ ខ្ញុំ យើងខ្ញុំយល់ឃើញថា ការបកស្រាយដោយតុលាការកំពូលត្រង់មាត្រា៣មានលក្ខណៈសង្ស័យច្រើន។ ទោះបីយើងអនុវត្តតាមការបកស្រាយនេះក៏ដោយ ពាក្យពេចន៍នៅក្នុងនោះ

គឺនិយាយអំពីក្រុមប្រឹក្សាជំនុំជម្រះដែលមានចៅក្រមប្រាំរូប ដូចដែលចៅក្រម ឡាវែន៍ និងលោកប្រធានបានលើកឡើង។ ទោះបីជាយើងអនុវត្តតាមការបកស្រាយនេះក៏ដោយ ហើយយើងសន្មតថាប្រធានមានអំណាចក្នុងការចាត់តាំង ឬតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២ក៏ដោយ តុលាការកំពូលត្រូវតែផ្តល់ឆន្ទានុសិទ្ធិឲ្យលោកប្រធានធ្វើការតែងតែងនៅក្នុងករណីចាំបាច់ទាក់ទងទៅនឹងផលប្រយោជន៍យុត្តិធម៌។

យើងខ្ញុំយល់ឃើញថា ផលប្រយោជន៍យុត្តិធម៌ គឺមិនឲ្យមាន -- មិនតម្រូវឲ្យមានក្រុមប្រឹក្សាជំនុំជម្រះទី២នោះទេ។ ហើយដោយសារតែវាមិននាំឲ្យការជំនុំជម្រះនេះដំណើរការទៅលឿននោះឡើយ។ តាមការស្តាប់ឮនៅព្រឹកមិញ ការជ្រើសរើសចៅក្រមថ្មី និងបុគ្គលិកថ្មីសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះទី២ត្រូវការពេល ចំណាយពេលច្រើនណាស់។ ចំពោះចៅក្រមជាតិ យើងបានស្តាប់ឮរួចមកហើយទោះបីជាពួកគាត់ដកស្រង់ ដកចេញមកពីចៅក្រមបម្រុងក៏ដោយ ក៏តម្រូវឲ្យមានព្រះរាជក្រឹត្យតែងតាំងពួកគាត់សាជាថ្មី។ ចំពោះអន្តរជាតិវិញ ធ្វើយ៉ាងណាធានាថា អ្នកបេក្ខជននៅក្នុងបញ្ជីដែលមាននៅក្នុងដៃរបស់អគ្គលេខាធិការ ធ្វើយ៉ាងណាពួកគាត់នោះទាល់តែទំនេរ ហើយអាចមកចូលរួមបាន។

[១៤:២៨:៥៩]

ចំពោះបុគ្គលិកគាំទ្រវិញ ការជ្រើសរើស នីតិវិធីជ្រើសរើស តម្រូវតាំងតែពីការប្រកាសរកបុគ្គលិក រហូតមកដល់ការសម្ភាស និងការជ្រើសរើសពួកគាត់ ហើយចំពោះបុគ្គលិកបណ្តោះអាសន្នដែលដូចដែលលើកឡើងដោយការិយាល័យរដ្ឋបាលនោះ គឺតម្រូវអាចឲ្យយើងប្រើប្រាស់តែមួយរយៈពេលខ្លីនេះ បុគ្គលិកប្រភេទហ្នឹង គឺមិនមែនជម្រើសល្អនោះឡើយ។ ប្រសិនយើងធ្វើដូច្នេះ គឺថាតម្រូវឲ្យយកបុគ្គលិកផ្សេងទៀតមកជំនួស ប្រសិនបើបុគ្គលិកបណ្តោះអាសន្ននេះគាត់ចាកចេញទៅក្នុងពេលដែលជំនុំជម្រះ។ ដូច្នេះវាធ្វើឲ្យយើងពន្យារពេលយើងបន្ថែមទៀត។ ដូច្នេះសរុបទៅវាមិនមែនជាការធ្វើឲ្យដំណើរការលឿនទេ ប្រសិនបើក្រុមប្រឹក្សាជំនុំជម្រះទី២ យើងនឹងបង្កើតនោះ។ ទី២ វាមិនមានប្រសិទ្ធភាពទៀត ដោយសារតែក្រុមប្រឹក្សាទី២នេះ ត្រូវធ្វើយ៉ាងណាឲ្យខ្លួនយល់នូវសម្ភារៈឯកសារនានាដែលមាននៅក្នុងសំណុំរឿង ០០២/០១ ដូចដែលសហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់អំពីចឹង។ ចំណុចហ្នឹង វានាំឲ្យអូសបន្លាយពេលវេលាយឺតដដែល។

ទី២ ប្រសិនបើក្រុមប្រឹក្សាទី២ អាចបង្កើតឡើងមែន បានន័យថាបង្កើតតែរយៈពេលមុនសាលក្រមតែបន្តិច មុនចេញសាលក្រមតែបន្តិចនោះ គឺក៏វាមិនមានអ្វីដែលជាមានប្រសិទ្ធភាពឲ្យលឿននោះដែរ។ យើងគិតថា យើងមិនត្រូវការក្រុមប្រឹក្សាជំនុំជម្រះទី២នោះទេ។ យើងចង់ឲ្យក្រុមប្រឹក្សាជំនុំជម្រះ

បច្ចុប្បន្ននេះជាអ្នកជំនុំជម្រះវគ្គទី២ ឲ្យបានលឿនតាមដែលអាចធ្វើទៅបាន។ បានន័យថា យើងគួរតែចាប់ផ្ដើមជំនុំជម្រះឲ្យបានលឿនទៅ។ ជាពិសេសការកំណត់ទៅលើវិសាលភាពនៃបទល្មើសបញ្ជីសាក្សី។ ហើយបន្ទាប់មកយើងនឹងធ្វើការជំនុំជម្រះលើអង្គសេចក្ដីតែម្ដងទៅ ក្រោយពេលដែលចេញសាលក្រម។ ទាំងអស់នេះ គឺជាយោបល់របស់យើងខ្ញុំ។ ខ្ញុំសូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណច្រើនណាស់ លោកស្រីមេធាវី។

ចុះលោក គង់ សំអុន? សូមអញ្ជើញបាទ!

[១៤:៣១:១៨]

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គប្រជុំ។

ខ្ញុំសូមនិយាយដោយខ្លី ត្រង់ជំហរទាក់ទងទៅនឹងការបង្កើតអង្គជំនុំជម្រះទី២ ដែលតាមសំណើរបស់លោកប្រធានឲ្យពិនិត្យទៅលើធនធានដែលមានស្រាប់នេះ គឺយើងខ្ញុំយល់ឃើញថាមិនអាចធ្វើទៅបានទេ។ វាពុំមានច្បាប់ណាដែលអាចអនុញ្ញាតឲ្យអង្គ -- លោកប្រធានអង្គជំនុំជម្រះសាលាដំបូងនេះចាត់តាំងចៅក្រមដែលមានសមត្ថភាពនៅក្នុងអង្គជំនុំជម្រះផ្សេងទៀត។ ឧទាហរណ៍ដូចជានៅតុលាការកំពូល ឬក៏នៅអង្គបុរេជំនុំជម្រះនោះទេ។

ការចាត់ដោយប្រធានអង្គជំនុំជម្រះពេលនេះ ទំនងជាអាចធ្វើទៅបាន ដោយមិនគិតទៅលើបញ្ហាច្បាប់ដែលមានស្រាប់ទេ ប៉ុន្តែតាមរយៈធ្វើវិសោធនកម្មផ្សេងៗដែលត្រូវចាត់ចែងដោយ អាចជាប្រធានតុលាការកំពូល ឬក៏តាមរយៈនយោបាយ មិនមែនតាមរយៈយើងខ្ញុំដែលជាមេធាវីការពារក្ដីនោះទេ។ លើកលែងតែក្នុងករណីដែលប៉ះពាល់ដល់សិទ្ធិរបស់កូនក្ដីខ្ញុំ។ អ៊ីចឹង យើងអាចស្នើទៅប្រធានតុលាការ ឬក៏ទៅរដ្ឋសភា ដែលជាតំណាងរាស្ត្រដើម្បីស្នើសុំវិសោធនកម្ម។ អានេះជាកិច្ចដែលយើងអាចធ្វើតាមរយៈស្ថាប័នជាតិធំៗដែលមានស្រាប់ក្នុងការធ្វើវិសោធនកម្ម។ ប៉ុន្តែជំហររបស់យើងគឺមិនមានចេតនាចង់បង្កើតឲ្យមានអង្គជំនុំជម្រះណាមួយថែមទៀត ដើម្បីជំនុំជម្រះលោក ខៀវ សំផន នេះទេ។ វាអត់មានអីចាំបាច់ទេ។ នេះវាជាការងារនយោបាយ ឬក៏ជាការងារដោយឡែក មិនមែនជាការទទួលខុសត្រូវរបស់យើង។

[១៤:៣៣:១៦]

ខ្ញុំបានស្តាប់ឮការឆ្លើយបញ្ជាក់របស់ការិយាល័យរដ្ឋបាល ទាក់ទងទៅនឹងថវិកា ក៏ដូចជាធនធានមនុស្ស ថាមានគ្រប់គ្រាន់ ថាមិនមែនជាចំណោទ។ បញ្ហានេះ ខ្ញុំនៅតែមានការសង្ស័យជាលក្ខណៈផ្ទាល់ខ្លួន។ ហើយដោយឡែកទាក់ទងទៅនឹងលទ្ធភាពក្នុងការធ្វើវិសោធនកម្ម ទាំងកិច្ចព្រមព្រៀង ក៏ដូចជាច្បាប់ដែលមានស្រាប់នេះ ខ្ញុំយល់ថាមិនមែនជាការងាយស្រួលប៉ុន្មានទេ ពីព្រោះវាត្រូវមានស្ថាប័នធំៗផ្សេងទៀត ដែលពាក់ព័ន្ធ គឺមានតាំងអង្គការសហប្រជាជាតិ រាជរដ្ឋាភិបាល និងរដ្ឋសភា។ ហើយទោះបីជាតុលាការកំពូលរបស់យើងនេះបានស្នើទៅរដ្ឋសភាដើម្បីឱ្យមានការធ្វើវិសោធនកម្មក៏ដោយ វាត្រូវការចំណាយពេលវេលាដែរ។ ហើយបើយើងប្រៀបធៀបរយៈពេលដែលតុលាការសាលាដំបូងបច្ចុប្បន្ននេះ អាចនឹងធ្វើដំណើរការនូវសំណុំរឿង០០២/០២បាននោះ គឺថាអាចនៅក្នុងខែ៦ ឆ្នាំ២០១៤នេះ។ អ៊ីចឹងសួរថាតើតុលាការអង្គជំនុំជម្រះទី២ ដែលនឹងបង្កើតនេះ អាចបង្កើតបាននៅក្នុងខែ៥ ឆ្នាំក្រោយនេះដែរទេ? ឬក៏អាចបង្កើតបាននៅខែ១ ឆ្នាំក្រោយនេះ? បាទ អ៊ីចឹងរយៈពេលដែលយើងមើលឃើញពីលទ្ធភាពដែលអង្គជំនុំជម្រះទី២ នឹងអាចបង្កើតបាននេះ គឺក៏វារយៈពេលហ្នឹងវាយូរដែរ។ គឺត្រូវចំណាយពេលវេលាដែរ។ អ៊ីចឹង ការព្យាយាមដើម្បីឱ្យមានអង្គជំនុំជម្រះទី២ទៀតនេះ វាអាចពុំមានប្រយោជន៍ច្រើនប៉ុន្មានទេ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើនលោកមេធាវី នូវមតិយោបល់នេះ។ ហើយឥឡូវនេះដល់ពេលសម្រាកសមល្មមសម្រាកហើយ។ ឥឡូវនេះយើង -- មានមតិយោបល់? បាទ សូមអញ្ជើញបាទ!

[១៤:៣៥:១៧]

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន! ខ្ញុំសូមឱ្យលោកប្រធានសួរបញ្ជាក់បំភ្លឺពីខាងមេធាវី គង់ សំអុន។ ខ្ញុំសូមសួរថាចំពោះមេធាវី ខៀវ សំផន លើកឡើងថា ពួកគាត់មិនជឿថា -- គាត់លើកឡើងថាគួរតែឱ្យការជំនុំជម្រះវគ្គទី២នេះចាប់ផ្តើមឡើងនៅពេលដែលមានសាលក្រមស្ថាពរនៅលើវគ្គទី១។ តើគាត់ចង់សំដៅលើសាលក្រមស្ថាពរ ឬក៏សាលដីកាស្ថាពរ? សូមឱ្យមេធាវីការពារក្តីធ្វើការបញ្ជាក់បំភ្លឺបានដែរឬទេ តើអ្វីដែល -- ប្រសិនបើតុលាការធ្វើការរកឃើញបទចោទចំពោះមេធាវីចំពោះកូនក្តីរបស់គាត់នោះថាតើវាជាគុណប្រយោជន៍សម្រាប់គាត់ ឬក៏ជាផលវិបាកសម្រាប់គាត់? ទាំងអស់នេះគឺជាចំណុចទាំងឡាយដែលខ្ញុំចង់សួរ។ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីគាត់លើកឡើងថា ការជំនុំជម្រះវគ្គពីរគួរតែចាប់ផ្តើម

ក្រោយពេលចេញសាលក្រម។ ដូច្នេះតើគាត់គិតថាគួរដោះស្រាយយ៉ាងម៉េច ដែលតុលាការកំពូលគាត់លើកឡើងថាមិនអាចចាំប្រាំបីខែ ឲ្យមានសាលក្រមវគ្គទី១សិនបានចាប់ផ្ដើមនោះទេ។ បើមិនដូច្នោះទេគឺវានឹងនាំឲ្យមានការដោះលែងទៅដល់ជនជាប់ចោទ ហើយសូមឲ្យមេធាវីទាំង ខៀវ សំផន និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីបញ្ជាក់បំភ្លឺទៅលើចំណុចទាំងអស់នេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក គង់សំអុន អាចឆ្លើយបំភ្លឺបានទេ? សូមអញ្ជើញបាទ។

[១៤:៣៦:៥៧]

**លោក គង់ សំអុន៖**

បាទ សូមអរគុណ។ ជាជំហររបស់យើងគឺថា ជារួមយើងចង់បានសាលក្រមចូលជាស្ថាពរមួយមុននឹងបន្តសំណុំរឿង០០២។ នេះជាចំណុចដំបូងដែលយើងធ្វើការតវ៉ារយៈពេលកន្លងមក។ ប៉ុន្តែចម្លើយរបស់ខ្ញុំអម្បាញ់មិញនេះខ្ញុំឆ្លើយតបទៅនឹងលទ្ធភាពនៃការបង្កើតអង្គជំនុំជម្រះទី២ ដែលយើងកំពុងតែពិភាក្សានេះ។ បានន័យថាចំណុចនៃការទាមទាររបស់ក្រុមមេធាវីការពារលោក ខៀវ សំផន ទៅលើការជំទាស់ក្នុងការដំណើរការនីតិវិធីសំណុំរឿង០០២/០២ នោះនៅតែជាការទាមទាររបស់យើងដដែលទេ។ ក៏ប៉ុន្តែខ្ញុំពិនិត្យទៅលើផលប្រយោជន៍ផ្នែកយុត្តិធម៌ដែលគិតថា តើសំណុំរឿង០០២/០២នេះ វាមានប្រយោជន៍អ្វីខ្លះនៅពេលដែលតុលាការមួយផ្សេងទៀត ឬក៏អង្គជំនុំជម្រះមួយផ្សេងទៀតដែលត្រូវបានបង្កើតឡើងដើម្បីពិនិត្យទៅលើសំណុំរឿង០០២នេះ ហើយដែលខ្ញុំបានពិនិត្យមើលទៅលើពេលវេលានៃការបង្កើតរបស់ -- លទ្ធភាពនៃការបង្កើតរបស់អង្គជំនុំជម្រះទី២នេះ វាហាក់ដូចជាពុំមានលទ្ធភាពណាដែលអាចធ្វើឲ្យបានឆាប់រហ័សនោះទេ។ ហើយទោះបីជាអង្គជំនុំជម្រះទី២នេះ ត្រូវបានបង្កើតឡើងក៏ដោយ ក៏ការតវ៉ា ការទាមទាររបស់យើងដើម្បីឲ្យពិនិត្យទៅលើការធានាសិទ្ធិរបស់លោក ខៀវ សំផន នៅតែមានជាធរមាន។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ហើយចុះលោកស្រីមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី?

**លោកស្រី បេនី យេៈ**

សូមអរគុណលោកប្រធាន។ ដើម្បីបញ្ជាក់បំភ្លឺនូវអ្វីដែលខ្ញុំបានលើកឡើង ជំហររបស់មេធាវីដើមបណ្ដឹងរដ្ឋប្បវេណីយើងគាំទ្រសវនាការរៀបចំការជំនុំជម្រះវគ្គទី២នេះឲ្យបានលឿនតាមដែលអាច

ធ្វើទៅបាន។ ហើយក្រោយពេលចេញសាលក្រមនោះគឺយើងចាប់ផ្ដើមសវនាការលើអង្គសេចក្ដីតែម្ដងទៅ។ ការដែលយើងរៀបចំសវនាការ រៀបចំមុនពេលចេញសាលក្រមនេះវាអាចឲ្យយើងរៀបចំបញ្ជីសាក្សី បញ្ជីអ្នកជំនាញ និងឲ្យយើងអាចត្រៀមខ្លួនសម្រាប់សំណុំរឿង០០២/០២។ ដូច្នេះ ការធ្វើដូច្នេះវាស្ថិតនៅក្នុងអំឡុងពេលប្រាំបីខែ ដែលកំណត់ដោយតុលាការកំពូលថាឲ្យធ្វើសវនាការក្នុងអំឡុងពេលហ្នឹង មិនឲ្យរង់ចាំឲ្យហួសពីប្រាំបីខែនោះទេ។

[១៤:៣៩:៣៨]

**លោក ពេជ អង្គុះ**

បាទ ខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម អង្គប្រជុំសាជាថ្មី។ ខ្ញុំសូមបញ្ជាក់បន្ថែមបន្តិចទៅលើគោលជំហររបស់មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងពេលវេលានៃការចាប់ផ្ដើមទៅលើសវនាការទៅលើសារធាតុ លើភស្តុតាង។

ជាការពិតយើងអាច -- នេះជាលទ្ធភាពមួយដែលលើកឡើងដោយលោកស្រី បេនី យេ ដែលថាសវនាការទៅលើភស្តុតាងនេះអាចចាប់ផ្ដើមបន្ទាប់ពីមានសាលក្រមរួចហើយ។ ក៏ប៉ុន្តែក៏អាចមានលទ្ធភាពមួយទៀត ដែលមានមេធាវីជាច្រើនដែលយើងបានពិភាក្សាជាមួយគ្នា ហើយភាគច្រើនយល់ថាប្រសិនបើអាចធ្វើឆាប់បាន យើងសវនាការទៅលើសារធាតុ -- ទៅលើភស្តុតាងនេះក៏ចាប់ផ្ដើមមុនពេលដែលមានសាលក្រមផងដែរ។ បាទខ្ញុំសូមបញ្ជាក់។ មានន័យថា ក្នុងករណីបើសិនសាលក្រមអាចមានខែមិថុនា សវនាការទៅលើភស្តុតាងអាចចាប់ផ្ដើមមុនពេលនោះផងដែរ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ឥឡូវនេះដល់ពេលសមស្របសម្រាកហើយ សម្រាកចាប់ពីពេលនេះទៅរហូតដល់ម៉ោងបីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចប្រជុំពិភាក្សារបស់យើង។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤១ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:១៩]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកប្រធាន ខ្ញុំសូមលើកឡើងដោយខ្លីទេ ដើម្បីឲ្យយើងច្បាស់ទាំងអស់គ្នាពាក់ព័ន្ធនឹងអ្វីដែលបានលើកឡើងដោយមេធាវីការពារក្តីលោក ខៀវ សំផន។ មេធាវីការពារក្តី ខៀវ សំផន បានបញ្ជាក់ថាខ្លួនមើលទៅថាមិនឃើញថាអាចចាប់ផ្តើមសវនាការបន្តបន្ទាប់បានទេដរាបណាសវនាការ០០២/០១នោះមិនទាន់ចប់ជាស្ថាពរនោះ។ ប្រហែលជាអ្នកច្បាប់នៅទីនេះមិនមានប្រព័ន្ធច្បាប់ដូចគ្នា។ អ៊ីចឹងប្រហែលជាពួកគាត់មិនសូវយល់ ដូច្នេះសូមឲ្យមេធាវីការពារក្តីបញ្ជាក់ឲ្យបានច្បាស់អំពីដែលថា អម្បាញ់មិញនេះថាទាល់តែមានការសម្រេចជាស្ថាពរហើយនោះ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកចៅក្រម ឡាវែន៍ គឺថាសាលក្រមស្ថាពរគឺសំដៅថាមានការសម្រេចនៅពេលដែលមានការប្តឹងឧទ្ធរណ៍ គឺថាសាលក្រមដែលសម្រេចអំពីបញ្ហាសំខាន់ៗទាំងអស់ពាក់ព័ន្ធទៅនឹងទម្រង់នៃការទទួលខុសត្រូវរបស់ជនជាប់ចោទ គឺពាក់ព័ន្ធទៅនឹងការដែលបានលើកឡើងដោយខាងមេធាវីការពារក្តីលោក ខៀវ សំផន។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០៥:៥០]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ឥឡូវនេះចូលទៅរបៀបវារៈទី២ ការពិភាក្សាអំពីបែបបទរដ្ឋបាលសម្រាប់ការរៀបចំសវនាការក្នុងសំណុំរឿង០០២/០២។ របៀបវារៈទី២នេះគឺពាក់ព័ន្ធទៅនឹងបញ្ហារដ្ឋបាលនៃការរៀបចំសវនាការក្នុងសំណុំរឿង០០២/០២។ ហើយអង្គជំនុំជម្រះសូមដាក់សំណួរទាំងនេះទៅឯកឧត្តមប្រធាន និងលោកអនុប្រធានការិយាល័យរដ្ឋបាល របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។ សំណួរនេះនឹងជួយដល់យើងខ្ញុំជាប្រធានអង្គជំនុំជម្រះសាលាដំបូង ក្នុងការកំណត់លទ្ធភាពផ្សេងៗក្នុងការតែងតាំងក្រុមប្រឹក្សាជំនុំជម្រះទី២។

អង្គជំនុំជម្រះក៏បានកត់សម្គាល់ផងដែរថា ក្រុមមេធាវីការពារក្តីទាំងពីរក្រុមក៏បានបញ្ជាក់រួចមកហើយថាខ្លួនមានការបារម្ភអំពីមួយចំនួន អំពីបញ្ហាមូលនិធិសម្រាប់ផ្នែកការពារក្តី។

ខ្ញុំសូមអញ្ជើញឯកឧត្តមប្រធាន និងលោកអនុប្រធានការិយាល័យរដ្ឋបាលអត្ថាធិប្បាយបញ្ជាក់ត្រួសៗផងដែរអំពីរចនាសម្ព័ន្ធថវិកា អ.វ.ត.ក សម្រាប់រយៈពីរឆ្នាំ គឺពីឆ្នាំ១៩១៤ រហូតដល់ឆ្នាំ -- ពីឆ្នាំ

២០១៤ រហូតដល់ឆ្នាំ២០១៥។ ព្រមទាំងការវិវត្តន៍ពាក់ព័ន្ធទៅនឹងស្ថានភាពនៃការអនុម័តទៅលើថវិកានេះ។ ជាពិសេស តើឯកឧត្តមប្រធាន និងលោកអនុប្រធានអាចពិភាក្សាអំពីស្ថានភាពហិរញ្ញវត្ថុរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដោយរួមបញ្ចូលទាំងការសន្យា និងការផ្តល់ជំនួយដែលបានធ្វើរួចមកហើយ ព្រមទាំងកិច្ចខំប្រឹងប្រែងនានារបស់តុលាការក្នុងការស្វែងរកមូលនិធិទាំងក្នុងពេលបច្ចុប្បន្នក៏ដូចជានៅពេលអនាគតដើម្បីធានាឲ្យមានមូលនិធិគ្រប់គ្រាន់សម្រាប់ដំណើរការនេះយ៉ាងណាដែរ?

[១៥:០៧:៥០]

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទសូមអរគុណលោកប្រធាន និងសូមគោរពសភាទាំងមូលជាថ្មីម្តងទៀតបាទ។ ពាក់ព័ន្ធទៅលើនីតិវិធីនៃការតាក់តែងថវិកា ជាទម្លាប់ថវិកា អ.វ.ត.ក យើងត្រូវបានតាក់តែងសម្រាប់ពីរឆ្នាំម្តងៗ។ ២០១៤-២០១៥ អ.វ.ត.ក ត្រូវបានតាក់តែងយោងទៅតាមសកម្មភាព ហើយដែលក្រោយពីមានការពិគ្រោះយោបល់ជាមួយផ្នែកទាំងអស់ ហើយនិងជាមួយសភាដែលមាននៅក្នុង អ.វ.ត.ក ទាំងអស់។ អ៊ីចឹងខ្ញុំបាទបានគម្រោងថវិការួមជាមួយនឹងដៃគូអន្តរជាតិរបស់យើង។ យើងបានទៅញូវយ៉កពីខែ១០ដើម្បីដាក់ជូន អ្វីដែលយើងហៅថាប្រទេសផ្តល់ជំនួយធំៗ –*ប្រាំងស៊ីប៉ាល់ ដូន័រគ្រុប*។ ឥឡូវនេះនីតិវិធីនៅកំពុងនៅក្នុងដៃរបស់ប្រទេសផ្តល់ជំនួយធំៗទាំងអស់នោះ លោកកំពុងពិចារណា មានសំណួរកែកុនតិចតួច។ ហើយយើងសង្ឃឹមថានឹងត្រូវបានអនុម័តឆាប់ៗនេះ ខែ១២ ឬដើមខែ១នេះ។ ឥឡូវនេះនៅត្រឹមដំណាក់កាលកំពុងពិចារណា ហើយនិងកំពុងសម្រិតសម្រង់ សម្រួចជាចុងក្រោយពីសំណាក់នៃប្រទេសផ្តល់ជំនួយធំៗ។

[១៥:០៩:០៦]

ក្រៅពីហ្នឹង ការសន្យាហើយ ការសន្យាជាក់ស្តែង គឺថាខ្ញុំបាទទៅប្រជុំនៅញូវយ៉កនោះ អត់ទាន់មានការសន្យាជាក់ស្តែងថា មាន ឬមិនទាន់មានទេ។ ដោយគេយោងថា គេចាំអនុម័តជាស្ថាពរនូវថវិកាហ្នឹងសិន។ ហើយប្រទេសមួយចំនួនបាននិយាយថាគាត់មិនអាចសន្យាឥឡូវហ្នឹងមុននឹងការអនុវត្តថវិកាទេដោយហេតុថាប្រទេសផ្ទាល់ខ្លួនរបស់គាត់ហ្នឹងក៏កំពុងតែមមាញឹកធ្វើថវិកាផ្ទាល់ខ្លួនរបស់ផងដែរបាទ។ មានតែកម្ពុជាទេដែលបានសន្យារួចហើយនៅពេលនោះ តាមតំណាងរបស់រដ្ឋាភិបាលឯកឧត្តមកែវ រ៉េមី លោកបានចូលរួមជាតំណាងរបស់រដ្ឋាភិបាល បានទៅបង្ហាញពីសមិទ្ធផលនៃអ.វ.ត.ក ហើយ

ក៏បានប្រកាសផងដែរនៅពេលប្រជុំនៅញូវយ៉កនោះថា រដ្ឋាភិបាលនៅសន្យា និងគាំទ្រដដែលលើបញ្ហាថវិកាបដិភាគដែលគ្រប់គ្រង ដែលពាក់ព័ន្ធទៅនឹងដំណើរទូទៅនៃសាលាក្តីរបស់យើងបាទ។

អ៊ីចឹងក្រៅពីនេះ ស្ថានភាពបច្ចុប្បន្នសព្វថ្ងៃគឺដំណាក់កាលនេះ គឺយើងរង់ចាំការអនុម័តថវិកាដើម្បីនឹងប្រទេសផ្តល់ជំនួយធំៗលោកមានលទ្ធភាពប្រកាសសន្យាក្នុងកម្រិតណាមួយនោះ ទី១។ ទី២ ដោយខ្ញុំសូមផ្សាភ្ជាប់ទៅនឹងសំណើ -- ចម្លើយទី២ ទន្ទឹមនឹងនេះ ឆ្នាំនេះក៏ដោយហេតុថា អ.វ.ត.ក យើងចំណុះដោយថវិកាស្ម័គ្រចិត្តពីប្រទេសផ្តល់ជំនួយធំៗនោះ តែងតែមានបញ្ហាកង្វះសាច់ប្រាក់ជារឿយៗ ជាពិសេសភាគីជាតិនៃ អ.វ.ត.ក យើង។ ឆ្នាំនេះលោក ឯកឧត្តមអគ្គលេខាធិការនៃអង្គការសហប្រជាជាតិធ្វើសំណើទៅគណៈកម្មាធិការទី៥ ដើម្បីសូមឱ្យមានយន្តការមួយទៀត យន្តការថ្មីមួយដែលអាចធានានូវការឧបត្ថម្ភធននៅពេលណាដែលយើងប្រឈមនឹងបញ្ហាកង្វះសាច់ប្រាក់ដូចសព្វដងនេះបាទ។

[១៥:១១:១២]

ហើយការងារនេះកំពុងតែមមាញឹកសិក្សា មានការឆ្លើយឆ្លងគ្នាជាពិសេសរវាងកម្ពុជាយើងគាំទ្រលើគោលការណ៍នៃយន្តការថ្មីនេះ ដើម្បីធានានិរន្តរភាពការងាររបស់ អ.វ.ត.ក ហើយនិងកំពុងតែមានការពិភាក្សាគ្នាយ៉ាងមមាញឹកជាមួយប្រទេសដែលពាក់ព័ន្ធនឹងអង្គការសហប្រជាជាតិនៅអ្វីដែលគេហៅថា គណៈកម្មាធិការទី៥ នៃអង្គការសហប្រជាជាតិ។ ចំពោះចំណុចចុងក្រោយនេះ ខ្ញុំនឹងសូមជូនវេទិកាជូនលោក លោក ឃ្លុត សម្រាប់លោកអត្ថាធិប្បាយឱ្យបានក្បោះក្បាយជាងហ្នឹងទៅលើយន្តការដែលកំពុងតែដាក់ជូននៅគណៈកម្មាធិការទី៥ នៅអង្គការសហប្រជាជាតិផងដែរ។

បាទ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណឯកឧត្តម។

សូមអញ្ជើញឯកឧត្តមអនុប្រធានការិយាល័យរដ្ឋបាល!

[១៥:១២:១៧]

**លោក ឃ្លុត រ៉ូសាន់ហោក៖**

សូមអរគុណលោកប្រធាន។ យើងមានបញ្ហាពីរ៖ ទី១ គឺដំណើរការថវិកា, បញ្ហាទី២ គឺស្ថានភាពផ្តល់មូលនិធិ។ ដូច្នេះយើងត្រូវបំបែកឱ្យឃើញខុសគ្នារវាងប្រធានបទទាំងពីរនេះ។ ទី១ គឺថវិកាដូចដែលខ្ញុំនិយាយ វាគឺជាដំណើរការរួមរវាងខាងការិយាល័យរដ្ឋបាលជាមួយនឹងផ្នែក ឬក៏អង្គភាពនានារបស់

តុលាការ។ ហើយខាងការិយាល័យរដ្ឋបាលបានដាក់បង្ហាញនូវសំណើថវិការបស់យើង ដែលជាពង្រាង នៅឡើយទៅទីក្រុងញូវយ៉កនៅខែវិច្ឆិកា ហើយក្នុងពេលបច្ចុប្បន្ននេះ គម្រោងថវិកានេះត្រូវបានពិភាក្សា ក្នុងចំណោមប្រទេសផ្តល់ជំនួយ ហើយឥឡូវហ្នឹងមានការសួរចោទគ្នាទៅវិញទៅមករវាងខាងការិយា-ល័យរដ្ឋបាលជាមួយនឹងប្រទេសផ្តល់ជំនួយនៅឡើយ។ ក្នុងពេលបច្ចុប្បន្នហ្នឹងគឺថាខាងរដ្ឋបាលព្យាយាម ស្វែងរកចម្លើយពីខាងអង្គភាពនានារបស់តុលាការ។ ដូច្នេះឥឡូវនេះ យើងកំពុងស្ថិតនៅក្នុងដំណើរការ រៀបចំថវិកា។ គឺថាយើងទាំងពីរនាក់បានចូលរួមនៅក្នុងកិច្ចប្រជុំផ្តល់ជំនួយនៅខែវិច្ឆិកា ហើយប្រទេស ផ្តល់ជំនួយបានបញ្ជាក់ថា គេនៅតែគាំទ្រ នៅតែជួយដល់តុលាការ ហើយប្រទេសផ្តល់ជំនួយទាំងអស់ គឺ ចូលរួមយ៉ាងសកម្មនៅក្នុងការបែងចែកថវិកាទាំងអស់នោះ។ ដូច្នេះ គឺថាប្រទេសទាំងអស់នោះគឺបាន ប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លា ប៉ុន្តែពួកគេមិនទាន់បានបញ្ជាក់ឲ្យបានច្បាស់ថា តើគេនឹងជួយឧបត្ថម្ភប៉ុន្មាន នោះទេ។

[១៥:១៣:០៣]

យើងត្រូវយល់ថា នៅពេលដែលយើងទទួលបាននូវការអនុម័តទៅលើថវិកា យើងត្រូវស្វែងរក ថវិកា។ ឥឡូវនេះ គឺយើងដឹងទាំងអស់គ្នាហើយថវិកាដែលឧបត្ថម្ភមក អ.វ.ត.ក គឺតាមរយៈមូលដ្ឋាន ស្ម័គ្រចិត្ត។ យើងខុសពីតុលាការនៅទីក្រុងឡាអេ គឺថាតុលាការឡាអេ នៅពេលដែលគេទទួលបានការ អនុម័តថវិកា គឺគេបានលុយតែម្តង ប៉ុន្តែចំពោះយើងគឺផ្សេងពីនេះ។ ឥឡូវនេះ គឺថាយើងនិយាយបន្ថែម បន្តិចថា តើថវិកាហ្នឹងវាមានលក្ខណៈបែបណាហើយនៅពេលដែលយើងកំពុងតែនិយាយនៅពេលឥឡូវ នេះ។ គឺថាលោក ឯកឧត្តមប្រធានប្រហែលជាគាត់អាចបញ្ជាក់ពីខាងជាតិ ខ្ញុំនិយាយពីខាងអន្តរជាតិ។ គឺថាផ្អែកទៅលើការប្តេជ្ញាចិត្តនៅក្នុងកិច្ចប្រជុំកន្លងមកនេះ គឺថាយើងព្យាយាមស្វែងរកថវិកាឲ្យបាននៅ ក្នុងថ្ងៃ០១ មករា ២០១៤ គឺឲ្យបាន ២,៧លានដុល្លារ។ ហើយនេះគឺជាការពង្រីកបន្ថែម ដើម្បីឲ្យយើង អាចពន្យារកិច្ចសន្យាបន្ថែមទៀត សម្រាប់បុគ្គលិកខាងអង្គការសហប្រជាជាតិឲ្យបីខែតទៅមុខទៀត។ បន្ថែមពីលើនេះ គឺថាយើងមានការប្តេជ្ញាចិត្តពីខាងអ្នកផ្តល់ជំនួយចំនួន៤លានដុល្លារនៅដើមឆ្នាំក្រោយ។ ដូច្នេះឥឡូវនេះ ហ្នឹងគឺយើងមាន២,៧លាន បូកនឹង៤លាន។ នេះគឺជាលុយដែលយើងមានក្នុងដៃតែម្តង។ ហើយសកម្មភាពស្វែងរកថវិកាមួយទៀត គឺធ្វើឡើងរួមដោយឯកឧត្តមប្រធានស្តីទី គឺយើងស្នើសុំឲ្យ មានការអន្តរាគមន៍ដែលអគ្គលេខាធិការអង្គការសហប្រជាជាតិ បានស្នើសុំឲ្យមានកញ្ចប់ថវិកាពិសេស មួយ។ ដំណើរការទាំងអស់នេះ គឺថាមានការឈប់ ឬក៏មានដំណាក់កាលបី។ ទី១ គឺដំណាក់កាលរបស់

អ្នកជំនាញ ដែលយើងហៅថា អេ.ស៊ី.អេ.អ៊ី។ គឺថាកម្មាធិការនេះបានពិនិត្យទៅលើសំណើសុំអន្តរាគមន៍ ហើយបានដាក់ចូលទៅក្នុងកម្មាធិការហិរញ្ញវត្ថុរបស់មហាសន្និបាតអង្គការសហប្រជាជាតិ។

[១៥:១៦:៤២]

នៅពេលដំបូង គឺយើងមានការស្ម័គ្រចិត្តផ្តល់ ១២,៦លាន រហូតមកដល់នេះ គឺ១២,៦លាន មកឲ្យ អ.វ.ត.ក យើងនេះ។ ហើយមានការប្រជុំនៅក្នុងគណៈកម្មាធិការទី៥របស់ អេ.ស៊ី.អេ.ប៊ី.យូ ដែលជាគណៈកម្មាធិការមួយរបស់សម្រាប់មហាសន្និបាតអង្គការសហប្រជាជាតិ។ នៅក្នុងពេលឥឡូវនេះគេកំពុងតែពិភាក្សាអំពីសំណើសុំអន្តរាគមន៍កញ្ចប់ថវិកាពិសេសនោះ។គឺថាឲ្យមានការកញ្ចប់ថវិកាពិសេសពេញតែម្តង ដើម្បីឧបត្ថម្ភដល់ខាង អ.វ.ត.ក យើងនេះ។ គឺថាជាកញ្ចប់ថវិកាដែលឧបត្ថម្ភឡើងដោយអង្គការសហប្រជាជាតិ ជំនួសឲ្យការផ្តល់ជាបែបស្ម័គ្រចិត្តនោះ។ គណៈកម្មាធិការទី៥ មិនទាន់បានបញ្ចប់ការពិភាក្សានៅឡើយទេ។ ហើយគណៈកម្មាធិការនេះនឹងបន្តរហូតទៅដល់ពេលយប់នេះ ម៉ោងស្រុកខ្មែរយើងនេះ។ ដូច្នេះ អានេះអ្វីដែលបានបន្តដំណើរទៅមុខ ហើយយើងសង្ឃឹមថា យើងទទួលលទ្ធផលជាវិជ្ជមានក្នុងពេលឆាប់ៗនេះ។ ប្រសិនបើអនុសាសន៍នេះវាទទួលបានការអនុម័ត ហើយសម្រេចទៅមុខ គឺយើងមានថវិកាយ៉ាងតិចបំផុតក៏១២លាន សម្រាប់ចំណាយរបស់យើង។ ហើយយើងដឹងថា យើងខាងអន្តរជាតិ យើងចំណាយប្រហែលជា២លានក្នុងមួយខែ។ ដូច្នេះ យើងនឹងអាចបន្តរហូតដល់ពាក់កណ្តាលឆ្នាំក្រោយ។ ប្រសិនបើកញ្ចប់ថវិកាពិសេសត្រូវបានអនុម័តយក គឺយើងទទួលបានការឧបត្ថម្ភទាំងស្រុងតែម្តង រហូតទៅដល់ដាច់ឆ្នាំក្រោយ ទាំងសម្រាប់ភាគីទាំងពីរតែម្តង។

[១៥:១៨:៣៦]

ដូច្នេះ ប្រសិនបើការបង្កើតកញ្ចប់ថវិកាពិសេសនេះមិនមានការរារាំង ឬក៏មិនមានការអ្វី គឺយើងនឹងអាចសម្រេចទៅបាន។ គឺមានលក្ខខណ្ឌគ្រប់គ្រាន់។ ប៉ុន្តែយ៉ាងក៏ដោយ ខាងអង្គការសហប្រជាជាតិក៏ដូចជារាជរដ្ឋាភិបាលកម្ពុជា ត្រូវមានកាតព្វកិច្ចស្វែងរកថវិកាបន្ថែមទៀត។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ សូមអរគុណចំពោះឯកឧត្តមប្រធានស្តីទី និងលោកអនុប្រធាន។

ខ្ញុំគិតសាលាដំបូងបានដឹងអំពីដំណាក់កាលទាំងពីរដែលយើងកំពុងតែពិភាក្សា ដែលយើងបានលើកឡើងនៅក្នុងកិច្ចប្រជុំរៀបចំសវនាការទី១ គឺដំណើរការថវិកា។ ទី២ គឺយើងហៅថា កញ្ចប់ថវិកាពិសេសនោះឯង។ ខ្ញុំចង់សួរសំណួរពីរបីបន្ថែមទៀត ទាក់ទងទៅនឹងថវិកា គឺដំណើរការថវិកាយើង។ លោកបានបញ្ជាក់ច្បាស់រួចមកហើយ ថាសំណើថវិកាព្រាងដែលបានលើកឡើងដោយឯកឧត្ដម និងលោក គឺមិនទាន់ត្រូវបានអនុម័តនៅឡើយ គឺថាវាកំពុងតែស្ថិតនៅក្នុងដំណាក់កាលជាធម្មតាមួយ។ ហើយត្រូវឲ្យមានការអនុម័តពីប្រទេសផ្ដល់ជំនួយដោយត្រូវធ្វើការត្រួតពិនិត្យជាលម្អិត។ ដូច្នេះ ខ្ញុំចង់សួរលោកថា តើអ្វីដែលលោកបានបញ្ជាក់ជាមួយសាលាដំបូងពាក់ព័ន្ធទៅនឹងបុគ្គលិក ឬក៏តួនាទីដែលលោករក្សាទុកសម្រាប់សាលាដំបូងនោះ ព្រោះថាប្រទេសផ្ដល់ជំនួយចង់ឲ្យមានការកាត់បន្ថយថវិកា១,២លាន។ ដូច្នេះថាតើ -- យើងដឹងច្បាស់ហើយថាមានការកាត់ថវិកា ២លាន -- ដូច្នេះតើលោកអាចដឹងថាមានការកាត់បន្ថយពីអង្គជំនុំជម្រះដទៃទៀត ឬក៏ថវិកាអ្វីបន្ថែមទៀតពីផ្នែកដទៃទៀតដែរឬទេ? អានេះគឺជាសំណួរទី១ដែលខ្ញុំចង់សួរលោក។

[១៥:២១:០៤]

**លោក ឃ្នុត វ៉ូសាន់ហោក៖**

សូមអរគុណលោកស្រីចៅក្រម។ ខ្ញុំបានបញ្ជាក់រួចហើយការពិភាក្សាកំពុងបន្តហើយយើងមានការ -- យើងទទួលបានសំណើពីប្រទេសផ្ដល់ជំនួយដើម្បីឲ្យមានការកាត់បន្ថយ ២លានដុល្លារ។ គឺកាត់បន្ថយពីថវិការបស់ភាគីទាំងពីរ ទាំងជាតិ ទាំងអន្តរជាតិ។ យើងមិនទាន់បានផ្ដល់ចម្លើយជាស្ថាពរទៅខាងប្រទេសផ្ដល់ជំនួយនោះទេ ព្រោះយើងកំពុងតែពិភាក្សានៅក្នុងតុលាការ។ ប៉ុន្តែសួរថាតើយើងអាចមានការកាត់បន្ថយ ឬក៏មានបញ្ហាអ្វីទេ? យើងសូមឆ្លើយថា បាទ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ឥឡូវនេះដោយសារតែមានការពិភាក្សាបន្តទៅមុខទៀតទាក់ទងទៅនឹងថវិកាបែបនេះ លោកបានជម្រាបប្រាប់យើងថា លោកមានការប្ដេជ្ញាម៉ឺងម៉ាត់ថា ត្រឹមខែមករា ឆ្នាំក្រោយ ហើយនិងពេលក្រោយមកទៀតគឺលោកនឹងទទួលបាន ៦,៧ លានដុល្លារ។ នៅពេលដែលលោកនិយាយថាមានការអះអាងមានការប្ដេជ្ញាពិតប្រាកដ ថាតើលោកចង់មានន័យយ៉ាងដូចម្ដេចដែរ? ព្រោះថាពេលខ្លះនៅពេលដែលមានការប្ដេជ្ញាយ៉ាងម៉ឺងម៉ាត់នោះមិនមែនបានន័យថា គេឲ្យលុយភ្លាមៗនោះទេ។ ដូច្នេះតើលោកចង់និយាយមានន័យយ៉ាងម៉េចដែរនៅពេលដែលលោកនិយាយថា មានការប្ដេជ្ញាយ៉ាងម៉ឺងម៉ាត់នោះ? ថាតើវាគ្រាន់តែជា

ការអះអាង ឬក៏ជាការប្តេជ្ញានោះដែលមិនមែនមានន័យថាជាការឲ្យលុយភ្លាមៗនោះទេ។ ខ្ញុំសួរបែបនេះព្រោះថា អង្គជំនុំជម្រះសាលាដំបូងដឹងថាតុលាការកំពូលគាត់ព្រួយបារម្ភដោយសារតែគាត់គិតថាសាលាដំបូងព្យាយាមមិនធ្វើតាមសាលាកំពូលដោយសារតែលើកហេតុផលថវិកាជាដើម។ ហេតុដូច្នេះហើយទើបខ្ញុំលើកសំណួរបែបនេះឡើងមកសួរលោក ព្រោះថាយើងមានបញ្ហាពិតប្រាកដជាក់ស្តែងជាពិសេសគឺទាក់ទងទៅនឹងការផ្អាក ឬការពន្យារដល់ដំណាក់កាលនីតិវិធីដោយសារតែបញ្ហាថវិកានេះឯង។

ដូច្នេះគឺថាយើងចង់ឲ្យមានការរៀបចំឲ្យបានច្បាស់លាស់សម្រាប់ក្រុមប្រឹក្សាជំនុំជម្រះទៅពេលខាងមុខ។ ដូច្នេះខ្ញុំចង់ឲ្យលោកបញ្ជាក់ច្បាស់ ថាតើពាក្យថា "ការអះអាងម៉ឺងម៉ាត់"នោះមានន័យថាម៉េចមានន័យថាមានលុយក្នុងធនាគារឬ?

[១៥:២៣:៣០]

**លោក ឃ្លុត វ៉ូសាន់ហោក៖**

"ការអះអាងយ៉ាងម៉ឺងម៉ាត់" គឺបានន័យថាជាការសន្យាពីរដ្ឋ។ វាមិនមែនមានន័យថាជាការផ្ទេរលុយទៅខាងអង្គការសហប្រជាជាតិនោះទេ ប៉ុន្តែខ្ញុំមិនមានការឆ្ងល់នោះឡើយ ព្រោះថាការអះអាងម៉ឺងម៉ាត់នោះនឹងមានការផ្ទេរលុយ។ ខ្ញុំសូមបញ្ជាក់បន្ថែមទៀតថា នៅក្នុងតុលាការនេះនៅពេលដែលលោកស្រីនិយាយគឺថា ការរារាំង ឬក៏ការអាក់ខានថវិកាគឺមិនមានការកើតឡើងចំពោះអង្គការសហប្រជាជាតិនោះទេគឺមានតែខាងជាតិប៉ុណ្ណោះ។ ដូច្នេះហើយខ្ញុំចង់បញ្ជាក់ថា នេះគឺជាការសន្យារបស់ប្រទេសផ្តល់ជំនួយ ហើយនៅពេលដែលប្រទេសផ្តល់ជំនួយសន្យា គឺតែងតែមានការផ្ទេរលុយមក។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ឥឡូវនេះមុននឹងយើងបន្តទៅបញ្ហាទីពីរ ខ្ញុំចង់និយាយថាជាឯកសារអន្តរាគមន៍នោះ ខ្ញុំចង់ឲ្យលោកបញ្ជាក់ច្បាស់ថា តើមានថវិកាសង្គ្រោះបន្ទាន់ដែរឬទេ ក្នុងករណីដែលតុលាការកំពុងតែដំណើរការ។ ឧទាហរណ៍ថា នៅពេលដែលមានក្រុមប្រឹក្សាជំនុំជម្រះទី២ គឺថាតម្រូវឲ្យមានការងារបន្ថែមតម្រូវឲ្យមានបុគ្គលិកបន្ថែម ក្នុងរយៈពេលហោចណាស់ក៏ត្រឹមប្រាំមួយខែដើមឆ្នាំក្រោយនោះ។ ថាតើយើងមានថវិកាសង្គ្រោះបន្ទាន់ ដែលយើងមាននៅក្នុងដៃ ឬក៏មានថវិកាដទៃទៀតដែលតម្រូវឲ្យមានការអនុម័តសិននៅក្នុងដំណើរការកំណត់ថវិកា។ ដូច្នេះ ចង់ដឹងថាតើលោកមានថវិកាសង្គ្រោះបន្ទាន់ចំនួនប៉ុន្មានដែរសម្រាប់ភាគីទាំងពីរ?

**លោក ឃ្លុត រ៉ូសាន់ហោក៖**

ថវិកាសង្គ្រោះបន្ទាន់ស្ថិតនៅក្នុងដំណើរការកំណត់ថវិកា។ ហើយយើងមិនអាចប្រមើលមើលឃើញនៅឆ្នាំក្រោយ ព្រោះថាយើងមិនមានអ្វី -- ប៉ុន្តែនេះយើងមានជាចំនួនសរុបរួមតែម្តង។ ប្រសិនបើលោកស្រីចង់សួរខ្ញុំបញ្ជាក់ថា ខាងអង្គការសហប្រជាជាតិគឺ ១,៨ ហើយនិង ១,៦ ខាងភាគីជាតិ។

[១៥:២៥:៥៣]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

ដូច្នេះ លោករំពឹងថា នឹងមានការអនុម័តទៅលើថវិកាសង្គ្រោះបន្ទាន់ ប៉ុន្តែអត់ទាន់មានអនុម័តជាផ្លូវការនៅឡើយទេ?

**លោក ឃ្លុត រ៉ូសាន់ហោក៖**

បាទ ពិតហើយលោកស្រីចៅក្រម។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយច៍៖**

លោកប្រធានខ្ញុំសូមអនុញ្ញាតបន្តទៅមុខបន្តិចទាក់ទងទៅនឹងបញ្ហាសង្គ្រោះអន្តរាគមន៍ ដែលមានស្នើសុំឲ្យមាន -- ទាក់ទងទៅនឹងអនុសាសន៍របស់គណៈកម្មាធិការ អេ.ស៊ី.អេ.ប៊ី.ឃ្យូ របស់ក្រុមប្រឹក្សាអង្គការសហប្រជាជាតិ ដែលបានឯកសារកញ្ចប់ថវិកាពិសេសនោះ គឺដោះស្រាយជាមួយនឹងបញ្ហាទាំងអស់ ក៏ដូចជាថវិកាមួយចំនួនដែលផ្តល់ឲ្យ។ ប៉ុន្តែយើងមិនអាចដោះស្រាយជាមួយបញ្ហាទាំងអស់ដែលយើងអាចជួបប្រទះនោះឡើយ។ គឺថាយើងមិនអាចដោះស្រាយទៅលើបញ្ហាអាចនឹងដែលរារាំងទៅការជំនុំជម្រះទាំងអស់បាននោះឡើយ។

[១៥:២៧:០៣]

ខ្ញុំបានសង្កត់ធ្ងន់រួចមកហើយថា មានតែចៅក្រមអន្តរជាតិប៉ុណ្ណោះតែអាចពិនិត្យមើលទៅលើឯកសារនេះបាន ពីព្រោះវាមានតែជាភាសាអង់គ្លេសតែប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំចង់ឲ្យលោកបកស្រាយទៅលើកថាខណ្ឌ៤២ ដែលឯកសារបាននិយាយថា "អគ្គលេខាធិការអង្គការសហប្រជាជាតិ ដូច្នេះស្នើឲ្យតាមឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការទាញយកនូវថវិកាកញ្ចប់ពិសេស ដើម្បីជួយឧបត្ថម្ភទៅលើខាងភាគីជាតិនៅក្នុងស្ថានភាពមួយ ដែលថាត្រូវឧបត្ថម្ភទូទាត់សងមកវិញ ដើម្បីទូទាត់ថវិកាដល់ប្រាក់ខែបុគ្គលិកជាតិដោយមិនគិតទៅដល់មន្ត្រីតុលាការ"។

ដូច្នេះកន្លងមកគឺមានការរំខានជាច្រើនដងរួចមកហើយ ដោយសារតែថវិកាមិនអាចទូទាត់ដល់

ប្រាក់ខែបុគ្គលិកបាន។ ដូច្នេះ អ្វីដែលចៅក្រមខ្ញុំមិនចង់និយាយ ប៉ុន្តែគាត់បាន -- ប៉ុន្តែខ្ញុំត្រូវតែនិយាយនោះ គឺថាចៅក្រមជាតិក៏មិនទទួលបានការទូទាត់ប្រាក់ខែនៅឡើយទេ។ ដូច្នេះប្រសិនបើកន្លងមកទៀតគឺថវិកា --គឺថាចៅក្រមជាតិមិនទាន់ទទួលបានប្រាក់ខែនៅឡើយ។ ហើយនៅក្នុងកញ្ចប់ថវិកាពិសេសហ្នឹងក៏មិនបាននិយាយអំពីការទូទាត់ ដែលចៅក្រមតុលាការដូចដែរ។

ដូច្នេះខ្ញុំចង់សួរថា ឯកឧត្តមប្រធានស្តីទី និងលោកអនុប្រធានអាចបញ្ជាក់អះអាងបានដែរឬទេថានឹងមិនមានការរារាំងដោយសារតែមិនមានការទូទាត់ថវិកាដល់មន្ត្រីតុលាការនោះ?

[១៥:២៨:៥៥]

**លោក ឃ្លុត វ៉ូសាន់ហោក៖**

ខ្ញុំសូមបញ្ជាក់បន្ថែមទៅលើអ្វីដែលបានស្នើឡើងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ គឺផ្អែកទៅលើមាត្រា១៥នៃកិច្ចព្រមព្រៀង ដែលបញ្ជាក់អំពីកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា។ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិយល់ឃើញថា មាត្រាទី១៥ គឺបានបញ្ជាក់ថាសំណើសុំកញ្ចប់ថវិកាពិសេសគឺត្រូវតែមានកំណត់បែបនេះ ហើយបញ្ជាក់ថាមន្ត្រីតុលាការ មន្ត្រីចៅក្រមគឺជាមន្ត្រីរបស់រដ្ឋបាភិបាល។ ដូច្នេះ ដោយសារតែមន្ត្រីតុលាការគាត់មានទំនាក់ទំនងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល ដូច្នេះគឺរាជរដ្ឋាភិបាលជាអ្នកទទួលខុសត្រូវ។

បន្ថែមពីលើនេះទៀត អ្នកតំណាងរបស់រាជរដ្ឋាភិបាលកម្ពុជាបានបញ្ជាក់អំពីសំណើដែលស្នើឲ្យដាក់បញ្ចូលមន្ត្រីតុលាការហ្នឹងទៅក្នុងកញ្ចប់ថវិកាពិសេស។ ប៉ុន្តែយើងមិនដឹងថាតើលទ្ធផលដែលទទួលបានវាមានលក្ខណៈយ៉ាងដូចម្តេចនោះទេ។ សូមអរគុណលោកស្រីចៅក្រម។

[១៥:៣០:១២]

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទខ្ញុំសូមបញ្ជាក់ពីលើចំណុចនេះ។ ខាងតំណាងរាជរដ្ឋាភិបាលពិតជាបានធ្វើសំណើទៅគណៈកម្មការទី៥ហ្នឹងសូមឲ្យដកពាក្យដែលថាមិនពាក់ព័ន្ធនឹងមន្ត្រីចៅក្រមតុលាការ។ ក៏ប៉ុន្តែសេចក្តីសម្រេចចុងក្រោយយ៉ាងណាមិញ យើងអត់ទាន់ដឹង។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

មានសំណួរបន្ថែមមួយទៀត ប្រសិនជាអនុញ្ញាតឲ្យខ្ញុំចោទសួរ។ ឯកសារកញ្ចប់ថវិកាពិសេសនេះ គឺថាសរសេរយោងទៅលើមន្ត្រីតុលាការផងដែរ ដែលអង្គជំនុំជម្រះសាលាដំបូងពិចារណាថាវាអាច

ពាក់ព័ន្ធទៅនឹងការរអាក់រអួលសវនាការក្នុងពេលបច្ចុប្បន្ន ឬអនាគត។ តើមានមន្ត្រីណាមួយទៀតផ្សេងទៀតដែលរដ្ឋាភិបាលជាអ្នកទទួលបន្ទុកលើបញ្ហាប្រាក់ខែដែរឬទេ? ឧទាហរណ៍ថាការិយាល័យរដ្ឋបាលនោះថាតើអាចទទួលរងផលប៉ះពាល់ដោយសារបញ្ហាហ្នឹងដែរឬទេ ហើយវាអាចជួបប្រទះនូវកញ្ចប់ប្រាក់ខែដែរឬទេ? ខ្ញុំសួរនេះដើម្បីឲ្យដំណើរការថវិកានេះ វាអាចគាំទ្រជារលូនទៅដល់តុលាការនេះ។

[១៥:៣១:៤០]

**ឯកឧត្តម ក្រាញ់ តូនី៖**

ខ្ញុំបាទសូមទោស ខ្ញុំស្ដាប់អត់ទាន់សំណួរ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ខ្ញុំសូមអធ្យាស្រ័យ។ ខ្ញុំសួរឡើងវិញ។ នៅក្នុងឯកសារស្ដីអំពីកញ្ចប់ថវិកាពិសេស ព្រោះវាបានបង្ហាញថាវាត្រូវបានយកទៅពិភាក្សានៅក្នុងគណៈកម្មាធិការទី៥។ សញ្ញាណនៃក្របខ័ណ្ឌថវិកាថ្មីដែលត្រូវបានគេយកពិចារណានោះ គឺគេមិនក្ដោបបញ្ចូលរួមទាំងចៅក្រមជាតិដូចដែលបានបញ្ជាក់អម្បាញ់មិញនោះទេ។ តើមានបុគ្គលិកមន្ត្រីណាផ្សេងទៀតក្រៅពីចៅក្រមនៅក្នុងការិយាល័យរដ្ឋបាលដែលនឹងមិនទទួលបានប្រាក់ខែ ឬក៏កាលពីអតីតកាលនេះ គាត់មិនទទួលបានប្រាក់ខែ ឬក៏ការដែលមិនទទួលបានប្រាក់ខែហ្នឹងគឺមានតែចៅក្រមតែប៉ុណ្ណោះ? តើមានមន្ត្រីណាផ្សេងទៀតដែរឬទេ ដែលមិនទាន់បានទទួលបានប្រាក់ខែ ដោយសារតែអង្គការសហប្រជាជាតិចាត់ទុកថាអ្នកទាំងអស់នោះជាប្រាក់ខែរបស់គាត់ទាំងអស់នោះទទួលខុសត្រូវដោយរដ្ឋាភិបាល? ហើយការដែលខ្ញុំសួរដូច្នេះ គឺដើម្បីឲ្យខាងរដ្ឋបាលហ្នឹងដឹងផង ដោយសារតែការិយាល័យរដ្ឋបាលមានតួនាទីក្នុងការធ្វើឲ្យរលូនទៅលើការងារប្រាក់ខែហ្នឹង។ អ៊ីចឹងក្រៅពីចៅក្រម តើមានមន្ត្រីណាផ្សេងទៀតនៅក្នុងការិយាល័យរដ្ឋបាលដែលមិនទាន់បានទទួលប្រាក់ខែដែរឬទេ?

[១៥:៣៣:១៩]

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទសូមអរគុណលោកស្រីចៅក្រម។ បញ្ហាប្រាក់ខែដែលមានការ -- អាចនិយាយថាមានការរើសអើងមិនឲ្យគិតគូរដល់ប្រាក់ខែមន្ត្រីច្បាប់ចៅក្រមហ្នឹង គឺចេញមកឆ្នាំនេះ ទី១។ បានសេចក្ដីថាឆ្នាំនេះបួន-ប្រាំខែមុននេះ ដោយសារយើងហ្នឹងមានកង្វះខាតសាច់ប្រាក់ក្នុងការបើកប្រាក់ខែដល់បុគ្គលិកខ្មែរទាំងអស់នោះ។ រាជរដ្ឋាភិបាល និង យូ.អិន បានឯកភាពគ្នាឲ្យមានការខ្ចីលុយ ខ្ចីថវិកាដើម្បីដោះស្រាយ

លើបញ្ហានេះ។ ហើយតាមខ្ញុំដឹង ដោយសារថវិកានេះមានភាពអាចថាមានលក្ខណៈមិនគ្រប់គ្រាន់ ក៏អង្គការសហប្រជាជាតិជាឯកតោភាគីបានស្នើសុំឲ្យមានការបើកប្រាក់ខែពីបុគ្គលិកចាប់ពីតូចដល់ធំ ហើយទុកឲ្យតែចៅក្រម មន្ត្រីច្បាប់នៅមួយឡែកសិន។ អាហ្នឹងតាមខ្ញុំយល់ មិនមានមូលហេតុអីជាក់លាក់ទេ តាមខ្ញុំយល់គឺជាមូលហេតុដោយសារប្រាក់វាមិនគ្រប់គ្រាន់។ ហើយទី២ ពាក់ព័ន្ធនឹងចំណុច៤២ ក្នុងរបាយការណ៍ដាក់នៅចំពោះមុខគណៈកម្មាធិការទី៥នេះ ពាក្យដែលថាប្រាក់ដែលអាចសុំមកសង្គ្រោះបន្ទាន់គឺជាប្រាក់ ជាលក្ខណៈឧបត្ថម្ភធននោះ *–ស៊ូវ៉េងស្យុង–* នោះគឺអាចស្នើមកបានដោយដាក់មន្ត្រីចៅក្រមដោយឡែក មិនដាច់ខាតទេ ពេលណាដែលទាមទារ *–អាស់ទីតឌីត–* តាមខ្ញុំនៅចាំ ខ្ញុំបានឃើញមាត្រានោះដែរ។

អ៊ីចឹងហើយក៏តាមតំណាងរដ្ឋាភិបាលនៅញូវយ៉ក តំណាងអចិន្ត្រៃយ៍យើងនៅញូវយ៉ក ក៏បានធ្វើសំណើជាផ្លូវការថាសុំឲ្យលុបពាក្យហ្នឹងចេញវិញទៅ កុំឲ្យមានការរើសអើងក្នុងការសុំថវិកាឧបត្ថម្ភធននេះបាទ។ ហើយ--

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

*(គ្មានការបកប្រែ)*

[១៥:៣៥:៣០]

**ឯកឧត្តម ក្រាញ់ តូនី៖**

ការិយាល័យរដ្ឋបាលកាលជំនាន់នោះ អត់មានពាក់ព័ន្ធទេ។ អត់មានៗមន្ត្រីណាពាក់ព័ន្ធក្រៅពីមន្ត្រីច្បាប់ និងចៅក្រមទេលើបញ្ហាជាក់ស្តែងនេះ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ចម្លើយចុងក្រោយអម្បាញ់មិញនេះ ខ្ញុំអាចសន្និដ្ឋាននិងយល់ថា បុគ្គលិកនៅក្នុងការិយាល័យរដ្ឋបាលផ្សេងទៀត គឺបានទទួលប្រាក់ខែគ្រប់ៗគ្នា។ បានន័យដែរឬទេ សម្រាប់តាំងពីមុនមកដល់ពេលនេះ? អ៊ីចឹងមានតែចៅក្រមជាតិតែប៉ុណ្ណោះដែលគាត់មិនទាន់ទទួលបានប្រាក់ខែ តើអ៊ីចឹងដែរឬទេ?

[១៥:៣៦:១៣]

**ឯកឧត្តម ក្រាញ់ តូនី៖**

អត់ទេ សូមទោសលោកស្រីចៅក្រម។ ឆ្នាំនេះ២០១៣ យើងមានថវិកាគ្រប់គ្រាន់សម្រាប់បើកប្រាក់ខែជូនមន្ត្រីបុគ្គលិកទាំងរដ្ឋបាល ទាំងមន្ត្រីចៅក្រមទាំងអស់។ យើងបានបើកជូនគាត់ប្រាក់ខែដែល

យើងខ្វះបីបួនខែនោះថ្មីៗនេះហើយ គឺអត់មានជំពាក់ប្រាក់ខែណាទេ។ ទាំងអស់គ្នាត្រូវបានបើកទាំងអស់ រួមទាំងមន្ត្រីច្បាប់ និងចៅក្រម ហើយយើងមានថវិកាគ្រប់គ្រាន់ដើម្បីបើកសម្រាប់ខែ១២ នេះ។ អ៊ីចឹង ទាំងអស់គ្នាអត់មានខ្វះ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណ។ ខ្ញុំសូមថ្លែងអំណរគុណឯកឧត្តម ដែលឯកឧត្តមជាអ្នក -- ដែលឯកឧត្តមមិនមែនជាអ្នកធ្វើសេចក្ដីសម្រេចថា ត្រូវបើកឲ្យអ្នកណាគេ ឬមិនបើឲ្យអ្នកណាគេនោះទេ គឺបានន័យថា បាទទូលទាំងអស់គ្នា។ មន្ត្រីច្បាប់ និងមន្ត្រីតុលាការ ស្ថានភាពរបស់គាត់ហ្នឹង គឺយើងព្រួយបារម្ភជាងគេ ដោយសារតែវាអាចពាក្យព័ន្ធទៅនឹងឯករាជ្យភាពរបស់មន្ត្រីតុលាការ។

ពួកគាត់គឺត្រូវដំណើរការទៅដោយមិនត្រូវមានការខ្វះខ្វាយរកមធ្យោបាយផ្សេងទៀត ដើម្បីយកមកផ្គត់ផ្គង់សម្រាប់ពួកគាត់នោះទេ។ តើបញ្ហានេះមានបានយកទៅពិភាក្សាផ្ទៃក្នុងនៅក្នុងការិយាល័យរដ្ឋបាលដែរឬទេ? ឬក៏មានបានយកបញ្ហាថា បញ្ហាហ្នឹងយកទៅពិភាក្សាជាមួយនឹងខាងភាគីពាក់ព័ន្ធខាងក្រៅទៀតដែរឬទេ?

[១៥:៣៧:៤៨]

**ឯកឧត្តម ក្រាញ់ តូនី៖**

បាទ អត់មានទេ គឺជាទូទៅបញ្ហាថវិកាខាងប្រាក់ខែជារួមទៅ ប្រាក់ខែរបស់បុគ្គលិកជាតិហ្នឹង គឺតែងតែមានប្រាក់មកយើង គឺយើងបើកប្រាក់ខែជូន ពេលខ្លះយើងបើកប្រាក់ -- ពេលខ្វះយើងបើកប្រាក់ចំនួនសមាមាត្រស្មើគ្នាផងមានពេលមួយនោះ ហើយអ្វីដែលចម្លែកហ្នឹង ដោយសារគេមានដាក់ឲ្យចៅក្រមដោយឡែកនោះ គឺជាអ្នកដែលឲ្យលុយយើងខ្ចី កាលជំនាន់នោះបាទ ហើយយើងក៏បានដោះស្រាយវិញមកដល់ពេលនេះ ដោយយើងមានទុនជួយសង្គ្រោះបន្ទាន់ពីសំណាក់រាជរដ្ឋាភិបាលដែលបានផ្ដល់ថវិកាចុងក្រោយ ១,៨លានហ្នឹង គឺយើងយកមកដឹងតែបើកប្រាក់ខែជូន អត់មានការរើសអើង វាអត់មានការជជែក។ បញ្ហាហ្នឹងមិនៗអាចជាកម្មវត្ថុនៃការជជែកបានទេ។ តែយើងមានប្រាក់ខែ យើងមានសាច់ប្រាក់យើងត្រូវតែបើកប្រាក់ខែជូនមន្ត្រីរាជការ គ្រប់មន្ត្រីបុគ្គលិក និងរួមទាំងចៅក្រមគ្រប់ៗគ្នា គឺអត់មានការរើសអើងក្នុងការគិតគូររបស់រដ្ឋបាលកម្ពុជា។

[១៥:៣៨:០០]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណ។ ប្រហែលជាខាងលោកអនុប្រធានរដ្ឋបាលអាចផ្តល់យោបល់ខ្លះអំពីការដែលខកខានមិនបើកប្រាក់ខែទៅដល់ចៅក្រមនេះ វាអាចធ្វើឲ្យប៉ះពាល់ដែលឯករាជ្យភាពរបស់គាត់។ តើលោកអាចផ្តល់ជាយោបល់ទេថាពិតជាអ៊ីចឹងមែននោះ?

**លោក ឃ្នុត រ៉ូសាន់ហោក៖**

សំណួរចុងក្រោយ ខ្ញុំមិនដឹងទេថាវាប៉ះពាល់យ៉ាងណានោះ។ តែខ្ញុំសូមផ្តល់យោបល់ជាអកុសលដែលថាមន្ត្រីតុលាការមិនទទួលបាននូវប្រាក់ខែកាលពីមុន។ ចំណុចនេះគឺយើងដឹងច្បាស់ ហើយកាលពីអតីតកាលក៏មិនមានប្រាក់ឧបត្ថម្ភធនដូចដែលយើងបានបញ្ជាក់ចែងនៅក្នុងសំណើសុំប្រាក់ឧត្ថម្ភធននោះផងដែរ។ សេណារីយ៉ូហ្នឹង កាលពីមុនអត់មានទេ យើងអត់មានឧបត្ថម្ភធននោះទេ។ កាលពីមុនគ្មានម្ចាស់ជំនួយណាមួយដែលផ្តល់ថវិកាទៅដល់ខាងជាតិ ហើយរដ្ឋាភិបាលនោះក៏មិនបានបំពេញកាតព្វកិច្ចទៅតាមមាត្រា១៥ ផងដែរ។ ដូច្នេះ បានន័យថានៅពេលនោះ ធ្វើឲ្យមិនមានប្រាក់ខែ។

អង្គការសហប្រជាជាតិបានស្នើសុំម្ចាស់ជំនួយធ្វើការលៃលកផ្ទេរពីខាងអន្តរជាតិនេះទៅដល់ខាងជាតិ។ ដើម្បីជាវិធានការបណ្តោះអាសន្ននៅពេលនោះ។ ម្ចាស់ជំនួយទាំងអស់នោះ គឺថាអង្គការសហប្រជាជាតិបានទៅទាក់ទង ហើយគេឯកភាព។ ដូច្នេះ ក្រោយមកក៏យើងបានផ្ទេរលុយមួយចំនួនទៅខាងជាតិ។ ដោយដាក់លក្ខខណ្ឌថា មន្ត្រីតុលាការ គឺមិនរួមបញ្ចូលនៅក្នុងកញ្ចប់ថវិកានេះទេ។ នៅពេលដែលយើងនិយាយថា មន្ត្រីតុលាការនេះ គឺយើងសំដៅទៅលើអង្គជំនុំជម្រះ។ ហើយខាងការិយាល័យសហព្រះរាជអាជ្ញានៅពេលនោះ ក៏មិនទទួលបានប្រាក់ខែដូចគ្នា។ អ៊ីចឹងបានន័យថា គឺក្តោបរួមទៅលើមន្ត្រីតុលាការទាំងអស់។ ហើយចំពោះសហសេវិករបស់ខ្ញុំ ក៏មិនទទួលបានប្រាក់ដូចគ្នាក្នុងពេលនោះ។ ដោយសារនៅក្នុងនោះ មានលក្ខខណ្ឌ។ លក្ខខណ្ឌកម្ចីលើកទី២ គឺគេផ្តល់ថវិកាប្រាក់ខែទៅដល់តែអ្នកមានមុខតំណែងថ្នាក់ទាបតែប៉ុណ្ណោះ ចំពោះ *ភី-ហ្វាយ* ហើយទៅខាងលើទៀត គឺគេមិនផ្តល់ប្រាក់ខែ។

[១៥:៤១:៣០]

ដូច្នេះ បានន័យថាការកម្ចីលើកទី២នេះ គឺគេឲ្យខ្ចីតែពី ភី-៤ ចុះមកក្រោយ។ ចាប់ពី *ភី-ហ្វាយ* ឡើងទៅ គឺគាត់ទទួលរងនូវបញ្ហាដែលមិនមានប្រាក់ផ្តល់ជូននាពេលនោះ។ នៅពេលដែលរដ្ឋាភិបាលបានយល់ច្បាស់អំពីបញ្ហាហ្នឹង ថាមិនមានថវិកាស្ម័គ្រចិត្តផ្តល់ឲ្យខាងជាតិ នៅពេលនោះរដ្ឋាភិបាលបានបំពេញកាតព្វកិច្ច ហើយបានផ្ទេរលុយ ១,៨លានដុល្លារទៅដល់តុលាការ ដើម្បីបញ្ចប់លើបញ្ហានូវការខ្វះ

ថវិកាតាំងពីដើមខែ -- ខែមុនៗមក។ ដូច្នេះ បញ្ហានេះត្រូវបានដោះស្រាយ។ យើងយល់ច្បាស់ទាំងអស់គ្នា។ ហើយខ្ញុំគឺថាមិនអាចលើកឡើងយោបល់ថា អំពីថាតើវាប៉ះពាល់ឯករាជ្យភាពរបស់ចៅក្រម ឬតុលាការដែរឬទេ នៅពេលដែលមិនទទួលបានប្រាក់ខែ។ ខ្ញុំមិនមានយោបល់អ្វីនោះឡើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណច្រើន។ បាទ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។

ជាបឋមនោះ ខ្ញុំចង់ -- យើងពិនិត្យមើលស្ថានភាពបច្ចុប្បន្ន។ គឺយើងមិនមើលអំពីឆ្នាំមុននោះទេ យើងមើលកំពុងឆ្នាំនេះ។ គឺកាលបរិច្ឆេទនៅឆ្នាំនេះ។ បើសិនជាខ្ញុំយល់ច្បាស់ពីព័ត៌មានដែលខ្ញុំទទួលបាននោះ ចំពោះខាងអន្តរជាតិ មូលនិធិដែលទទួលបាននៅក្នុងក្របខ័ណ្ឌនៃការចូលរួមស្ម័គ្រចិត្តរបស់រដ្ឋផ្សេងៗនោះ គឺថាបានប្រើអស់ហើយ។ ដូច្នេះ ខ្ញុំចង់ដឹងថាតើប្រភពនៃមូលនិធិសម្រាប់ផ្តល់ថវិកាជូន អ.វ.ត.ក នៅក្នុងឆ្នាំ -- កាលបរិច្ឆេទនេះយ៉ាងនេះ? ហើយតើមូលនិធិនេះ មកពីអង្គការសហប្រជាជាតិ ឬក៏វាពាក់ព័ន្ធទៅនឹងដំណើរការនៃឧបត្ថម្ភធនដែលកំពុងតែត្រូវបានពិភាក្សានោះ? ហើយតើអាចផ្តល់ជូនអំពីតួលេខពាក់ព័ន្ធនឹងបញ្ហានេះដែរឬទេ? គឺថាអាចសូមឲ្យផ្តល់ជូនអំពីតួលេខនៃមូលនិធិដែលបានផ្តល់ជូន ដែលមិនមែនជា -- ដែលជាតួលេខនៃការចូលរួមរបស់រដ្ឋផ្សេងៗជាលក្ខណៈស្ម័គ្រចិត្តនោះ។

[១៥:៤៤:១២]

**លោក ឃ្នុត រ៉ូសាន់ហោក៖**

សូមអរគុណលោកចៅក្រម។ ចំពោះខាងជាតិ គឺអត់មានលុយថវិកាចេញមកពី យូ.អិន ផ្តល់ឲ្យនោះទេ។ ខាងជាតិគឺម្ចាស់ជំនួយជាអ្នកផ្តល់ថវិកា ហើយនិងថវិកានោះមកពីរដ្ឋាភិបាល។ ដូច្នេះបានន័យថាថវិកាទាំងពីរមកពីខាងរដ្ឋាភិបាល និងម្ចាស់ជំនួយ។ បានន័យថាដោះស្រាយពេញមួយឆ្នាំ២០១៣នេះតែម្តង។ ចំពោះខាងអន្តរជាតិ ដូចដែលខ្ញុំបានបញ្ជាក់អ៊ីចឹង គឺមានការសន្យាជាក់លាក់ពី-- នៅក្នុងឆ្នាំបច្ចុប្បន្ននេះ។ ហើយបានន័យថានៅចុងត្រឹមឆ្នាំនេះ យើងមានសល់ខ្លះដែរ។ ដូច្នេះដូចដែលខ្ញុំបានបញ្ជាក់អ៊ីចឹង បានន័យថាការសន្យាជាក់លាក់នេះ មិនមែនថាយើងមានលុយនៅក្នុងធនាគារនោះទេ យើងត្រូវការពេលវេលាឲ្យមានការផ្ទេរលុយជាសាច់ប្រាក់។ ហើយ ប្រសិនបើចាំបាច់អង្គការសហប្រជាជាតិនិងធ្វើការអារ៉ង់។ បានន័យថា ផ្តល់ថវិការបស់អង្គការសហប្រជាជាតិនេះជាមុនសិនបន្ទាប់មកយកលុយ

សងទៅវិញ។ ដូច្នេះបានន័យថា វាបានបញ្ចប់ត្រឹមចុងឆ្នាំ នេះនៅពេលដែលយើងប្រើប្រាស់ថវិកាទៅតាមទម្រង់ និងក្របខ័ណ្ឌបែបហ្នឹង។

[១៥:៤៥:៣៣]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកបានពន្យល់ថា គម្រោងនៃឧបត្ថម្ភធននោះគឺពាក់ព័ន្ធទៅនឹងដំណើរការនៃការប្រមូលមូលនិធិ ហើយវាខុសគ្នាអំពីដំណើរការនៃការឯកភាពថវិកា។ ទោះជាយ៉ាងណាក៏ដោយតើលោកអាចពន្យល់បានទេ ថានៅក្នុងឯកសារណាមួយដែលត្រូវបានពិភាក្សានៅញ៉ូយ៉កដែលមានការលើកឡើងអំពីការចំណាយពាក់ព័ន្ធទៅនឹងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២នោះ?

**លោក ឃ្នុត វ៉ូសាន់ហោក៖**

អត់មានទេ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បើតាមទស្សនៈថវិកានោះ តើអាចទេក្នុងការធ្វើការជ្រើសរើសចៅក្រមក្នុងអង្គជំនុំជម្រះទី២នៅពេលដែលការចំណាយថវិកានេះមិនមាននៅក្នុងគម្រោងថវិកានោះ? ប្រសិនបើខ្ញុំស្តាប់មិនច្រឡំទេគឺថា គម្រោងថវិកាមិនទាន់បានអនុម័តនោះទេ។ តើលោកអាចបញ្ជាក់ជូនបានទេ ថានៅពេលណាដែលមានការអនុម័តគម្រោងថវិកា? ហើយប្រសិនបើមានការអនុម័តហើយ ហើយមិនមានការចែងអំពីការចំណាយសម្រាប់ក្រុមប្រឹក្សាជំនុំជម្រះទី២នោះទេ តើវាមានការលំបាកទេក្នុងការជ្រើសរើសចៅក្រមសម្រាប់ធ្វើការនៅក្នុងអង្គជំនុំជម្រះទី២ ឬក៏បុគ្គលិកគាំទ្រដល់ការដំណើរការក្រុមជំនុំជម្រះទី២នោះ?

[១៥:៤៧:០៩]

**លោក ឃ្នុត វ៉ូសាន់ហោក៖**

នេះវាពាក់ព័ន្ធទៅនឹងបញ្ហាថវិកាមិនមែនទៅលើប្រាក់ឧបត្ថម្ភធននោះទេ។ ថវិកានេះគឺថាវាមានក្របខ័ណ្ឌកញ្ចប់មួយថា កញ្ចប់ថវិកាសង្គ្រោះចំពោះខាងជាតិវិញគេហៅថា ជី.ធី.អេ។ នៅពេលដែលយើងធ្វើសកម្មភាពណាមួយដែលមិនមានគ្រោងនៅក្នុងគម្រោងការងាររបស់យើង យើងនឹងទៅជួបជាមួយម្ចាស់ជំនួយ ក្រុមម្ចាស់ជំនួយសំខាន់ៗនោះឲ្យស្នើសុំពួកគាត់ឲ្យយើងអាចប្រើប្រាស់ចំនួនខ្លះនៅក្នុងកញ្ចប់ថវិកាសង្គ្រោះសម្រាប់គោលបំណងណាមួយជាក់លាក់។ ដូច្នេះយើងជម្រាបពួកគាត់អំពីភាពចាំបាច់ក្នុងការត្រូវការថវិកាណាមួយដែលយើងមើលមិនឃើញ ហើយយើងមិនអាចប្រាប់គាត់ថាតើ

ការងារដែលយើងមើលមិនឃើញនោះជាអ្វីនោះទេ ហេតុអីបានយើងប្រាប់មិនបាន? ដោយសារយើងមិនដឹងថាការងារនោះជាការងារអ្វីផងនោះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំចង់ឲ្យយើងនិយាយអំពីតួលេខ និងភាពជាក់ស្តែង។ តើលោកអាចប្រាប់បានទេអំពីចំណាយដំណើរការបច្ចុប្បន្នរបស់អង្គជំនុំជម្រះសាលាដំបូងនេះ តើចំណាយអស់ប៉ុន្មានលោកអាចមានតួលេខច្បាស់លាស់ទេ? ខ្ញុំសន្និដ្ឋានថាបើសិនបើមានការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះទី២ នោះយើងនឹងមានការចំណាយប្រហាក់ប្រហែលគ្នានឹងអង្គជំនុំជម្រះសព្វថ្ងៃនេះ។ ដូច្នេះ សូមឲ្យលោកបញ្ជាក់ឲ្យបានច្បាស់អំពីទំហំនៃការចំណាយដែលគ្រោងទុកសម្រាប់ការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២នេះ។

[១៥:៤៨:៥៧]

**លោក ឃ្នុត រ៉ូសាន់ហោក៖**

ការិយាល័យរដ្ឋបាលមិនបានធ្វើការទាយស្មានទំហំទៅលើការចំណាយរបស់ក្រុមប្រឹក្សាជំនុំជម្រះនោះទេ។ យើងមិនដឹងថាបុគ្គលិកគាំទ្រប៉ុន្មាន? ចៅក្រមយើងនឹងតែងតាំងឬក៏យ៉ាងណានោះ ទេ ដូច្នេះយើងមិនធ្វើការថ្លឹងថ្លែង ឬក៏ប៉ាន់ស្មានទៅលើការចំណាយនោះទេ។ វាមិនអាចធ្វើទៅបាន។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំដឹងថាលោកបានធ្វើការពិនិត្យស៊ីជម្រៅរួចទៅហើយមុននឹងឆ្លើយទៅនឹងអង្គជំនុំជម្រះតុលាការកំពូល។ ដូច្នេះគឺលោកមិនដឹងទេមែនទេ មិនដឹងថាតើចំណាយអស់ប៉ុន្មានទេ? ប្រសិនបើលោកមិនដឹងនោះ សូមឲ្យលោកអាចបញ្ជាក់អំពីការចំណាយរបស់អង្គជំនុំជម្រះសាលាដំបូងបច្ចុប្បន្ននេះគឺមានទាំងចៅក្រម និងបុគ្គលិកគាំទ្រផ្សេងៗទាំងអស់នោះតើចំណាយអស់ប៉ុន្មានដែររហូតមកដល់ពេលនេះ?

**លោក ឃ្នុត រ៉ូសាន់ហោក៖**

ខ្ញុំអាច ក៏ប៉ុន្តែខ្ញុំមានតារាងចំណាយជាមួយខ្ញុំនៅពេលនេះទេ។ ខ្ញុំអាចឆ្លើយតបនាពេលក្រោយថាតើចំនួនជាក់លាក់ប៉ុន្មានដែលចំណាយទៅលើអង្គជំនុំជម្រះសាលាដំបូង និងបុគ្គលិកគាំទ្រ។ ប៉ុន្តែខ្ញុំសូមបន្ថែមថា យើងមិនដែលទទួលបានដំណឹងពីអង្គជំនុំជម្រះថា គាត់ចង់ប្រើប្រាស់ប្រាក់ហ្នឹងបន្ថែមនោះទេ ហើយដំណើរការទាំងអស់ហ្នឹងគឺថាយើងអត់ទទួលបានព័ត៌មានពីអង្គជំនុំជម្រះវិញ តើគាត់ត្រូវការបន្ថែម ឬក៏យ៉ាងណា។

[១៥:៥០:៣២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លើកលែងតែខ្ញុំស្ដាប់ច្រឡំ ក្នុងក្របខ័ណ្ឌនៃការពិនិត្យ ដែលលោកបានធ្វើដើម្បីឆ្លើយតបទៅនឹងអង្គជំនុំជម្រះតុលាការកំពូល ខ្ញុំគិតថាលោកមិនបានពិគ្រោះយោបល់ជាមួយពួកយើងទេ។ ខ្ញុំសូមរំឭកផងដែរថា លើកលែងតែខ្ញុំស្ដាប់ -- លើកលែងតែខ្ញុំមានភ័ន្តច្រឡំ មូលនិធិដែលបានគ្រោងទុកនោះគឺមានការកំណត់១,៨លានដុល្លារសម្រាប់ឆ្នាំកាលបរិច្ឆេទលើកក្រោយ។ តើលោកអាចបញ្ជាក់បានទេ ថាទឹកប្រាក់១,៨លានដុល្លារនេះជាតួរលេខ ជាទឹកប្រាក់ដែលត្រូវបានប្រើសម្រាប់ការចំណាយពាក់ព័ន្ធទៅនឹងការបង្កើតក្រុមប្រឹក្សាជំនុំជម្រះទី២នោះ? តើមានបញ្ចូលទេក្នុងទឹកប្រាក់១,៨លានហ្នឹងបញ្ចូលការចំណាយទៅលើក្រុមប្រឹក្សាជំនុំជម្រះទី២ហ្នឹងទេ?

**លោក ឃ្នុត រ៉ូសាន់ហោក៖**

ជាដំបូងខ្ញុំបានពិគ្រោះយោបល់ជាមួយនឹងអង្គជំនុំជម្រះសាលាដំបូង ពាក់ព័ន្ធទៅនឹងការបង្កើតក្រុមប្រឹក្សាទី២ ដូចដែលមានសរសេរនៅក្នុងអនុស្សរណៈ។ ខ្ញុំបានពិភាក្សា ពិគ្រោះយោបល់ជាមួយលោកប្រធាន ហើយបានសរសេរនៅក្នុងអនុស្សរណៈរបស់ខ្ញុំនេះ។ ១,៨នេះ គឺតំណាងឲ្យភាគរយនៃប្រាក់ទាំងមូលក្នុងគម្រោងថវិកា។ ដូច្នេះវាមិនបានគិតគ្រោងទុកក្នុងនោះទេ។ ខ្ញុំជឿថា១,៨លាននេះគឺគ្រប់គ្រាន់ក្នុងការផ្ដល់មូលនិធិទៅលើការងារជម្រើសមួយណាផ្សេង ហើយនិងគម្រោងការងារបណ្ដោះអាសន្ន។ ហើយអាចស្នើសុំទៅម្ចាស់ជំនួយឲ្យគាត់ធ្វើការកែសម្រួលចំនួនបន្ថែមពីលើនេះបាន ប្រសិនបើចាំបាច់។ ហើយដូច្នេះសរុបមកវិញ គឺវាមិនអាចធ្វើឲ្យរាំងស្ទះ ឬក៏ជាប់គាំងទៅលើដំណើរការណាមួយនោះឡើយ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

តើមូលនិធិនេះមានទេ? ហើយត្រូវមានការសម្រេចឯកភាព អនុម័ត ឬក៏យ៉ាងម៉េច? តើលោកអាចបញ្ជាក់បានទេអំពីឋានៈនៃមូលនិធិសម្រាប់ការមិនបានគ្រោងទុកនេះ?

[១៥:៥២:០៦]

**លោក ឃ្នុត រ៉ូសាន់ហោក៖**

ខ្ញុំជឿថា ខ្ញុំបានពន្យល់លើកឡើងពីខាងដើមរួចមកហើយ គឺថាថវិកាមិនទាន់បានអនុម័ត។ ដូច្នេះ *ខនធិនជេនស៊ី* – ថវិកាសង្គ្រោះបន្ទាន់នេះ – គឺថាមិនទាន់មាននៅឡើយនោះទេ។ ហើយប្រសិនបើការងារណាមួយដែលយើងគិតថា មិនមានផែនការ ដែលយើងមិនបានគ្រោងទុកនៅក្នុងហ្នឹង គឺថាយើងអាច

ត្រឡប់ទៅជួបជាមួយនឹងម្ចាស់ជំនួសសាជាថ្មី ដើម្បីដាក់បញ្ចូលការងារដែលថានឹងគ្រោងនឹងមាននោះ។ គឺថាខ្ញុំនឹងធ្វើការពិគ្រោះយោបល់ជាមួយនឹងប្រធានស្តីទី និងធ្វើការពិភាក្សាលើចំណុចនេះ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ប្រហែលជាខ្ញុំតាមមិនទាន់។ ខ្ញុំដូចជាមិនបានស្តាប់ឮអំពីលោកពាក់ព័ន្ធទៅនឹងកាលបរិច្ឆេទ ថាតើគម្រោងថវិកាត្រូវអនុម័តនៅពេលណា? លោកអាចបញ្ជាក់បានទេអំពីស្ថានភាពអនុម័តថវិកានេះ? ដូចជាកាលពីឆ្នាំ កាលពីបរិច្ឆេទមុនអ៊ីចឹង ការអនុម័តនោះមានរយៈពេលយឺតពេល។ ដូច្នេះ តើលោកអាចដឹងទេ ថាតើការអនុម័តថវិកានេះវាឈានដល់ដំណាក់កាលណាហើយ?

**លោក ឃ្នុត រ៉ូសាន់ហោក៖**

អត់ទេ។ ខ្ញុំគិតថាវាល្ងាចពេកហើយទើបយើងប្រហែលជាចាប់អត់ទាន់ចំណុចដែលខ្ញុំបានលើកឡើង។ គឺថវិកាមិនបានអនុម័តនៅឡើយនោះទេ។

[១៥:៥៤:២២]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

នេះមិនមែនជាសំណួររបស់ខ្ញុំទេ។ សំណួរខ្ញុំ ខ្ញុំចង់ដឹងថាតើលោកគិតថានៅពេលណាដែលមានការសម្រេចអនុម័តទៅលើគម្រោងថវិកានោះ? ខ្ញុំយល់ហើយថាថវិកាមិនទាន់អនុម័ត អ៊ីចឹងខ្ញុំចង់ដឹងថាតើនៅពេលណាដែលលោកគិតថា សេចក្តីព្រាងថវិកានោះនឹងត្រូវទទួលបានការសម្រេចអនុម័តសម្រាប់ អ.វ.ត.ក នេះ?

**លោក ឃ្នុត រ៉ូសាន់ហោក៖**

វាជាសិទ្ធិសម្រេចរបស់ក្រុមម្ចាស់ជំនួយធំៗ ហើយខ្ញុំមិនអាចបញ្ជាក់ទាយស្មានថាថ្ងៃណានោះទេ។ នៅពេលនេះ គឺថាការពិភាក្សាជិតចប់ហើយ ជិតដល់ចុងបញ្ចប់ហើយ ដូច្នេះប្រហែលជាមិនយូរទេក្នុងពេលឆាប់ៗហ្នឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ជាលក្ខណៈចង្អុលបង្ហាញ តើលោកអាចបញ្ជាក់បានទេថាតើថវិកាចុងក្រោយនោះត្រូវបានអនុម័តនៅពេលណាសម្រាប់ឆ្នាំនេះ ហើយនិងឆ្នាំមុនៗនោះ?

**លោក ឃ្នុត រ៉ូសាន់ហោក៖**

ថវិកាបច្ចុប្បន្ន គឺបានន័យថាពីរឆ្នាំមុន អនុម័តតាំងពីពីរឆ្នាំ។ ថវិកាបច្ចុប្បន្នដែលកំពុងតែយក

ទៅពិភាក្សាពិចារណានោះ គឺថាសម្រាប់ពីរឆ្នាំបន្ទាប់មិនមែនបច្ចុប្បន្នទេ។ អ៊ីចឹងគឺបច្ចុប្បន្នគឺបានអនុម័តតាំងពីពីរឆ្នាំមុននោះ។

[១៥:៥៥:៥០]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទយើងស្ដាប់គ្នាមិនបាន។ ខ្ញុំចង់ឲ្យលោកបង្ហាញជាឧទាហរណ៍ ថាតើនៅពេលណាដែលថា ថវិកា ឆ្នាំកាលបរិច្ឆេទមុននោះត្រូវបានអនុម័ត។ តើក្នុងការខែកក្កដា ខែសីហា ឬក៏ខែណានៅក្នុងឆ្នាំមុននោះដែលគេអនុម័តថវិកានោះ?

**លោក ឃ្លុត វ៉ូសាន់ហោក៖**

ថវិកាបច្ចុប្បន្នគឺអនុម័តតាំងពីពីរឆ្នាំមុនឯណោះ មិនមែនឆ្នាំហ្នឹងទេ។ បាទខ្ញុំសូមបញ្ជាក់។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

តាំងពីពីរឆ្នាំមុនហ្នឹងតើនៅពេលណា? ខ្ញុំចង់ដឹងនៅពេលប្រាកដ ពេលណាដែលគេអនុម័តនោះ? ខែមករា ខែកញ្ញា ឬក៏ខែណា ដែលលោកថាពីរឆ្នាំមុននោះ?

**លោក ឃ្លុត វ៉ូសាន់ហោក៖**

ខ្ញុំត្រូវតែមើលកំណត់ចំណាំរបស់ខ្ញុំ មិនដឹងថ្ងៃណានោះទេ។ ប៉ុន្តែខ្ញុំជឿថាប្រហែលជាក្នុងខែកុម្ភៈ កាលពីពីរឆ្នាំមុន។ ខ្ញុំត្រូវទៅមើលកំណត់ហេតុរបស់ខ្ញុំវិញ ដើម្បីឲ្យចាំ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកអនុប្រធានការិយាល័យរដ្ឋបាល។

**ប្រធានអង្គជំនុំ៖**

បាទអរគុណច្រើន។ ឥឡូវនេះដល់ពេលសម្រាកហើយ ថ្ងៃនេះឃើញថាមានការនឿយហត់ណាស់។ ហើយប៉ុន្តែមុននឹងសម្រាកនេះ អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគីដទៃទៀតថា នៅថ្ងៃស្អែកនេះ ព្រលឹមឡើង នៅពេលដែលចាប់ផ្ដើមហ្នឹង អង្គជំនុំជម្រះនឹងផ្ដល់វេទិកាជូនទៅភាគីដទៃទៀត ដើម្បីមានឱកាសក្នុងការសាកសួរដល់ ប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាលអំពីរបៀបវារៈទី២ អម្បាញ់មិញនេះពាក់ព័ន្ធជាមួយនឹងបញ្ហាបែបបទរដ្ឋបាលសម្រាប់រៀបចំកិច្ចដំណើរការក្នុងសំណុំរឿង ០០២ ជាមុន មុននឹងអង្គជំនុំជម្រះបន្តទៅរៀបវារៈមួយទៀត។ វារៈទី៣ គឺវិសាលភាពនៃសំណុំរឿង ០០២/០២។ សូមភាគីដទៃផ្សេងទៀតជ្រាប។

បាទឥឡូវនេះដល់ពេលសម្រាកហើយ។ យើងសម្រាកសម្រាប់រសៀលនេះត្រឹមនេះ ហើយកិច្ចប្រជុំរបស់យើង គឺលើកបន្តទៅធ្វើនៅព្រឹកថ្ងៃស្អែកចាប់ផ្តើមពីម៉ោងប្រាំបួន គឺនៅទីនេះ។ សូមអញ្ជើញឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់សូមអញ្ជើញចូលរួមតាមពេលវេលា និងទីកន្លែងកំណត់។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមនៅក្នុងកិច្ចប្រជុំនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន ដោយឲ្យនាំគាត់មកនៅត្រឹមបន្ទប់ឃុំខ្លួននៅពីក្រោមសាលសវនាការនេះ ដោយមានរៀបចំនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការកិច្ចប្រជុំពិភាក្សានេះពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥៩ នាទី)*